ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Dec-2011, 15:31
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី១០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក សេង ប៊ុនឃាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ច័ន្ទ តារាស្មី

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែរកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គឹមសួន

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine SUTZ)*

លោក អូលីវីយេ៉ បាហ៊ូញ

*(Mr. Olivior BAHOUGNE)*

លោកស្រី នូស៊ីន សាការ៉ាទី

*(Ms. Nushin SAKARATI)*

លោក គ្រីស្ទីន ម៉ាទីណូ

*(Mr. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**មន្ត្រីអង្គភាពគាំពារសាក្សី/អ្នកជំនាញ៖**

លោក ញ៉ែម សំណាង

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី នូស៊ីន សាកាវ៉ាទី | អង់គ្លេស |
| លោក នួន ជា | ខ្មែរ |
| លោក ឡុង នរិន្ទ (TCW-395) | ខ្មែរ |
| លោក ញ៉ែម សំណាង | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅជនជាប់ចោទ នួន ជា**

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........................................ទំព័រ ២

សួរដោយលោក ឌេល លីសាក់ ផ្តើមពី........................................ទំព័រ ២១

**ការសួរសំណួរទៅសាក្សី ឡុង នរិន្ទ** (TCW-395) (តាមប្រព័ន្ធសោតទស្សន៍)

សួរដោយ លោកស្រី នូស៊ីន សាកាវ៉ាទី........................................ទំព័រ ៤១

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី........................................ទំព័រ ៤៥

សួរដោយលោក សុន អារុណ ផ្តើមពី........................................ទំព័រ ៥៨

សួរដោយលោក ម៉ៃខល ផេសមិន ផ្តើមពី........................................ទំព័រ ៧៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៣១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមផែនការដែលបានជម្រាបជូនដល់ភាគី និងសាធារណជនកាលពីម្សិលមិញ អង្គជំនុំជម្រះមានបំណងស្ដាប់សក្ខីកម្មសាក្សីមួយរូបឈ្មោះ ឡុង នរិន្ទ តាមប្រព័ន្ធសោតទស្សន៍។ ប៉ុន្តែការស្ដាប់សក្ខីកម្មចំពោះសាក្សីរូបនេះ នាពេលនេះមិនអាចប្រព្រឹត្តទៅបាន ដោយបញ្ហាប្រព័ន្ធសោតទស្សន៍មិនអាចដំណើរការបាននៅទីនោះ។

ហេតុដូច្នេះ អង្គជំនុំជម្រះបន្តការសួរចម្លើយជនជាប់ចោទ នួន ជា ជាជំនួសពេលនេះ ដូចអ្វីដែលអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនកាលពីម្សិលមិញ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា មកកាន់ឈើរាងវង់ក្រចកសេះ នៅពីមុខអង្គជំនុំជម្រះនេះ។

*(លោក នួន ជា ដើរមកកាន់ឈើរាងវង់ក្រចកសេះ)*

[០៩:០៥:៤៤]

**ប្រធានអង្គជំនុំ៖**

សួស្ដីលោក នួន ជា នៅព្រឹកនេះអង្គជំនុំជម្រះបន្តការសួរចម្លើយលោកជាបន្តទៀត ពាក់ព័ន្ធជាមួយនឹងអង្គហេតុវគ្គទីមួយ ដែលអង្គជំនុំជម្រះបានកំណត់ក្នុងការធ្វើសវនាការ។ ហើយកាលពីម្សិលមិញមុនពេលសម្រាក គឺដល់ចៅក្រមប្រឹក្សាផ្សេងទៀត ដែលសួរបន្តពីចៅក្រមដែលយើងបានកំណត់ប្រគល់ភារកិច្ចក្នុងការរៀបចំតាំងសំណួរចំពោះលោក។ ហើយម្សិលមិញ គឺដល់វេនលោក ហ្សង់ម៉ាក។ លោកចៅក្រម ហ្សង់ម៉ាក តើមានសំណួរអ្វីដែលត្រូវសួរដល់លោក នួន ជា ដែរឬទេ?

សូមអញ្ជើញលោកចៅក្រម!

[០៩:០៦:៤២]

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

សូមគោរពលោកប្រធាន ខ្ញុំសូមកែសម្រួលបន្តិចកាលពីម្សិលមិញ។ អំពីរឿងជម្លៀសប្រជាជន ខ្ញុំសូមបញ្ជាក់ដូចតទៅនេះ៖ មានការប្រជុំគណៈអចិន្ត្រៃយ៍រួមជាមួយសមាជិកមជ្ឈិមមិនពេញអង្គខ្លះនៅពាក់កណ្ដាលឆ្នាំ១៩៧៤។ ខ្ញុំសូមបញ្ជាក់ថែម គឺប្រជុំគណៈអចិន្ត្រៃយ៍ និងសមាជិកមជ្ឈិមមិនពេញអង្គខ្លះនៅក្នុងឆ្នាំ១៩៧៤ សម្រេចអំពីរឿងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្ត។

សូមជម្រាប គោរពលោកប្រធានប៉ុណ្ណឹង។

[០៩:០៧:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។

សូមអញ្ជើញលោក ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោក នួន ជា អ្វីដែលលោកទើបតែបាននិយាយអម្បាញ់មិញនេះ តើលោកអាចបញ្ជាក់ជូនតុលាការបានទេ ថាតើលោក អៀង សារី ហើយនិងលោក ខៀវ សំផន ជាសមាជិកនៃកិច្ចប្រជុំវិសាមញ្ញនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ដែលបានប្រព្រឹត្តទៅនៅពាក់កណ្ដាលឆ្នាំ៧៤? ហើយនៅក្នុងអំឡុងកិច្ចប្រជុំនោះមានការវិភាគអំពីការជម្លៀសចេញពីទីក្រុងភ្នំពេញ។

[០៩:០៨:៣០]

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមគោរពលោកប្រធាន ពេលនោះគ្មានលោក អៀង សារី គ្មានលោក ខៀវ សំផន ទេ។

**ស៖** តើក្នុងកិច្ចប្រជុំនោះមានកំណត់ហេតុ មានការកត់សម្គាល់ ឬហើយមានការបញ្ជូនកំណត់ហេតុនោះទៅដល់សមាជិកនៃគណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍ទេ?

**ឆ៖** ក្នុងការប្រជុំនោះ គឺគណៈអចិន្ត្រៃយ៍មកប្រជុំ។ កាលនោះដូចខ្ញុំវតែ អៀង សារី មួយទេ ព្រោះគាត់នៅបរទេស។ ឯគណៈមជ្ឈិមមកមិនពេញអង្គនោះទេ។ ប្រជុំហើយឲ្យគណៈអចិន្ត្រៃយ៍ដែល

មកប្រជុំ និងគណៈមជ្ឈិមដែលមកប្រជុំនេះទៅផ្សាយសេចក្ដីសម្រេចនៅភូមិភាគរបស់ខ្លួននីមួយៗ។

[០៩:១០:០៥]

សៈ នួន ជា តើលោក អៀង សារី និង ខៀវ សំផន អាចមិនដឹងអំពីសេចក្ដីសម្រេចដែលបានធ្វើឡើងនៅក្នុងការប្រជុំនោះ គឺនៅក្នុងការប្រជុំនោះគឺមានការសម្រេចអំពីមាគ៌ានយោបាយ តើថាគាត់អាចមិនដឹងអំពីអ្វីដែលគេគ្រោងនឹងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បើតាមខ្ញុំគិត គាត់មិនបានចូលប្រជុំ គាត់មិនបានដឹងទេ។

**សៈ** នេះមិនមែនជាសំណួរដែលខ្ញុំសួរច្បាស់លាស់នោះទេ។ លោកបានថា បន្ទាប់ពីកិច្ចប្រជុំនោះមក គឺមានការបង្គាប់ឲ្យអ្នកចូលរួមទាំងអស់ឲ្យផ្សព្វផ្សាយនូវសេចក្ដីសម្រេចដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំនោះ ដើម្បីឲ្យមានការអនុវត្តសេចក្ដីសម្រេចនោះ។ ដូច្នេះ ជាថ្មីម្ដងទៀត ខ្ញុំចង់សួរថា តើលោក ខៀវ សំផន និងលោក អៀង សារី ត្រូវបានផ្ដល់ដំណឹង ឬក៏គាត់ដឹង ឬក៏គាត់បានទទួលពីការផ្សព្វផ្សាយនូវសេចក្ដីសម្រេចដែលធ្វើឡើងនៅក្នុងការប្រជុំវិសាមញ្ញនោះ?

**ឆ៖** ខ្ញុំសូមជម្រាបដូចតទៅនេះ តាមខ្ញុំ លោក អៀង សារី នៅឯបរទេសនោះទេ ឯលោក ខៀវ សំផន គាត់មានភារកិច្ចផ្សេង គឺគាត់មានភារកិច្ចខាងធ្វើបញ្ជីតម្លៃ ចំណេញ ចំណូល អីៗ ដូច្នោះ គាត់គ្មានភារកិច្ចមកខាងរឿងជម្លៀសប្រជាជន ឬមិនជម្លៀសប្រជាជនអីនោះ គាត់គ្មានភារកិច្ចហ្នឹងទេ។

[០៩:១២:៣៨]

**សៈ** លោក នួន ជា តើចាប់ពីពេលណាទៅដែលលោក ខៀវ សំផន បានក្លាយជាសមាជិកបម្រុងរបស់គណៈអចិន្ត្រៃយ៍? តើនៅក្នុងពេលប្រជុំនោះ គាត់ជាសមាជិកបម្រុងនៃគណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ គាត់មិនទាន់ជាសមាជិកបម្រុងរបស់គណៈអចិន្ត្រៃយ៍ទេ។ ខ្ញុំសូមជម្រាបលោកដូចតទៅនេះ គណៈអចិន្ត្រៃយ៍គ្មានសមាជិកបម្រុងទេ។ បើមានៗតែគណៈមជ្ឈិមបម្រុង ឯគណៈអចិន្ត្រៃយ៍សុទ្ធតែជាគណៈអចិន្ត្រៃយ៍ជ្រើសរើសមកពីសមាជិកមជ្ឈិមដែលពេញអង្គ-- ដែលពេញសិទ្ធ។ ដូច្នោះ គ្មានពាក្យហៅថា “អចិន្ត្រៃយ៍បម្រុង” ទេ។

**សៈ** ដូច្នេះ តើនៅពេលណាដែលលោក ខៀវ សំផន ក្លាយទៅជាសមាជិកគណៈអចិន្ត្រៃយ៍? សូមទោសគឺគណៈមជ្ឈិម?

**ឆ៖** សូមអភ័យទោស ខ្ញុំចាំមិនបានទេ។

**ស៖** ហើយជាទូទៅតើលោកអាចជម្រាបតុលាការបានទេថាលោកអាចចាំបានទេថា នៅពេលណាដែលលោក ខៀវ សំផន បានក្លាយទៅជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** សូមជម្រាបលោក ដូចជាខ្ញុំបានជម្រាបមកហើយ ខ្ញុំមិនដែលជិតស្និទ្ធជាមួយលោក ខៀវ សំផន ទេ។ គ្រាន់តែស្គាល់គ្នា ថាគាត់មកពីស្រុកបារាំង ឯគាត់ជាសមាជិកបក្ខ ចូលបក្ខពីអង្កាល់អីពីអង្កាល់ ខ្ញុំមិនបានដឹងទេ ពីព្រោះខ្ញុំសូមជម្រាបយ៉ាងណានេះ។

ថ្ងៃមួយក្នុងឆ្នាំ១៩៧៥ អូ! ៧៤, ៧៥អឺឬ ៧៣, ៧៤ ប៉ុល ពត បានហៅខ្ញុំទៅប្រាប់ថា មិត្តមិនបាច់ទៅរវល់ខាងផ្នែកបញ្ហាជនគេមកពីបរទេសទេ ពីព្រោះមិត្តអនុវត្តនយោបាយរណសិរ្សសម្រាប់បញ្ហាជនមិនផូវផង់។ ដូច្នោះ ខ្ញុំគ្មាននាទីអីពីរឿងបញ្ហាជន ដែលមកពីក្រៅប្រទេសទេ ហើយគាត់ប្រាប់ថែមទៀត ថាឥឡូវសភាពការណ៍វាប្រែប្រួលអ៊ីចឹង មិត្តគិតខំតែខាងអប់រំរៀនសូត្រទៅបានហើយ។

[០៩:១៦:២៥]

**ស៖** ខ្ញុំនិយាយអំពីកិច្ចប្រជុំវិសាមញ្ញនេះឡើងវិញម្តងទៀតនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ បើតាមលោក តើមានសេចក្តីសម្រេចក្នុងការបណ្តេញលោក ខៀវ សំផន ចេញពីកិច្ចប្រជុំនេះទេ?

**ឆ៖** សូម ខ្ញុំសូមសួរអនុញ្ញាតជម្រាប បណ្តេញយ៉ាងម៉េច? បណ្តេញឲ្យចេញពីអង្គប្រជុំ?

**ស៖** បាទ, ជាសេចក្តីសម្រេចដែលមិនកោះហៅគាត់ឲ្យចូលរួមក្នុងកិច្ចប្រជុំ ថាមានសេចក្តីក្នុងការមិនកោះហៅលោក ខៀវ សំផន នៅក្នុងកិច្ចប្រជុំដែលក្នុងនោះគេជជែក អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ឆ៖** មិនមានសិទ្ធិអីទៅបណ្តេញគាត់ ឬក៏មិនហៅទេ ពីព្រោះគាត់គ្មានសិទ្ធិចូលប្រជុំទេ ហៅតែដូចខ្ញុំជម្រាបអំមិញអ៊ីចឹងមានតែគណៈអចិន្ត្រៃយ៍ដែលខ្វះ អៀង សារី ម្នាក់ ហើយនិងគណៈមជ្ឈិមមិនពេញអង្គមួយចំនួនតែប៉ុណ្ណឹងទេ។

[០៩:១៨:០០]

**ស៖** លោក នួន ជា គឺថាសមាជិកមួយចំនួនបានចូលរួមព្រោះត្រូវបានគេកោះហៅ ហើយអ្នកមួយចំនួនទៀតមិនត្រូវបានគេកោះហៅ។ ហេតុអ្វីបានជាមានសមាជិកខ្លះត្រូវបានគេកោះហៅ ហើយសមាជិកខ្លះទៀតមិនត្រូវបានគេកោះហៅ?

**ឆ៖** បញ្ហានេះ តាមខ្ញុំចាំសម្រេចនឹងលេខាគណៈភាគ គេជ្រើសរើស ឯខាងមជ្ឈិមគ្រាន់តែជម្រាបថាឲ្យជ្រើសរើសគណៈមជ្ឈិមមួយចំនួន ឯការជ្រើសរើសយ៉ាងម៉េចៗនោះសម្រេចតែនឹងលេខាគណៈភាគគេសម្រេច។

**ស៖** តើលោក ខៀវ សំផន ជាសមាជិកភូមិភាគ ឬក៏គាត់ចូលរួមនៅក្នុងគណៈមជ្ឈិម?

[០៩:១៩:១៨]

**ឆ៖** គាត់មិនមែនជាសមាជិកភូមិភាគទេ។ ឯគាត់ជាសមាជិកមជ្ឈិមពីអង្កាល់ណា អីអង្កាល់ណា ខ្ញុំមិនបានដឹងទេ ដូចខ្ញុំបានជម្រាបលោកអម្បាញ់មិញហើយ គឺថាប៉ុល ពត ប្រាប់ខ្ញុំថាមិត្តមិនបាច់ទៅរវល់ខាងណោះទេ ទុកឲ្យគេខាងណោះទៅ ព្រោះខាងណោះប៉ុល ពត គាត់ទទួលខាងបញ្ញាជនដែលមកពីប្រទេសក្រៅ។ ប៉ុល ពត គាត់អ្នកទទួលខុសត្រូវ។

**ស៖** តើលោកដឹងថា ខៀវ សំផន គឺជាសមាជិកគណៈមជ្ឈិម ឬក៏អត់ទេ? ថាតើលោកដឹងដែរឬទេ?

**ឆ៖** សូមជម្រាបលោក ខ្ញុំមិនបានដឹងទេ។

**ស៖** ប្រសិនបើលោកមិនដឹងទេ ដូច្នេះ គឺលោកមិនដឹងថាគាត់ជាសមាជិកគណៈមជ្ឈិមទេ។ អីចឹងលោកច្បាស់ទេ ថាគាត់មិនចូលរួមនៅក្នុងកិច្ចប្រជុំនោះ តើអីចឹងទេ?

**ឆ៖** ពេលណា-- នេះសម្រេចនឹងលេខាបក្ស ប៉ុល ពត គាត់ចង់ហៅប្រជុំ គាត់ហៅប្រជុំ ប៉ុន្មាននាក់អីប៉ុន្មាននាក់ដែលចាំបាច់។ បើគាត់ឃើញថាមិនចាំបាច់ទេ គាត់មិនហៅមកប្រជុំទេ ទុកឲ្យគេធ្វើការងាររបស់គេចុះ។

[០៩:២១:៤៨]

**ស៖** ចំពោះទំនាក់ទំនងរវាងកម្លាំងនៅខាងក្នុង ហើយនិងលោក អៀង សារី នៅសម័យនោះ លោក អៀង សារី គាត់នៅប៉េកាំង ឬក៏គាត់នៅកន្លែងណាផ្សេងទៀត?

**ឆ៖** បញ្ហានេះ ខ្ញុំមិនអាចឆ្លើយបានទេ ពីព្រោះខ្ញុំមិនទទួលភារកិច្ចខាងហ្នឹងទេ។

**ស៖** ដូច្នេះលោកមិនដឹងទាំងស្រុងតែម្តង ថាតើសមាជិកគណៈអចិន្ត្រៃយ៍អាចមានទំនាក់ទំនងជាមួយលោក អៀង សារី គឺលោកមិនដឹងទាល់តែសោះតែម្តងឬយ៉ាងម៉េច? លោកមិនដែលដឹងអំពីការទំនាក់ទំនងរវាងគណៈអចិន្ត្រៃយ៍និងលោក អៀង សារី នៅសម័យនោះ?

[០៩:២២:៤៨]

**ឆ៖** នៅសម័យនោះ ខ្ញុំយូរៗប្រហែលជាបីបួនប្រាំប្រាំមួយខែ ឃើញលោក អៀង សារី ត្រឡប់មកប្រទេសម្តងៗ ក៏ប៉ុន្តែមិនដែលមានកិច្ចការអីជាមួយខ្ញុំទេ។ មានការអីគាត់ទាក់ទងតែជាមួយលេខាបក្ស ប៉ុល ពត ប៉ុណ្ណោះ។

**ស៖** ដូច្នេះ លោក អៀង សារី នៅប៉េកាំងគាត់មានមធ្យោបាយសម្រាប់ទំនាក់ទំនងជាមួយនឹង ប៉ុល ពត មែនទេ?

[០៩:២៣:៤១]

**ឆ៖** បញ្ហានេះ ខ្ញុំមិនបានដឹងទេ ប៉ុន្តែគាត់ទៅមកខ្លួនគាត់។ ខ្ញុំសូមជម្រាបលោកឲ្យច្បាស់ក្នុងការងារបក្សពេលនោះ ការណា ការអ្នកណា អ្នកនោះដឹង មិនមែនការយើង យើងមិនត្រូវដឹង។ យើងដឹងតែការណាធ្វើ យើងដឹងអីចឹង ហើយមិនបាច់ទៅសាកសួរគេ មិនបាច់ទៅអីគេទេ។ ការណាអ្នកនោះការងាររបស់អ្នកណា អ្នកនោះដឹង។ អានេះជាគោលការណ៍សម្ងាត់ ទោះបីជារំដោះហើយក៏ដោយ ក៏នៅតែមានគោលការណ៍សម្ងាត់របស់បក្សដដែល។ ដូច្នោះ កិច្ចការណាត្រូវដឹង លេខាបក្សគេឲ្យដឹង ក្នុងឋានៈខ្ញុំជាអនុ ឬក៏ជាសមាជិកឯទៀតគេឲ្យដឹង។ ប៉ុន្តែកិច្ចការណាគេមិន-- សម្ងាត់ក៏គេមិនឲ្យដឹងដែរ។ សូមចប់។

**ស៖** លោកនួន ជា តើលោកមិនដឹងអំពីតួនាទីរបស់ អៀង សារី នៅប៉េកាំងទេ។ តើមែនទេ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា អៀង សារី នៅប៉េកាំង ដើម្បីទាក់ទងសភាពការណ៍ដែល ប៉ុល ពត ប្រាប់ទៅពីប្រទេសកម្ពុជាឲ្យ អៀង សារី ដឹងថា សភាពការណ៍កម្ពុជាវាយ៉ាងនេះៗ ដូច្នោះរយប្រាប់ឲ្យខាងចិនគេដឹងផង។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ ប៉ុន្តែល្អិតខ្ញុំមិនដឹងទេ។

**ស៖** សំណួរ ខ្ញុំចូលទៅសំណួរមួយទៀត។ លោក នួន ជា លោកបាននិយាយអំពីមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា អំពីការតស៊ូនយោបាយ ការតស៊ូអាវុធ តើលោកអាចជម្រាបតុលាការបានទេថា នៅក្នុងមាគ៌ានយោបាយនេះ មានភាពខុសគ្នារវាងការតស៊ូប្រឆាំងនឹងរបបសង្គមរាស្ត្រនិយម ហើយនិងការតស៊ូប្រឆាំងនឹងសម្តេច សីហនុ។ តើលោក សម្តេច សីហនុ គាត់មានតួនាទីអីសំខាន់ទេនៅក្នុងមាគ៌ានយោបាយនេះ?

**ឆ៖** គោរព, បក្សកុម្មុយនីស្តកម្ពុជាគ្មានមាគ៌ានយោបាយប្រឆាំងនឹងសម្តេច ព្រះនរោត្តម សីហនុ ទេ មានតែមាគ៌ាគោរពអញ្ជើញ សូមឲ្យព្រះអង្គអង្គាល់នោះតម្រង់តំណែងជាប្រធានគណ: ប្រធានរដ្ឋ គឺជាអំណាចខ្ពស់បំផុត។

[០៩:២៧:៣៤]

**ស៖** លោក នួន ជា ខ្ញុំសូមកាត់លោក។ ខ្ញុំមិននិយាយអំពីអ្វីដែលកើតឡើងក្រោយឆ្នាំ៧៥ ទេ គឺយើងខ្ញុំនិយាយអំពីបរិបទប្រវត្តិសាស្ត្រ ដែលកើតឡើងនៅក្នុងរបបសង្គមរាស្ត្រនិយម។ នៅសម័យនោះ តើគណៈបក្សកុម្មុយនីស្តកម្ពុជាហ្នឹងមានគោលជំហរយ៉ាងណាចំពោះសម្តេចនរោត្តម សីហនុ?

**ឆ៖** ពេលនោះ កម្ពុជាប្រជាធិបតេយ្យមានមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ារណសិរ្ស។ មាគ៌ារណសិរ្សរបស់កម្ពុជាប្រជាធិបតេយ្យចែងច្បាស់ថា ប្រមូលកម្លាំងប្រជាជាតិគ្រប់ទាំងអស់ រួមទាំងព្រះរាជវង្សានុវង្ស ដែលមានស្មារតីជាតិ រួមទាំងព្រះករុណាទាំងអស់ គឺថា ដើម្បីប្រមូលកម្លាំងឲ្យបានជាអតិបរមា វៀរលែងតែ ខ្ញុំសូមជម្រាបអ៊ីចេះ វៀរលែងតែពួកសមាសភាពដែលជាបរិវារចក្រពត្តិឈ្លានពាន។

**ស៖** លោក នួន ជា តើខ្ញុំត្រូវយល់ថា តាំងពីយូរណាស់មកហើយ នៅក្នុងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា គឺមានការគ្រោងក្នុងការធ្វើសម្ព័ន្ធភាពជាមួយនឹងសម្តេច នរោត្តម សីហនុ តើអ៊ីចឹងមែនទេ?

[០៩:៣០:០០]

**ឆ៖** ពេលនោះបក្សកុម្មុយនីស្តកម្ពុជា មិនមែនគ្រាន់តែធ្វើសម្ព័ន្ធភាពជាមួយព្រះអង្គប៉ុណ្ណឹងទេ ថែមទាំងទុកព្រះអង្គជាបុគ្គលដែលគោរពបូជារបស់ប្រជាជនកម្ពុជា។

**ស៖** លោក នួន ជា តើលោកចាំអ្វីដែលកើតឡើងនៅខែមីនា ឆ្នាំ១៩៧៣ ដែលពេលនោះ ខ្ញុំយល់ឃើញថាមានឥស្សរភាព ៣៤នាក់ដែលចាត់ទុកថាជាអ្នកឆ្វេងនិយម ហើយនិងត្រូវបានកោះហៅទៅវាំងនៅពេលនោះ ដើម្បីបង្កើតជារដ្ឋាភិបាលមួយរលូន?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំឮតែដំណឹង ក៏ប៉ុន្តែអ្នកណាខ្លះៗខ្ញុំមិនដឹងទេ ពីព្រោះខ្ញុំមិនបានចូលប្រឡូកក្នុងរណសិរ្សហ្នឹងទេ តែខ្ញុំដឹងដំណឹងតាមវិទ្យុតាមអី។

**ស៖** តើអ្នកណាជាសមាជិកនៃមនុស្សទាំង ៣៤នាក់ហ្នឹង ឥស្សរជនទាំង ៣៤នាក់ហ្នឹង? តើសហជនជាប់ចោទទាំងពីរនាក់នៅទីនេះហ្នឹង គឺជាសមាជិកនៃមនុស្សទាំង ៣៤នាក់ហ្នឹងដែរឬទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបហើយថា ខ្ញុំមិនចាំឈ្មោះទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី!

**លោក សុន អរុណ៖**

បើខ្ញុំមិនច្រឡំទេខ្ញុំសូមសួរលោក ហ្សង់ម៉ាក សូមបញ្ជាក់សាជាថ្មីម្តងទៀត ដើម្បីកុំឲ្យកូនក្តីខ្ញុំច្រឡំ។ អំមិញលោកនិយាយថា នៅខែ៣ ឆ្នាំ១៩៧៣ អ៊ីចឹងហើយយ៉ាងម៉េច? ដែលមានកោះហៅព្រះករុណា កោះហៅ ៣៤នាក់ សមាជិក ប.ក.ក នោះ? អ៊ីចឹង ឬក៏ឆ្នាំដែលខ្ញុំកត់ហ្នឹងខុស? ប្រសិនបើជាឆ្នាំហ្នឹង គឺព្រះករុណានៅប៉េកាំងទេ មិនមែនក្នុងវាំងទេ។ ហ្នឹងសូមបញ្ជាក់ឲ្យច្បាស់ សូមអរគុណ។

[០៩:៣៣:១២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ, គឺនៅក្នុងខែមីនា ឆ្នាំ១៩៦៣ អ៊ីចឹងដែលមានការកោះហៅទៅព្រះរាជវាំង អ៊ីចឹងគឺថាការកោះហៅហ្នឹង គឺតាម គឺថាកោះហៅ ឥស្សរជនមួយចំនួនដែលចាត់ទុកថាជាអ្នកឆ្វេងនិយម ហើយគឺថាកោះពួកគាត់នុំង ដើម្បីបង្កើតជារដ្ឋាភិបាលខាងឆ្វេងនិយមមួយ តើព័ត៌មានអស់នេះច្បាស់លាស់ដែរឬទេ? លោក នួន ជា ចាំបានដែរ ឬទេ ទាក់ទងទៅនឹងព្រឹត្តិការណ៍នុំង?

[០៩:៣៣:៥៣]

**ឆ៖** សូមជម្រាបលោក ដូចខ្ញុំបានជម្រាបហើយ ខ្ញុំមិនរវល់-- មិនទាក់ទងពីរឿងអ៊ីចឹងៗទេ ខ្ញុំគិតតែពីរឿងអប់រំកសាងមូលដ្ឋានប្រជាជន ហើយដោយច្រើន គឺគិតគូរអំពីសតិអារម្មណ៍ គោលជំហរទស្សនៈនយោបាយរបស់បក្ខជនធម្មតា ឯរឿងដែលខាងលើៗគេធ្វើយ៉ាងម៉េច អីយ៉ាងម៉េចខ្ញុំមិនបានជាយកចិត្តទុកដាក់ទេ ពីព្រោះរឿងរបស់គេ ឯខ្ញុំវារឿងផ្សេង។

**ស៖** បាទ, លោក នួន ជា តើលោក ប៉ុល ពត និង អៀង សារី បានចូលទៅក្នុងព្រៃម៉ាគីនៅពេលណាដែរ?

**ឆ៖** ៦៣, ៦៤, ៦៥ សូម-- ខ្ញុំសូមគោរពលោក ខ្ញុំចាំមិនច្បាស់ទេ។

**ស៖** បើខ្ញុំ ន័ចម្លើយរបស់លោក នួន ជា ហ្នឹងអត់ត្រូវបានបកប្រែទេ ហើយខ្ញុំមិនដឹងថាបានបកប្រែជាភាសាអង់គ្លេសឬអត់ទេ? តើលោកអាចនិយាយឡើងវិញនូវចម្លើយរបស់លោកបានដែរឬទេលោក នួន ជា? តើលោកអាចឆ្លើយម្តងទៀតបានទេ?

**ឆ៖** ខ្ញុំឆ្លើយម្តងទៀតថា ខ្ញុំចាំមិនច្បាស់ទេ។

**ស៖** តើលោកមិនចាំសំណួរដែលខ្ញុំសួរអម្បាញ់មិញ ឬក៏អត់ចាំពីកាលបរិច្ឆេទដែលលោក ប៉ុល ពត និង អៀង សារី បានចូលទៅក្នុងព្រៃម៉ាគីនោះ?

[០៩:៣៦:៣៤]

**ឆ៖** ខ្ញុំមិនចាំកាលបរិច្ឆេទ ដែលលោក ប៉ុល ពត និង អៀង សារី ចេញព្រៃទេ។

**ស៖** តើចំពោះលោកនោះ ហេតុអ្វីបានជាពួកគាត់ទាំងអស់គ្នាហ្នឹងចូលទៅក្នុងព្រៃម៉ាគីហ្នឹង?

**ឆ៖** សូមជម្រាបលោក ពីព្រោះតាមខ្ញុំដឹង កាលនោះរដ្ឋាភិបាល លន់ នល់, សិរិមតៈ, សឹង ង៉ុកថាញ់ រករឿង រកហេតុ ចោទប្រកាន់ពួកបញ្ញាជនដែលចម្រើន សុទ្ធតែពួកក្រហម។ អានេះខ្ញុំចាំ ខ្ញុំដឹងដំណឹងទេ ខ្ញុំមិនច្បាស់ទេ ប៉ុន្តែខ្ញុំដឹងខ្លះតាមពាក្យចចាមអារ៉ាម ដែលគេនិយាយ ហើយចាប់ រកចាប់។ ដូច្នោះពួកអ្នកអស់នេះ មិនប៉ានរស់នៅក្នុងទីក្រុងភ្នំពេញ ក៏ភៀសខ្លួនទៅនៅមូលដ្ឋានព្រៃ នៅព្រៃ ទៅនៅព្រៃម៉ាគី ហើយខ្ញុំមិនដឹងអាហ្នឹង វាស្អីផង--

**ស៖** ខ្ញុំអត់បានឮការបកប្រែជាភាសាបារាំងហ្នឹង ខ្ញុំមិនដឹងថាជាមានបញ្ហាអីទេនេះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលសម្របសម្រួលផ្នែកខាងប្រព័ន្ធសំឡេង ដើម្បីឲ្យមានការបកប្រែត្រឹមត្រូវ។

**ស៖** បាទ, ជាថ្មីម្តងទៀត ខ្ញុំអត់បានឮការបកប្រែជាភាសាបារាំងទេ ដែលលោកប្រធានបាននិយាយអម្បាញ់មិញនេះ។ ខ្ញុំគិតថាប្រហែលជាមានបញ្ហានៅក្នុងកាប៊ីន ភាសាបារាំង ហើយនិងភាសាអង់គ្លេសហើយមើលទៅ។

*(មានបញ្ហាបច្ចេកទេស)*

[០៩:៤០:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តលោកចៅក្រម ហ្សង់ម៉ាក!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** តើយើងអាចបាននិយាយទៀតទេ ថាបន្ទាប់ពីការចេញដំណើររបស់លោក ប៉ុល ពត ហើយនិង អៀង សារី នោះ។ លោកបានស្ថិតនៅក្នុងទីក្រុងភ្នំពេញ ហើយលោកជាអ្នកទទួលខុសត្រូវខ្ពស់ជាងគេបំផុតនៃបក្សកុម្មុយនីស្តកម្ពុជានៅសម័យនោះ នៅក្នុងទីក្រុងភ្នំពេញនោះ?

**លោក នួន ជា៖**

**ឆ៖** ពិតមែនតែខ្ញុំនៅទីក្រុងភ្នំពេញ តែខ្ញុំមិនមែនជាអ្នកទទួលខុសត្រូវខ្ពស់ជាងគេបំផុតនោះទេ ការដឹកនាំនៅលើលេខាបក្សដដែល។

[០៩:៤១:២០]

**ស៖** តើនៅសម័យនោះ គេហៅលោកគឺថាបងទី២ ហើយឬក៏ពេលណាក្រោយទៀត ដែលត្រូវបានគេហៅលោកថា លោក ជា បងទី២ នោះ?

**ឆ៖** ខ្ញុំសូមគោរពលោក។ ក្នុងបក្សកុម្មុយនីស្តកម្ពុជាគ្មានបងទី១ គ្មានបងទី២ បងទី៣ ទេ។ ក៏ប៉ុន្តែដែលហៅបងទី២ នេះ វាជាប់ពីវប្បធម៌យួន វប្បធម៌វៀតណាម គឺពួកខ្មែរដែលទៅនៅវៀតណាមក្រោយកិច្ចព្រមព្រៀងហ្សឺណែវ មកពេលកិច្ចព្រមព្រៀងហ្សឺណែវ ខ្មែរមួយចំនួនប្រហែលជា១៥០០ ឬ ២០០០ ត្រូវទៅវៀតណាម។ ពួកនេះ ត្រឡប់មកវិញយកវប្បធម៌របស់គេ យកមកនិយាយ ហៅ "អញហាយ" "អញហ្វា" "អញទី"។ ឯក្នុងបក្សខ្មែរគ្មានទេ មានហៅតែ បង, អ៊ំ តែប៉ុណ្ណឹង។

**ស៖** តើលោកជា បងទី២ នៅក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជាមែនឬទេ?

**ឆ៖** ខ្ញុំមិនមែនជាបងទី២ ទេ។ ខ្ញុំជាអនុលេខា ដូច្នោះហៅបងទី២ នេះ វាដូចជាធំពេក ពាក្យថា "បង" នេះ តែបើខ្ញុំជាអនុ ខ្ញុំនៅបន្ទាប់ពីលេខាបក្ស។ ហើយពាក្យនេះ ខ្ញុំមិនដែលប្រើក្នុងបក្សខ្ញុំនៅក្នុងប្រទេសមិនដែលប្រើ ហើយមិនដែលហៅខ្ញុំ បងទី២ ទីអីទេ មិនដែលទេ។ មានតែពួកដែលទៅអប់រំវប្បធម៌ ទៅអប់រំរៀនសូត្រនៅភាគខាងជើងវៀតណាមប៉ុណ្ណឹងទេ ដែលហៅ។

[០៩:៤៤:១៤]

**ស៖** លោក នួន ជា តើនៅក្នុងឋានានុក្រម នៅមានអ្នកណានៅចន្លោះរវាងលេខា ហើយនិងអនុប្រធាន នោះទេ?

**ឆ៖** សូមអភ័យទោស។ ខ្ញុំមិនយល់ពាក្យសំណួររបស់លោក។

**ស៖** សូមនិយាយម្តងទៀត ប៉ុល ពត ជាលេខា លោកជាអនុលេខា តើនៅក្នុងឋានានុក្រមនោះមានអ្នកណាម្នាក់ដែលថាជានៅចន្លោះរវាង ប៉ុល ពត ហើយនិងលោកផ្ទាល់ទេ?

**ឆ៖** គ្មានទេ។

**ស៖** ឥឡូវខ្ញុំសូមត្រឡប់ចូលមកនិយាយព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា គឺថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០។ តើលោកអាចប្រាប់យើងបានទេ ថាតើស្ថានភាពកងកម្លាំងបដិវត្តន៍--កងទ័ពបដិវត្តន៍របស់កម្ពុជានៅពេលធ្វើរដ្ឋប្រហារហ្នឹង តើកម្លាំងហ្នឹងសំខាន់ខ្លាំង មានមនុស្សរាប់ពាន់នាក់។ តើយ៉ាងម៉េចដែរ?

**ឆ៖** លោកសួរអំមិញ ១៨ មីនា ១៩៧០? ខ្ញុំសូមបញ្ជាក់។ ១៨ មីនា ១៩៧០ គឺជារដ្ឋប្រហារ របស់ លន់ នល់ មែនទេ? សូមលោកឲ្យឯកសារខ្ញុំ។

[០៩:៤៦:៤២]

**ស៖** លោក នួន ជា លោកសុំឯកសារអី ព្រោះថានៅក្នុងដីកាដំណោះស្រាយហ្នឹង គឺថានៅថ្ងៃ ១៨ មេសា ឆ្នាំ១៩៧០ ហ្នឹងមានរដ្ឋប្រហារមួយ។

**ប្រធានអង្គជំនុំ៖**

លោក ហ្សង់ម៉ាក បញ្ជាក់កាលបរិច្ឆេទឲ្យបានច្បាស់លាស់ អ៊ីចឹងនៅតែមានបញ្ហា។ ព្រឹត្តិការណ៍នៃរដ្ឋប្រហារដោយ លន់ នល់ ផ្ដួលរំលំរបបនរោត្តម សីហនុ នុ៎ង សង្គមរាស្ត្រនិយមនុ៎ង គឺថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ ពុំមែនខែមេសាទេ។ កាលបើលោកប្រើពាក្យថា ១៨ មេសា វាអត់មានព្រឹត្តិ-ការណ៍អីទាំងអស់។ អ៊ីចឹងការឆ្លើយហ្នឹងក៏ពិបាកនឹងឆ្លើយដែរ ពីព្រោះអត់មានព្រឹត្តិការណ៍ គាត់ស្ទើរស្ទាក់នឹងនៅក្នុងការឆ្លើយ ពីព្រោះកាលបរិច្ឆេទមិនជាក់លាក់ មិនច្បាស់លាស់។ អ៊ីចឹងសូមបញ្ជាក់។

បកប្រែឮទេ?

[០៩:៤៧:៥៤]

**អ្នកបកប្រែ៖**

បាទ, ឮលោកប្រធាន ប៉ុន្តែការបកប្រែទៅជាខ្មែរហ្នឹង គឺល្អៀងបាទ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** គឺថាថ្ងៃ១៨ មីនា ឆ្នាំ១៩៧០។ លោក នួន ជាខ្ញុំចង់និយាយថាថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០។ សំណួរខ្ញុំ គឺចង់ដឹងថា តើកងកម្លាំងបដិវត្តន៍កម្ពុជាសម័យនោះវាស្ថិតក្នុងស្ថានភាពយ៉ាងម៉េចដែរឬទេ? សូមលោកជួយបំភ្លឺបន្តិច។

[០៩:៤៨:៣៦]

**លោក នួន ជា៖**

**ឆ៖** បាទ, សូមគោរពលោកចៅក្រម។ ថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ ពេលនោះខ្ញុំមិនបាននៅក្នុងទីក្រុងភ្នំពេញទេ ខ្ញុំទៅធ្វើសន្និបាតនៅភូមិភាគបូព៌ា។ ដល់ឮថា រដ្ឋសភាក្រោមការគ្រប់គ្រងរបស់ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់ បានដកតំណែង ឬហៅថារដ្ឋប្រហារទៅចុះ របស់សម្ដេច។ ដូច្នោះការប្រជុំរៀនសូត្រនៅភូមិភាគបូព៌ាក៏រំសាយភ្លាម ហើយគ្មានកម្លាំងអាវុធអីទេ គឺថាពួកយកជីវពលដែលចាត់

តាំងឡើងដោយសម្តេចព្រះនរោត្តម សីហនុ ជាកម្លាំងដែលស្មោះត្រង់ជាមួយសម្តេច ជាមួយការតស៊ូនេះចែកជាក្រុម ចែកជាកម្លាំងតូចៗទៅវាយយកប៉ុស្តិ៍ប៉មតូចៗនៅតាមព្រំដែន បានកាំភ្លើងមួយដើមពីរដើម ហើយកាំភ្លើងនោះហៅថា *"កាំភ្លើងម៉ូស្កើតុង"* មិនមែនកាំភ្លើងសម័យអីទេ។ ហើយក្រៅពីនេះមានចលនាបាតុកម្មរបស់ប្រជាជនប្រឆាំងនឹងរដ្ឋប្រហារ ឧមត្ថម្ភសម្តេចព្រះនរោត្តម សីហនុ។ ចលនានេះវារីកម្តងបន្តិចមកពីបូព៌ា ហើយមកខាង-- ដូចចុះ កាលខ្ញុំចាំដូចមកខាងនេ៎ ដែលឆ្លងមកភ្នំពេញហ្នឹងនេ៎ ពីត្រើយម្ខាងមកឆ្លងមកត្រូវទាហានរបស់ លន់ នល់ បាញ់ស្លាប់ច្រើនណាស់។ ហើយក៏បាតុកម្មនេះរីកខ្លួនឯងដោយកម្លាំងប្រជាជនឧបត្ថម្ភសម្តេចនរោត្តម សីហនុ ដែលកាន់មាគ៌ានយោបាយអព្យាក្រឹត។ ហើយកម្លាំងនេះ វាចេះតែរីកម្តងបន្តិចៗទៅ មិនមែនជាកម្លាំង មិនទាន់មានជាកងទ័ពអីធំដុំទេ។

[០៩:៥១:៤៦]

**ស៖** តើបន្ទាប់ពីចលនាហ្នឹងមក មានកម្មាភិបាលដែលគ្រប់គ្រងចលនាហ្នឹងនៅមូលដ្ឋាន ក៏ប៉ុន្តែមិនមែនជាកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា តើមានមនុស្សដែលគេចាត់ទុកថាជារាជានិយម។ តើការបែងចែករវាងអ្នកតំណាងឲ្យបក្សកុម្មុយនីស្តកម្ពុជា ហើយនិងកម្លាំងរបស់ព្រះរាជានោះ?

**ឆ៖** តាមខ្ញុំចាំសម័យនោះមិនមានការបែងចែកទេ។ គឺទាំងអស់គ្នា ទាំងរាជានិយមទាំងបក្សកុម្មុយនីស្ត សមាជិកបក្សកុម្មុយនីស្ត រួមកម្លាំងគ្នា ដើម្បីប្រឆាំងទប់ទល់នឹងរដ្ឋប្រហារ។ មិនមែនត្រឹមតែប៉ុណ្ណឹងប្រជាជនក៏ធ្វើបាតុកម្ម កូដកម្ម ដើម្បីប្រឆាំងនឹងរដ្ឋប្រហាររបស់ លន់ នល់។ ដូច្នោះត្រូវបង្ក្រាមច្រើនណាស់។

**ស៖** លោក នួន ជា តើអ្នកណាជាប្រធានរបស់រណសិរ្សរំដោះកងទ័ពរំដោះជាតិកម្ពុជា តើនេះលោកយល់ទេពាក្យហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបថាកាលណោះ លោកចង់សួរហ្នឹងពីឆ្នាំណា? ឆ្នាំរដ្ឋប្រហារថ្មីៗ ឬក៏ក្រោយរដ្ឋប្រហារ? ឬក៏ពេលរំដោះ? ខ្ញុំសូមកាលបរិច្ឆេទឲ្យច្បាស់។

**ស៖** បាទ, ខ្ញុំសូមភ្ជាប់សំណួរពីរ តើលោកអាចនិយាយអំពីរណសិរ្សរំដោះជាតិប្រជាជនកម្ពុជានៅពេលរដ្ឋប្រហារនោះ ហើយនិងនៅពេលដែលវាយបែកភ្នំពេញនោះ?

[០៩:៥៥:០៥]

ឆ៖ ខ្ញុំសូមជម្រាប ពេលរដ្ឋប្រហារថ្មីៗ គឺអ្នកដែលទទួលខុសត្រូវនៅតាមភាគនីមួយៗបញ្ជា

ការកងទ័ព ហើយកន្លែងនីមួយៗមានមេបញ្ជាការដោយឡែកៗរបស់ខ្លួន មិនទាន់ឯកភាពគ្នាទេ។ ដល់ពេលរំដោះ សូម្បីតែគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាក៏គ្មានកងទ័ពរបស់ខ្លួនដែរ ពឹងពាក់លើកងទ័ពរបស់ភាគ។ តែ ប៉ុល ពត គេទទួលស្គាល់ថាគាត់ជាមេបញ្ជាការកងទ័ព។

**ស៖** តើនៅក្នុងចំណោមអ្នកទទួលខុសត្រូវភូមិភាគនោះ មានប្រធានភូមិភាគខ្លះដែលថាមិនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ភាគច្រើនប្រធានភូមិភាគសុទ្ធតែជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា។

**ស៖** តើលោកអាចនិយាយប្រាប់យើងអំពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលបានចុះហត្ថលេខានៅឆ្នាំ១៩៧៣ រវាងអ្នកតំណាងកុម្មុយនីស្តវៀតណាម និងអាមេរិកដែរឬទេ? តើផលវិបាកនៃកិច្ចព្រមព្រៀងនេះមានយ៉ាងម៉េចដែរមកលើប្រទេសកម្ពុជានោះ?

[០៩:៥៧:៤១]

**ឆ៖** សូមគោរពជូនលោកប្រធាន! កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសរវាងវៀតណាម និងអាមេរិក ពីឆ្នាំមួយពាន់ប្រាំបួនរយ-- ដូចលោកមានប្រសាសន៍អំមិញ៧៣? កាលណោះ ហ្វាម ហ៊ុង ដែលជាសមាជិកការិយាល័យបក្សកុម្មុយនីស្តវៀតណាម សួរខ្ញុំថា តើមិត្តយល់ឃើញយ៉ាងម៉េច-- មិនមែនមិត្តៗ តើប្រជាជនខ្មែរយល់យ៉ាងម៉េចដែលវៀតណាមធ្វើកិច្ចព្រមព្រៀងសន្តិភាព? ខ្ញុំឆ្លើយថា រឿងនេះជារឿងរបស់វៀតណាមទេ ឯប្រជាជនកម្ពុជានៅតែតស៊ូតទៅទៀត។ ហើយសួរថា តើប្រជាជនកម្ពុជាយល់យ៉ាងម៉េច? ហ្វាម ហ៊ុង សួរខ្ញុំ។ ខ្ញុំថាអត់យល់យ៉ាងម៉េចទេ កិច្ចការរបស់អ្នកណាអ្នកនោះធ្វើ។ ខ្ញុំស្មើប៉ុណ្ណឹង ហ្វាម ហ៊ុង មុខក្រហម ស្មានថាប្រជាជនកម្ពុជាឧបត្ថម្ភកិច្ចព្រមព្រៀងសន្តិភាព។ ខ្ញុំឆ្លើយថា ប្រជាជនកម្ពុជានៅតែតស៊ូដដែល។ នេះមានប៉ុណ្ណឹងរឿងហ្នឹង។ ហើយខ្ញុំថែមទៀត ថាបដិវត្តន៍កម្ពុជាមិនរណបបដិវត្តន៍វៀតណាមទេ។ ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនសម្រេចវាសនាជាតិខ្លួនដោយខ្លួនឯង នេះខ្ញុំបន្ថែម។ ហ្វាម ហ៊ុង មុខឡើងក្រហម។ ខ្ញុំយករឿងហ្នឹងមកនិយាយប្រាប់ ប៉ុល ពត។ ប៉ុល ពត បន្ទោសខ្ញុំថា មិត្តឯងមិនចេះនយោបាយបរទេស។ ខ្ញុំថានយោបាយបរទេសអី! បក្សនិងបក្សនិយាយគ្នា។ ចប់ប៉ុណ្ណឹងទៅ។

**ស៖** បើតាមលោក តើកិច្ចព្រមព្រៀងនេះជាកិច្ចព្រមព្រៀងឈប់បាញ់ បទឈប់បាញ់ តើមានផលវិបាកដើម្បីបង្កើនសង្គ្រាមនៅប្រទេសកម្ពុជាដែរឬទេ?

**ឆៈ** តាមខ្ញុំយល់ ជារឿងរាល់ហូរហែមកវាមានឥទ្ធិពលខ្លះដែរ ព្រោះពីដើមវៀតណាមអាស្រ័យនៅប្រទេសវៀតណាមនោះទេ ដល់មានកិច្ចព្រមព្រៀងសន្តិភាពវៀតណាមនេះ ត្រៀមរៀបចំដូចជាបោះឆ្នោតអីចេះមិនដឹង ហូរចូលមកក្នុងប្រទេសកម្ពុជារាប់ម៉ឺនរាប់សែន ធ្វើឲ្យប្រជាជនកម្ពុជាមានការមិនសប្បាយចិត្ត ហើយថែមទាំងគាបសង្កត់ឲ្យបក្សកុម្មុយនីស្តកម្ពុជានេះ ធ្វើកិច្ច-- រួមជាមួយវៀតណាម ធ្វើកិច្ចព្រមព្រៀងសន្តិភាពផង។

[១០:០៣:០៥]

ប៉ុល ពត សួរថាឲ្យខ្ញុំស៊ីញេកិច្ចព្រមព្រៀងសន្តិភាពជាមួយអ្នកណា? ឆ្លើយថា ធ្វើកិច្ចព្រមព្រៀងសន្តិភាពជាមួយ លន់ នល់។ ប៉ុល ពត ឆ្លើយថា ខ្ញុំមិនធ្វើកិច្ចព្រមព្រៀងសន្តិភាពជាមួយ លន់ នល់ ទេ បើអាមេរិកចង់ឈប់សង្គ្រាមជាមួយខ្មែរ *គីស៊ីងហ្គ័រ* មកស៊ីញេកិច្ចព្រមព្រៀងជាមួយកម្ពុជាប្រជាធិបតេយ្យទៅ។ នេះព្រឹត្តិការណ៍វាមានអ៊ីចឹង។ ដូច្នោះ ការទំនាក់ទំនងរវាងវៀតណាម និងកម្ពុជាមិនកក់ក្តៅទេ ហើយមិនជិតស្និទ្ធទេ។ ម្នាក់ៗ វៀតណាមរកតែស្មៀតធ្វើម៉េចបង្ខំឲ្យកម្ពុជានេះ ស៊ីញេកិច្ចព្រមព្រៀងជាមួយវៀតណាមផង។ ហើយផ្តាំមកថា ហើយអង្កាល់នោះ ឡេ ឌឹកថ ផ្តាំមកថា គីស៊ីងហ្គ័រផ្តាំមកបក្សកុម្មុយនីស្តកម្ពុជាថា បើអ្នកឯងមិនឈប់សង្គ្រាមទេ ខ្ញុំនឹងកម្ទេចកម្ពុជាក្នុង៧៤ម៉ោង។ នេះសម្តី ប៉ុន្តែមិនដឹងជា គីស៊ីងហ្គ័រ និយាយមែន ឬក៏វៀតណាមនិយាយក៏ខ្ញុំមិនដឹងដែរ។ ប៉ុន្តែវៀតណាមប្រាប់មកអ៊ីចឹង។

[១០:០៥:០០]

ហើយគេបំភ័យទៀត ថាមិនបានទេ លន់ នល់ អាមេរិកសព្វថ្ងៃណា វាមានអាវុធវាទាន់សម័យខ្លាំងណាស់ បេ៥២ គ្រាន់តែផ្ទុះមើលស្ពាន ក្បាលប៊ូឡុងមួយក៏មើលឃើញដែរ ហើយមនុស្សបីបួននាក់ទៅជ្រកក្រោមដើមឈើ ចំហាយមនុស្សហ្នឹង ក៏វាធ្វើឲ្យ បេ៥២ ដឹងដែរ។ ដូច្នោះ មិត្តតស៊ូម្នាក់ឯងម៉េចបាន? ហើយក្នុងលោកនេះគ្មានអ្នកណាតស៊ូម្នាក់ឯងទេ យើងត្រូវពឹងពាក់គ្នា អាស្រ័យគ្នាទៅវិញទៅមក។ ប៉ុល ពត ឆ្លើយថា ខ្ញុំគោរពនូវមិត្តភាពរវាងខ្មែរនិងវៀតណាម ក៏ប៉ុន្តែសព្វថ្ងៃនេះ កម្លាំងរបស់ លន់ នល់ វាទន់ខ្សោយណាស់ទៅហើយ។ ខ្ញុំត្រូវតែបន្តសង្គ្រាមតទៅទៀត។ បើខ្ញុំចុះកិច្ចព្រមព្រៀងសន្តិភាពដូចវៀតណាម ការតស៊ូរបស់ខ្ញុំមុខជារលាយហើយ។ បានសេចក្តីថា ប៉ុល ពត ចង់និយាយថាវៀតណាមមុខតែគ្រប់គ្រងកម្ពុជាហើយ ប៉ុន្តែ ប៉ុល ពត គាត់មិននិយាយ។ គាត់ថាប៉ុណ្ណឹង។ នេះខ្ញុំសូមជម្រាបឲ្យអស់។ តាមខ្ញុំនៅចាំខ្លះ សេចក្តីប៉ុណ្ណឹង។ នេះហើយឥទ្ធិពលអាក្រក់ ឬល្អ វាមាន ដូច្នេះឯង។

លោកប្រធាន ខ្ញុំហត់ហើយ។

[១០:០៧:២៦]

**លោក សុន អរុណ៖**

កូនក្ដីបានប្រាប់ខ្ញុំថា គាត់ហត់ ហើយនិយាយតទៅទៀតស្ដាប់មិនសូវបានសំណួរ ហើយនិយាយទៅទៀតក្រែងលោខុស។ សូមសម្រាក។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំនៅសល់តែពីរសំណួរផ្សេងទៀតទេ។ តើលោកអាចឆ្លើយនឹងសំណួរពីរទៀតបានទេលោក នួន ជា?

**លោក នួន ជា៖**

ខ្ញុំសូមអនុញ្ញាតទៅបន្ទប់ទឹក។

[១០:០៨:០៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកនួន ជា! ហើយអនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅបន្ទប់ទឹក!

បាទ, ឥឡូវនេះពេលវេលាសមល្មមនឹងសម្រាកហើយដែរ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

*(សវនាការសម្រាកពីម៉ោង ១០:០៩ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:១០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សូមប្រគល់វេទិកាទៅលោក ហ្សង់ម៉ាក ដើម្បីបន្តតាំងសំណួរចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក នួន ជា ក្នុងអំឡុងឆ្នាំ៧៣ សម្ដេច នរោត្ដម សីហនុ គឺថា ហាក់ដូចជាបានមកទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយគាត់បានយាងទៅភ្នំគូលែន។ តើលោក នួន ជា អាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេថា តើអ្នកណាសម្រេចអំពីទស្សនកិច្ចនេះ? តើមានមូលហេតុអ្វីខ្លះ? ហើយដំណើរទស្សនកិច្ចនេះប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ?

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមគោរពលោកចៅក្រម! ឆ្នាំ១៩៧៣ ដែលព្រះករុណា កាលនោះនៅប៉េកាំង លោកមានព្រះរាជបំណងចង់មកធ្វើទស្សនកិច្ចសួរសុខទុក្ខកូនចៅព្រះអង្គនៅក្នុងប្រទេស។ ដូច្នោះបានស្នើបានទាក់ទងតាមរយៈចិន ឲ្យទាក់ទងមកបក្សកុម្មុយនីស្ដកម្ពុជា។ បក្សកុម្មុយនីស្ដកម្ពុជារីករាយ យល់ស្របទទួលព្រះរាជដំណើរយាងមកទស្សនកិច្ចរបស់ព្រះអង្គ។ តែពេលនោះ វៀតណាម គេជំទាស់គេថាបើព្រះអង្គយាងទៅ ត្រូវតាមទៅកាន់តាមផ្លូវហូជីមិញ បានទៅដល់ប្រទេសកម្ពុជា។ ឯផ្លូវហូជីមិញ នេះ គេរក្សាការសម្ងាត់ មិនឲ្យអ្នកណាឆ្លងកាត់ទេ ក្រៅពីវៀតណាម និងកងទ័ពវៀតណាម។

[១០:៣៥:៣៩]

ដូច្នោះ ព្រះអង្គក៏បានទាក់ទងខាងវៀតណាម ធ្វើដំណើរមកតាមផ្លូវហូជីមិញ ហើយវៀត-ណាមនេះ គេមិនឲ្យកម្មាភិបាលចិនជូនមកទេ គេឲ្យឧត្ដមសេនីយ៍វៀតណាមម្នាក់ ហើយនិងកងទ័ពមួយចំនួន ធ្វើដំណើរជូនព្រះអង្គពីហាណូយកាត់តាមផ្លូវហូជីមិញ មកតាមឡានតូច មកដល់ស្ទឹងត្រែង។ មកដល់ស្ទឹងត្រែង គណបក្សកុម្មុយនីស្ដកម្ពុជា ដែលមានលេខា ប៉ុល ពត ជាលេខាទទួលខុសត្រូវទាំងស្រុង នូវសន្តិសុខរបស់ព្រះអង្គ។ ហេតុដូច្នោះ បានជារៀបចំកងទ័ពដែលមានមួយចំនួនចាំរក្សានៅសុខសន្តិភាពរបស់ព្រះអង្គ។ ពេលនោះ យន្តហោះអាមេរិក កំពុងទម្លាក់គ្រាប់បែកយ៉ាងខ្លាំងក្នុងឆ្នាំ១៩៧៣ តាំងពីអាអេហ្វ-- គេហៅថាអាអេហ្វ៥ (F-5) *ហ្វុងតូម,* បេ៥២ ហើយកងកប៉ាល់ហោះស៊ើបការណ៍ ហោះទៅ ហោះមកត្រួតតាមទន្លេមេគង្គ ប៉ុន្តែទោះបីយ៉ាងនេះហើយក៏ដោយ ក៏បក្សកុម្មុយនីស្ដកម្ពុជាត្រៀមរៀបចំសព្វគ្រប់ដើម្បីរក្សានូវសន្តិសុខថ្វាយព្រះអង្គពេញទី។ ដល់ដូច្នោះ ពេលព្រះអង្គយាងមកដល់ស្ទឹងត្រែង ព្រះអង្គឆ្លងទន្លេមេគង្គ ឡើងមកខាងក្រចេះ។

[១០:៣៨:៥០]

មកដល់នេះ មកដល់កំពង់ ដូចតាមខ្ញុំចាំ ធ្វើដំណើរមកដល់កំពង់ធំ ៗក៏ព្រះអង្គសម្រាកនៅឃុំមួយ គេហៅថា បឹងព្រហ្ម អំ បឹងគ្រុំ នៅក្នុងស្រុករវៀង-- នៅៗខេត្តព្រះវិហារ។ ព្រះអង្គសម្រាកនៅនោះបន្តិច ប៉ុល ពត បានចាត់ឲ្យខ្ញុំ នួន ជា នេះ រៀបចំផ្លូវពីកំពង់គ្រុំ ទៅដល់ប្រាសាទព្រះវិហារ-- អំ ទៅសៀមរាប ប្រាសាទអង្គរ។ ហើយនៅលើភ្នំប្រាសាទអង្គរនេះ បានធ្វើព្រះរាជដំណាក់មួយយ៉ាងល្អទុកថ្វាយព្រះអង្គ និងកាលនោះហៅអ្នកម្នាង និងអ្នកម្នាង។ ពេលនោះគ្រោះថ្នាក់ច្រើនណាស់ កប៉ាល់ហោះ ហោះចុះហោះឡើងៗ។ ក៏ប៉ុន្តែរក្សាសន្តិសុខថ្វាយព្រះអង្គរហូតដល់ព្រះអង្គធ្វើដំណើរបានសុខសន្តិភាពរហូតទៅដល់សៀមរាប ហើយយាងទៅសំណាក់នៅលើព្រះរាជដំណាក់លើភ្នំមួយ ព្រះអង្គសរសើរថា អ្ហេ! ព្រះរាជដំណាក់នេះល្អណាស់ តូច ស្អាត។ ដូច្នោះព្រះអង្គពេញព្រះទ័យ ហើយមិននឹកស្មានថា បក្សកុម្មុយនីស្តកម្ពុជាមានលទ្ធភាពរក្សាសន្តិសុខថ្វាយព្រះអង្គដល់ប៉ុណ្ណឹងទេ។ រួចហើយពេលនោះបាននិមន្តប្រជាជននៅខាងខេត្តព្រះវិហារ ហើយនិងហៅខេត្តជិតខាងច្រើន ទាំងព្រះសង្ឃទាំងប្រជាជនមកទទួលអបអរសាទរព្រះអង្គ ហើយមានធ្វើបុណ្យរំឭក ហើយព្រះអង្គសួរសុខទុក្ខកូនចៅព្រះអង្គអី សព្វគ្រប់អស់។ បានរយៈប្រហែលជាប្រាំមួយប្រាំពីរថ្ងៃដែរ ព្រះអង្គគង់នៅលើបានយាងទតមើលប្រាសាទអង្គរ។ ហើយព្រះអង្គក៏ទ្រង់សរសើរថា អ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាយកចិត្តទុកដាក់រក្សាសន្តិសុខរបស់ព្រះអង្គបានប៉ុណ្ណេះ ព្រះអង្គសូមអរគុណ។

[១០:៤២:៤៣]

រួចហើយក៏ធ្វើដំណើរជូនព្រះអង្គត្រឡប់ទៅវិញ។ ពេលធ្វើដំណើរជូនព្រះអង្គត្រឡប់ទៅវិញនេះក៏ទៅតាមផ្លូវហូជីមិញដែរ ហើយឆ្លងទន្លេមេគង្គ កប៉ាល់ទឹករបស់ខ្មាំងបើកឡើងបើកចុះ ក៏ប៉ុន្តែឆ្លៀតពេលចន្លោះបន្តិចបន្តួចនេះ ខំកាណូតព្រះអង្គឡើងដល់ច្រាំងទៅខាងស្ទឹងម្ខាងនោះទៅ។ ហើយក៏មានអ្នកជូនដំណើរកងទ័ពវៀតណាមនេះឯង គេទទួលភារកិច្ចជូនដំណើរព្រះអង្គទៅតាមផ្លូវហូជីមិញវិញ។ តើមូលហេតុអី ដែលវៀតណាមមិនឲ្យចិនទទួលភារកិច្ចធ្វើជូនដំណើរថ្វាយព្រះអង្គ? ពីព្រោះវៀតណាមដណ្តើមឥទ្ធិពលពីចិន មិនចង់ឲ្យចិននេះមានឥទ្ធិពលលើប្រទេសកម្ពុជា ហើយមិនឲ្យមានឥទ្ធិពលលើព្រះអង្គដែរ។ ដូច្នោះបានជាទោះបីយ៉ាងម៉េច វៀតណាមក៏គេដណ្តើមយកភារកិច្ចនេះជំនួសចិន។ ក៏ប៉ុន្តែបើតាមខ្ញុំសង្កេតមើលទៅព្រះករុណាក៏មិនសូវជាពេញព្រះទ័យដែរ ពីព្រោះគាត់បានទាក់ទងជាមួយចិនហើយៗវៀតណាមមកដណ្តើមធ្វើនាទីនេះ។ រឿងហ្នឹងមានតែប៉ុណ្ណឹង។ ព្រះអង្គត្រឡប់ទៅប្រទេស

វៀតណាម ទៅហាណូយ ហើយក៏ត្រឡប់ទៅប៉េកាំងដោយសុខសន្តិភាព ដើម្បីដំណើរការដឹកនាំតស៊ូតទៅទៀត។ នេះខ្ញុំសូមជម្រាបបន្តិចដំណើររបស់ព្រះអង្គយ៉ាងនេះ។

[១០:៤៥:១៥]

**ស៖** លោក នួន ជា តើលោកមាននៅចាំទេថា សម្តេច សីហនុ បានជួបនឹង ប៉ុល ពត នោះ? ឬក៏គាត់បានជួបនឹងសមាជិកបក្សអចិន្ត្រៃយ៍ណាខ្លះ?

**ឆ៖** ខ្ញុំសូមជម្រាបលោក ពេលនោះមានធ្វើការជប់លៀងថ្វាយព្រះអង្គ ប៉ុន្តែជួបអ្នកណាៗ ប៉ុន្តែជួប ប៉ុល ពត មុខជាជួបហើយ។ មាន ប៉ុល ពត, មាន សឺន សេន, មាន អៀង សារី ៗ ជូនដំណើរព្រះអង្គមកដែរ ហើយមានកម្មាភិបាលថ្នាក់ភាគមួយចំនួន។ ឯខ្ញុំមិនបានចូលរួមក្នុងពិធីជប់លៀង នោះទេ ដូច្នោះបានជាខ្ញុំដឹងមិនអស់ថា តើមានអ្នកណាខ្លះៗ ព្រោះខ្ញុំមានភារកិច្ចការពារព្រះអង្គពីកំពង់ត្រុំទៅសៀមរាបឯណោះទេ។

**ស៖** សូមអរគុណលោក នួន ជា។ ខ្ញុំចង់សួរសំណួរពាក់ព័ន្ធនឹងការប្រយុទ្ធគ្នាដែលបានប្រព្រឹត្តទៅនៅក្នុងចន្លោះឆ្នាំ៧០ និង ៧៥។ តើលោកអាចជម្រាបបានទេថា តើលោកដឹងពីការប្រព្រឹត្តទៅនៃប្រតិបត្តិការយោធា ហើយនិងលទ្ធផលនៃការប្រយុទ្ធគ្នានៅពេលនោះដែរទេ? តើលោកបានទទួលព័ត៌មានអីខ្លះពាក់ព័ន្ធទៅនឹងចំណុចនេះ?

[១០:៤៧:០៤]

**ឆ៖** ដូចខ្ញុំជម្រាបលោកប្រធាន ខ្ញុំមិនទទួលខាងយោធាទេ ខ្ញុំទទួលខាង-- ខ្ញុំទទួលខាងអប់រំ។ ក៏ប៉ុន្តែការប្រយុទ្ធគ្នាក៏ខ្ញុំដឹងខ្លះដែរ ក៏ប៉ុន្តែវាមិនបានច្បាស់ខ្លួនឯងទេ ពីព្រោះខ្ញុំមិនបានទៅប្រយុទ្ធផ្ទាល់ទេ មានតែកម្មាភិបាលយោធាទេ គេទៅប្រយុទ្ធ។

**ស៖** លោក នួន ជា តើលោកអាចនិយាយអំពីការប្រយុទ្ធគ្នាដែលបានប្រព្រឹត្តទៅនៅឧដុង្គដែរឬទេ? លោកអាចជម្រាបជូនអង្គតុលាការបានទេ? តើលោកបានដឹងអំពីអត្ថិភាពនៃការប្រយុទ្ធគ្នា ហើយតើមានអីកើតឡើងជាពិសេសទេនៅពេលនោះ?

**ឆ៖** ខ្ញុំមិនបានដឹងទេ។

**ស៖** លោកបាននិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ បើតាមលោកដឹង តើទីក្រុងផ្សេងទៀតដែលត្រូវបានវាយយកបាន ដណ្តើមយកបាននោះ តើគេត្រូវជម្លៀសប្រជាជនចេញដែរឬទេ?

**ឆ៖** បើតាមខ្ញុំដឹង នៅតាមទីក្រុងធំៗខ្លះគេជម្លៀស ប៉ុន្តែទីក្រុងខ្លះមិនជម្លៀសទេ ពីព្រោះយើងវានៅ-- ឧទាហរណ៍ ដូចជានៅក្រចេះអីៗនេះ ដូចមិនបានជម្លៀសទេ។ ពីព្រោះការជម្លៀសនេះ វានៅលើភារកិច្ចរបស់ខាងយោធា។ ឧបមាដូច ជម្លៀសទីក្រុងភ្នំពេញនេះ មានគណៈកម្មាធិការយោធា ឯខ្ញុំគ្រាន់តែទទួលខាងការអប់រំប៉ុណ្ណឹងទេ។ វាខុសគ្នា វាផ្សេងគ្នា ការងារផ្សេងគ្នា។ មួយការងារយោធារដ្ឋបាល ឯមួយទៀតការងារខាងសភា។ ឯសភាខាងខ្ញុំនេះ ខ្ញុំទទួលខាងអប់រំដាច់មុខ ហើយគ្មានកម្មាភិបាល គ្មានកងទ័ពអីទេ។

[១០:៥០:១២]

**សៈ** បើតាមលោកដឹង ហេតុអ្វីបានជាទីក្រុងផ្សេងៗទៀតមានគេជម្លៀសប្រជាជនដែរ?

**ឆ៖** នេះសម្រេចតែសភាពការណ៍របស់គណៈភាគគេ ពីព្រោះកាលណោះចែកជាភាគ តាមខ្ញុំចាំ។ មានភូមិភាគបូព៌ា ភូមិភាគនិរតី ភូមិពាយព្យ ភូមិភាគឧត្តរ ហើយក្រៅពីនេះក៏មានខាងភូមិភាគព្លិសាន។ ដូច្នោះការជម្លៀស ដូច្នោះសិទ្ធិអំណាចសម្រេចដោយខ្លួនឯង ម្ចាស់ការដោយខ្លួនឯងធ្លាក់ទៅលើគណៈកម្មាធិការភាគ គេសម្រេចតើត្រូវជម្លៀស ឬក៏មិនត្រូវជម្លៀស។

**សៈ** ដើម្បីឲ្យយល់ឲ្យច្បាស់នោះ បើតាមលោកគឺខាងគណៈភាគជាអ្នកសម្រេចដោយខ្លួនឯងផ្ទាល់ ដោយគ្មានទទួលការបញ្ជាពីខាងគណៈអចិន្ត្រៃយ៍ គឺខាងគណៈភាគ គឺគាត់សម្រេចដោយឯងតែម្តង ឬក៏ម៉េច? ហើយនៅពេលនោះតើមានប្រតិកម្មអីខ្លះពីខាងគណៈអចិន្ត្រៃយ៍?

**ឆ៖** ខាងគណៈភាគ គេមានសិទ្ធិចាត់ចែង ឯខាងណោះ គណៈអចិន្ត្រៃយ៍នៅឆ្ងាយ មិនមានប្រតិកម្មអីទេ គឺថាប្រគល់អំណាច ប្រគល់សិទ្ធិឲ្យទៅខាងគណៈភាគគេមើល។ តើកន្លែងណាមានដីស្រែល្អ ដែលអាចជម្លៀសប្រជាជនទៅធ្វើបាន ទៅធ្វើ។ ឯកន្លែងណាដែលសហករណ៍រឹងពឹងហើយសហករណ៍ចម្រើនគ្រាន់បើហើយ គេអាចជម្លៀសទៅកន្លែងនោះ។ ឯខាងគណៈអចិន្ត្រៃយ៍ក្តាប់មិនដល់ហ្នឹងទេ ក្តាប់គណៈភាគ សេចក្តីសម្រេចលើគណៈភាគ ឲ្យសិទ្ធិគណៈភាគ ពីព្រោះក្នុងសង្គ្រាមឈ្លបខ្ញុំសូមជម្រាបលោកដូចតទៅនេះ៖

អ្វីៗទាំងអស់ត្រូវសម្រេចឲ្យឆាប់ ឲ្យរហ័ស បើមិនអ៊ីចឹងទេខកឱកាសហើយ។ ឧបមាដូចខ្មាំងចូលមក មិនចាំបាច់សុំសេចក្តីអនុញ្ញាតពីគណៈមជ្ឈិមទេ ឬគណៈអចិន្ត្រៃយ៍ទេ។ គណៈភាគគេមានសិទ្ធិដើម្បីគេដោះស្រាយខ្លួនគេ ពីព្រោះបើមិនអ៊ីចឹងទេ វាខកឱកាស។

[១០:៥២:៤៨]

នេះជា-- តាមខ្ញុំដឹងខ្លះជាគោលការណ៍នៃសង្គ្រាមឈ្លប គឺវ៉ៃឆាប់ វ៉ៃរហ័ស ដករហ័ស ប្រមូលសម្ភារៈឲ្យរហ័ស ហើយគេចឲ្យរហ័ស។ មិនបាច់មកសុំសារាចរ សុំសេចក្ដីអនុម័តអីពីខាងលើទេ ម្ចាស់ការខ្លួនឯងទៅ។ ដូច្នោះបានជាពាក្យស្លោកនៅក្នុងមាគ៌ា គឺម្ចាស់ការឯករាជ្យ ខ្លួនឧបត្ថម្ភខ្លួន ខ្លួនសម្រេចវាសនាជាតិខ្លួន ដោយខ្លួនឯង។

[១០:៥៤:២២]

**ស៖** លោក នួន ជា តើយើងត្រូវយល់ថានៅក្នុងការផ្ទេរអំណាចដែលបានផ្ដល់ទៅឲ្យអ្នកទទួលខុសត្រូវគណៈភាគនោះ តើជាការចាត់ចែងរបស់គណៈអចិន្ត្រៃយ៍ថាទីក្រុងនីមួយៗ គឺថាអាចត្រូវតែមានកាជម្លៀសប្រជាជន តើអ៊ីចឹងមែនទេ? ឬមួយក៏ថា តើថាវាមានចែងរួចទៅហើយនៅក្នុងការផ្ទេរអំណាចរួចទៅហើយនោះ?

**ឆ៖** ដូចខ្ញុំបានជម្រាបហើយ បញ្ហានេះនៅក្នុងវិនិច្ឆ័យរបស់គណៈភូមិភាគ។

**ស៖** លោក នួន ជា ខ្ញុំបានយល់ច្បាស់ថាគឺគណៈភាគជាអ្នកសម្រេចអំពីការជម្លៀសនេះ ប៉ុន្តែលោកក៏បាននិយាយអំពីការផ្ទេរអំណាច គឺការផ្ទេរសមត្ថកិច្ចទៅដល់គណៈភាគ ថាតើអ្នកណាជាអ្នកផ្ទេរអំណាចទៅឲ្យគណៈភាគនេះ? ហើយថាតើការផ្ទេរអំណាចនេះអាចទៅដល់កម្រិតណាដែរ? តើវាមានការចែងមុនរួចហើយទេ ថាគណៈភាគនុំងមានសិទ្ធិក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង?

**ឆ៖** បញ្ហានេះ តាមខ្ញុំចាំគឺថាគណៈមជ្ឈិមបក្សជាអ្នកប្រជុំ ដើម្បីសម្រេច ឯគណៈអចិន្ត្រៃយ៍ជួយមតិវិភាគ ហើយជួយមតិបាន តែការសម្រេច សម្រេចលើគេ សម្រេចលើគណៈភាគ។

**ស៖** លោក នួន ជា លោកបាននិយាយអំពីលក្ខណៈវិនិច្ឆ័យដើម្បីសម្រេចអំពីការជម្លៀសប្រជាជន ហើយលោកក៏បាននិយាយផងដែរ អំពីលក្ខណៈវិនិច្ឆ័យមួយ ប្រសិនបើខ្ញុំយល់ច្បាស់នេះ គឺការធ្វើឲ្យដីមានជីជាតិ តើលោកអាចនិយាយពន្យល់ឲ្យបានច្បាស់បន្តិចទេ ថាលក្ខខណ្ឌក្នុងការធ្វើឲ្យដីមានជីជាតិនេះយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថា លក្ខណៈការធ្វើដីជីជាតិនេះ គឺប្រើជីធម្មជាតិ ដូចជា ទន្រ្ទានខែត្រ ស្លឹកឈើ ហើយដាច់ខាតមិនឲ្យប្រើជីជាតិគីមីទេ ឬក៏ប្រើលាមកសត្វ ដូចជា គោ ដូចជាក្របី ឬកម្ទេចកម្ទីស្មៅអីៗអស់នេះ ធ្វើជាឲ្យដីដែលខ្វះជីជាតិនេះ ទៅជាដីដែលមានជីជាតិ ពីព្រោះមានកន្លែងខ្លះប្រើជីជាតិៗ ធម្មជាតិនេះវាបានផលទ្វេមួយជាពីរជាងយើងមិនប្រើជីជាតិ។

[១០:៥៨:២៦]

**សៈ** ខ្ញុំយល់ឃើញច្បាស់ណាស់ពីការប្រើប្រាស់ដី ហើយនិងការជម្លៀសប្រជាជន ប៉ុន្តែខ្ញុំមានសំណួរមួយផ្សេងទៀត ថាតើគណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍អាចជំទាស់ទៅនឹងការជម្លៀសចេញពីទីក្រុងមួយចំនួនដែរឬទេ? ហើយតើវាមានការជំទាស់បែបនេះដែរឬទេ?

**ឆះ** តាមខ្ញុំដឹងដូចជាមិនដែលមានការជំទាស់អីទេ ពីព្រោះយើងបានប្រគល់ការខុសត្រូវភារកិច្ចនេះទៅឲ្យគណៈភាគហើយ គេទទួលខុសត្រូវចំពោះខ្លួនគេ។

**សៈ** សំណួរចុងក្រោយលោក នួន ជា តើលោកមានធ្លាប់និយាយអំពីបញ្ជីជនក្បត់ មហាជនក្បត់ទាំងប្រាំពីរនាក់ទេ? ថាតើអ្នកណាជាអ្នកបង្កើតបញ្ជីនេះ ហើយបង្កើតនៅពេលណា? ហើយតើសម្រាប់អ្នកណាដែរបញ្ជីហ្នឹង?

[១០:៥៩:៤៥]

**ឆះ** បញ្ហានេះ ខ្ញុំមិនដែលដឹងទេ គ្រាន់តែឮ ប៉ុន្តែឲ្យដឹងថាទៅចូលរួមសម្រេច ខ្ញុំមិនបានចូលរួមសម្រេចទេ ប៉ុន្តែឮប្រកាសតាមវិទ្យុ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ, សូមអរគុណលោក នួន ជា។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម ហ្សង់ម៉ាក ឡាវែន ហើយតើលោកចៅក្រមប្រឹក្សាមានសំណួរអីចង់សួរទៅលោក នួន ជា ទៀតទេ?

ប្រសិនបើមិនមានទេ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះជនជាប់ចោទ នួន ជា។ ប្រសិនបើមានសូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមរៀបចំឧបករណ៍នៅទីនេះ ដើម្បីសម្រួលបាទ។

**សៈ** សូមជម្រាបសួរលោក នួន ជា។ លោក នួន ជា លោកស្តាប់ខ្ញុំឮទេ? នៅក្នុងសេចក្តីថ្លែងការណ៍ដែលលោកបានធ្វើនៅពេលចាប់ផ្តើមសវនាការនេះ លោកបាននិយាយហើយនិយាយទៀតថាពួកវៀតណាម ហើយលោកបានលើកឡើងដែលថា ពួកគេត្រួតត្រាបក្សកុម្មុយនីស្តកម្ពុជា ហើយខ្ញុំសូមឲ្យលោកបំភ្លឺចំណុចមួយដែលខ្ញុំយល់ថា មានសារៈសំខាន់។ ខ្ញុំមិនយល់ឃើញថា លោកជាបុគ្គលដែល

ទទួលបញ្ជា ឬក៏ការណែនាំពីវៀតណាមនោះទេ ឬក៏បញ្ជាពីប្រទេសផ្សេងមកទេ។ ដូច្នេះ អ្វីដែលខ្ញុំចង់សួរលោកនៅក្នុងសម័យដែលលោកជាអនុលេខារបស់បក្សនោះ តើលោកអាចបញ្ជាក់ប្រាប់តុលាការបានទេ ថាតើលោកមិនមែនជាអាយ៉ងរបស់វៀតណាមនោះ?

[១១:០២:៤៣]

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញា។ បក្សកុម្មុយនីស្តឥណ្ឌូចិន មិនមែនកកើតឡើងដោយប្រជាជនកម្ពុជាទេ។ នេះខ្ញុំសូមជម្រាប។ បក្សកុម្មុយនីស្តឥណ្ឌូចិនកកើតឡើងដោយបក្សវៀតណាម គេចាត់តាំងឡើងពីឆ្នាំ១៩៣០ នេះតាមខ្ញុំចាំ។ ដល់ចាត់តាំងបានបក្សនេះ ពីឆ្នាំ១៩៣០ ហើយ ប្រជាជនខ្មែរ តាមខ្ញុំដឹងកាលនោះខ្ញុំនៅក្មេងទេ ប៉ុន្តែឮគេនិយាយតមកទៀតថា ប្រជាជនខ្មែរមិនចូលចិត្តវៀតណាមទេ ស្អប់វៀតណាមណាស់។ ដូច្នោះបក្សកុម្មុយនីស្តវៀតណាម ក៏មិនបានរីកចម្រើនអីទេ ប៉ុន្តែតមកក្រោយទៀត ខ្ញុំបាន-- កាលនោះរវាងឆ្នាំ-- ក្រោយកិច្ច ឆ្នាំ១៩៥០-- ខ្ញុំភ្លេច។ ហើយក្រោយមកឆ្នាំ១៩៥០ វៀតណាមនេះបានទាក់ទងជាមួយនឹងខ្មែរនៅកម្ពុជាក្រោមម្នាក់ គាត់បួសជាលោកសង្ឃ ឈ្មោះគាត់ដើម ឈ្មោះអាចារ្យមាន។ បួសនៅវត្ត ន៎ែពីដើមគេហៅវត្តថាញ់ ឬក៏វត្ត វត្តអីមិនដឹងទេ វត្តហ្នឹងជាវត្តវៀតណាម វត្តហ្នឹងកាត់ព្រះពុទ្ធសាសនា ប៉ុន្តែវៀតណាមដែលមកនៅស្រុកខ្មែរច្រើននិយមទៅវត្តនោះ។ ដូច្នោះបានទៅទាក់ទងនឹងអាចារ្យ មាន នេះ ដើម្បីរៀបចំកសាងជាអង្គការបដិវត្តន៍។ អានេះ ខទីពីរ។

[១១:០៥:៣៤]

ប៉ុន្តែហេតុដូចម្តេចបានជាអាចារ្យ មាន នេះផ្លាស់ឈ្មោះជា សឺង ង៉ុកមិញ ពីព្រោះកាលនោះក្រោយកិច្ចព្រមព្រៀងហ្សឺណែវ សឺង ង៉ុកមិញ នេះមានឥទ្ធិពលច្រើននៅក្នុងបញ្ញាជន នៅក្នុងអី នៅក្នុងអ្នករាជការ ហើយល្បីឈ្មោះជាអ្នកស្នេហាជាតិ ប្រឆាំងនឹងស្តេច ប្រឆាំងនឹងបារាំង។ នេះ ដូច្នោះវៀតណាមនេះបានឲ្យអាចារ្យ-- បានផ្សឹក បានណែនាំអាចារ្យ មាន នេះឲ្យត្រឡប់ទៅតែនិញ កាលនោះស្រុកខ្មែរហៅរោងដំរី។ ហើយប្រែឈ្មោះ សឺង ង៉ុកមិញ នេះ អ៎!ប្រែឈ្មោះអាចារ្យ មាន នេះជា សឺង ង៉ុកមិញ។

ឯអ្នកដែលប្រែឈ្មោះជា សឺង ង៉ុកមិញ នេះ កាលនោះចាត់តាំងជាគណៈជាតិមុតគាហា មានបីរូប បួនរូប គឺ សឺង ង៉ុកមិញ ដែលឈ្មោះដើមអាចារ្យ មាន, ស៊ីវ ហេង, លោកតា ទូ សាមុត, និង

លោក ឡាំ ផៃ។ ឡាំ ផៃ នេះ ក៏ជាខ្មែរក្រោមដែរ ទាំងអស់សុទ្ធតែជាខ្មែរក្រោមនៅត្រាយឃិញ។

[១១:០៧:៤៦]

វៀតណាម ឃើញថា ហើយ ឡាំ ផៃ នេះណា នែគាត់ឈ្មោះ ខ្ញុំភ្លេចឈ្មោះហើយ។ ត្រូវជាប្អូនថ្លៃរបស់ សឺង ង៉ុកមិញ អ៊ំ សឺង ង៉ុកថាញ់។ ដល់វៀតណាម ឃើញដូច្នោះ ឲ្យ ឡាំ ផៃ នេះនែ ទៅទាក់ទងល្បួងយក សឺង ង៉ុកថាញ់ នេះមកចូលក្នុងគណៈកម្មាធិការ គណៈជាតិមុតគាហា។ គណៈជាតិមុតគាហា នេះប្រែថា គណៈកម្មាធិការរំដោះជាតិ។ ជិះដំរីទៅ កាលនោះ សឺង ង៉ុកថាញ់ ទៅនៅភ្នំដងរែក ប៉ុន្តែទៅមិនបាន ព្រោះខ្លាំងវាស្ទាក់ផ្លូវ។ ដូច្នោះត្រឡប់មកវិញៗនេះ បានរៀបចំចាត់តាំងជាបក្សកុម្មុយនីស្តឥណ្ឌូចិន នៅឆ្នាំ១៩៥១។ ដល់ឆ្នាំ១៩៥១ នេះ គឺឆ្នាំ១៩៥០ បែងចែកបក្សនេះ ជាបីបក្ស ពីព្រោះបើទុកជាឈ្មោះបក្សកុម្មុយនីស្តឥណ្ឌូចិន ចលនាប្រជាជនមិនបានទេ ប្រជាជនមិនចូលចិត្តទេ។

[១១:១០:០០]

ដូច្នោះចែកបក្សនេះ។ នេះជាយុទ្ធវិធីរបស់វៀតណាម ហើយវៀតណាម គេកាន់កាប់ទាំងអស់ ខ្ញុំសូមជម្រាបអ៊ីចេះ នៅអមជាមួយគណៈជាតិមុតគាហា គ្រប់ថ្នាក់តាំងពីមជ្ឈិមរហូតដល់ភូមិឃុំ គេហៅថា មានគណៈ ភាសាវៀតណាម គេហៅថា បានកានស៊ឹក គឺគណៈបក្សវៀតណាម នៅដឹកនាំបញ្ជាគណៈជាតិមុតគាហា។ ដូច្នោះគណៈជាតិមុតគាហានេះ វានៅក្រោមការដឹកនាំបញ្ជារបស់បក្សកុម្មុយនីស្តវៀតណាម ដែលមាន ង្វៀន ថាញ់សឺន ទទួលខុសត្រូវនៅវៀតណាមខាងត្បូង។ វៀតណាមនេះទទួលខុសត្រូវគ្រប់គ្រងថ្នាក់ជាតិមុតគាហាមជ្ឈិមរបស់ខ្មែរ ហើយចុះមកទៀតតាមភាគក៏មានបានកានស៊ឹក របស់គេដែរ មានគណៈវៀតណាម សុទ្ធតែវៀតណាមទាំងអស់។ ឯកងទ័ពពេលនោះក៏ដូចជាគ្នាដែរ កងទ័ពឈ្មោះជាកងទ័ពខ្មែរ ដូចជាកងទ័ពអាចារ្យ ជុំ កងទ័ពអាចារ្យ ជាវ កងទ័ពពោធិ៍កំបោរ កងទ័ពអាចារ្យ ស្វា ក៏ប៉ុន្តែមេបញ្ជាការរូបភាពជាខ្មែរ ក៏ប៉ុន្តែមេបញ្ជាការមែនទែននោះគឺវៀតណាមទេ ឯខ្មែរគ្រាន់តែបាំងមុខទេ គ្រាន់តែឈរឈ្មោះបាំងមុខប៉ុណ្ណឹងទេ។

[១១:១១:៥៩]

នេះខ្ញុំសូមជម្រាបដោយសង្ខេប។ ដូច្នោះវៀតណាមដឹកនាំរហូត រហូតដល់ក្រោយកិច្ចព្រមព្រៀងហ្សឺណែវហើយ ឆ្នាំ១៩៦១ ហើយនេះ បានបែកគ្នាខ្លះ។ ក៏ប៉ុន្តែវៀតណាមនៅតែបង្កប់ខ្លួននៅក្នុងប្រទេសកម្ពុជាដដែល ដើម្បីអី? ដូចជា ឡេ យន់ នេះ នែ៎ ឡេ យន់ នៅភ្នំពេញ នៅខាងត្បូងសាលារៀនយុគគន្ធរ ខ្ញុំស្គាល់ច្បាស់ ឡេយន់ ហ្នឹង ដឹកនាំនៅហ្នឹង។ ដូច្នោះនែ៎ ដែលហៅថា បក្សកុម្មុយនីស្តឥណ្ឌូចិន

ដែលថាចែកជាបក្សបីហ្នឹងហើយក៏ដោយ បក្សខ្មែរហ្នឹងដំបូងហៅថា "បក្សប្រជាជនបដិវត្តន៍កម្ពុជា" បក្សលាវហៅថា "បក្សប្រជាជនបដិវត្តន៍ឡាវ" ឯបក្សវៀតណាមគេប្រែឈ្មោះហៅថា "បក្សពលករវៀតណាម ឬបក្សឡាវដុង"។ ក៏ប៉ុន្តែប្រែតែឈ្មោះទេ ឯខ្លឹមសារអីវៀតណាម នៅតែដឹកនាំដដែល មិនមានប្រែប្រួលអីទេ។ នេះអស់មួយរយៈ។

[១១:១៣:៣៩]

ដល់ឆ្នាំ១៩៦០ វៀតណាមនេះចាប់ផ្ដើមតស៊ូអារុធ ដើម្បីរំដោះនៃវៀតណាមខាងត្បូង ក៏ប៉ុន្តែគ្មានកន្លែងនៅទេ ហើយមកពឹងពាក់នៅដីខ្មែរ អ្នកដឹកនាំវៀតណាមប៉ុន្មានហ្នឹងហើយមកនៅដីខ្មែរទាំងអស់ ដូចជា ង្វៀន វ៉ាន់លិញ, ហាយ សូ អីៗអស់នេះ សូម្បីតែ ឡេ យន់ ហ្នឹងឯងក៏ដោយ ក៏មកនៅដីខ្មែរដែរ។ ខ្ញុំឃើញច្បាស់ ខ្ញុំស្គាល់ ខ្ញុំឃើញតែម្ដង។ ដំណឹងនេះដែលបញ្ជាក់ឃើញថា បក្សវៀតណាម នេះពឹងផ្អែកលើមាគ៌ានយោបាយអព្យាក្រឹត្យរបស់ប្រទេសកម្ពុជា ដើម្បីធ្វើជាបង្អែកតស៊ូទៅរំដោះវៀតណាមខាងត្បូង។ នេះមួយរយៈអស់។ នេះខ្ញុំសូមប៉ុណ្ណឹងសិនចុះ។

**ស៖** លោក នួន ជា ខ្ញុំជូនឱកាសមួយទៅលោក ខ្ញុំមិនសួរលោកអំពីរយៈកាលតាំងពីឆ្នាំ១៩៣០, ៥០ ឬក៏៦០ទេ ខ្ញុំសួររយៈពេលក្រោយពីខែកញ្ញា ឆ្នាំ១៩៦០ ហើយលោកបានបង្កើតបក្សរបស់លោក ហើយលោកបង្កើតមាគ៌ារបស់ខ្លួនផ្ទាល់។ បន្ទាប់ពីពេលនោះមក នៅក្នុងឆ្នាំ១៩៦០ និងទសវត្សរ៍ឆ្នាំ៧០ លោកជាអនុលេខាបក្ស។ តើលោកជាអាយ៉ងរបស់វៀតណាមទេ ឬក៏លោកធ្វើសេចក្ដីសម្រេចដោយខ្លួនឯង?

[១១:១៦:០១]

**ឆ៖** កាលនោះមិនធ្វើជាអាយ៉ងរបស់វៀតណាមទេ។ ក៏ប៉ុន្តែមានកិច្ចការអី អាចមានការពិភាក្សាគ្នាខ្លះ។ ពីឆ្នាំ១៩៦០ រៀងរហូតមក បក្សកម្ពុជាមានមាគ៌ាយុទ្ធសាស្ត្រ មាគ៌ាយុទ្ធវិធីរបស់ឯងដាច់ពីវៀតណាម។ ព្រោះកាលនោះយល់ឃើញថា បើកាលណាយើងចង់ឯករាជ្យខ្លួនយើងៗត្រូវមានមាគ៌ាយុទ្ធសាស្ត្រ មាគ៌ាយុទ្ធវិធី ឯករាជ្យរបស់ខ្លួន ដូចជាខ្ញុំបានជម្រាបកាលពីថ្ងៃទីប៉ុន្មាន? ថ្ងៃទី៥ អំថ្ងៃទី៦។ មិនធ្វើអាយ៉ងវៀតណាមទេ។

[១១:១៧:២៣]

**ស៖** ថាតើត្រូវទេលោក នួន ជា ថានៅក្នុងសម័យកាលនោះ គឺចាប់ពីកញ្ញា ខែកញ្ញា ឆ្នាំ១៩៦០ មករហូតដែលលោកបានបង្កើតមាគ៌ាបក្សដោយខ្លួននោះ។ តើគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមរបស់

បក្សកុម្មុយនីស្តកម្ពុជាមិនមែនជាអាយ៉ងរបស់វៀតណាមនោះទេ ប៉ុន្តែបានធ្វើសេចក្តីសម្រេចទាំងឡាយដោយខ្លួនឯង តើយ៉ាងដូចម្តេចដែរ?

**ឆ៖** ទាំងអស់នេះ យើងធ្វើសេចក្តីសម្រេចដោយខ្លួនយើង។ វៀតណាមគ្មានសិទ្ធិ ប៉ុន្តែថាឲ្យគេពេញចិត្តគេមិនពេញចិត្តទេ។ គេបន្ទោស ដូចខ្ញុំបានជម្រាបហើយ គេបន្ទោសថា បក្សកុម្មុយនីស្តកម្ពុជានេះឆ្វេងនិយម។ តស៊ូដោយមានមាគ៌ាដែលមិនត្រឹមត្រូវតាមលទ្ធិម៉ាក្ស-លេនីន នេះតាមខ្ញុំចាំ។ ហើយគេបន្ទោសថា បក្សកុម្មុយនីស្តកម្ពុជានេះមិនបាន ធ្វើអ្វីមិនបានពិភាក្សាជាមួយបក្សវៀតណាម។ បានជាក្នុងបក្សកុម្មុយនីស្តកម្ពុជាឆ្លើយទៅវិញថា យើងមានឯករាជ្យ អធិបតេយ្យភាព បូរណភាពដែនដីរបស់យើង។ យើងធ្វើអីយើងធ្វើតាមសភាពការណ៍ជាក់ស្តែងរបស់ប្រទេសយើង ក៏ប៉ុន្តែបើមិត្តវៀតណាមកាលនោះយើង-- កាលនោះនៅហៅ "មិត្ត" នៅឡើយទេ។ បើមិត្តវៀតណាមមានមតិអីអាចជួយបានក៏ជួយៗមិនទេក៏ហីទៅ យើងធ្វើដោយខ្លួនយើង។ នេះខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញា។

**ស៖** នៅពេលដែលលោកនិយាយថា ខាងបក្សកុម្មុយនីស្តវៀតណាមនិយាយថា លោកជាឆ្វេងនិយមនោះ តើគេចង់និយាយដូចម្តេចដែរ? មានន័យដូចម្តេច?

[១១:២០:១៥]

**ឆ៖** ឆ្វេងនិយមនេះ គេចង់និយាយថា យើងតស៊ូដោយអាវុធ ដែលឱកាសវាមិនទាន់បើកឲ្យ។ វៀតណាមគេប្រាប់ថា ពួកមិត្តមិនបាច់តស៊ូអាវុធទេ ចាំកាលណាវៀតណាមរំដោះវៀតណាមខាងត្បូងបានហើយ វៀតណាមហ្នឹងយកកងទ័ពចូលវាយទីក្រុងភ្នំពេញតែ២៤ម៉ោងប៉ុណ្ណឹងទេ។ ដូច្នេះពួកមិត្តត្រៀមតែអ្នកនាំផ្លូវទៅបានហើយ។ ហើយ ប៉ុល ពត គាត់ឆ្លើយវិញថា អ្នកណាគេធ្វើ អ្នកនោះគេយកផលប្រយោជន៍។ ដូច្នេះបញ្ហានេះបក្សកុម្មុយនីស្តកម្ពុជាត្រូវខិតខំធ្វើខ្លួនឯង ហើយអប់រំផ្ទៃក្នុងខ្លួនឯងកុំឲ្យពឹងផ្អែកលើគេ។ ជាពិសេសកុំឲ្យពឹងផ្អែកលើបក្សវៀតណាម ពីព្រោះគេមានឧបាយកល គេមានស្នៀតច្រើនណាស់ ដើម្បីនឹងក្តោបក្តាប់យកបក្សកុម្មុយនីស្តកម្ពុជានេះនៅក្រោមការដឹកនាំរបស់គេ។ ដូច្នេះបានជាមានការទំនាស់គ្នារហូតដល់ជាមានការទំនាស់គ្នាអាវុធ។

អត់ទោស ខ្ញុំសូមទៅបង្គន់-- ទៅបន្ទប់ទឹក។

[១១:២២:១៥]

**ប្រធានអង្គជំនុំ៖**

បាទ, អនុញ្ញាត។ អនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅបន្ទប់ទឹក។

សហព្រះរាជអាជ្ញាសម្រាកសិនទៅ។

*(លោក នួន ជា ទៅបន្ទប់ទឹក)*

[១១:២៦:២៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិបន្តសំណួរ!

**លោក នួន ជា៖**

អម្បាញ់មិញខ្ញុំទៅបន្ទប់ទឹកមិនបានសុំអនុញ្ញាតលោកប្រធាន សុំអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

មិនអីទេ។

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិបន្តសំណួរ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ នៅពេលនេះខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារមួយទៅលោក នួន ជា។ ឯកសារនេះនៅក្នុងសំណុំរឿងគឺឯកសារ D366/7.1.140 បាទ បើសិនជា ហើយនិង៩ នៅខាងចុង។ ហើយប្រសិនបើខាងមន្ត្រីអាចបង្ហាញនៅលើអេក្រង់ ឬក៏បង្ហាញឯកសារជូនទៅលោក នួន ជា។

លោកបានឃើញឯកសារនេះហើយលោក នួន ជា ជាឯកសារកំណត់សរសេរផ្ទាល់ដៃ ដែលនិយាយថាការតស៊ូអតីតកាលរបស់កសិករកម្ពុជា ឆ្នាំ១៩៥៤ រហូតដល់ឆ្នាំ១៩៧០ នៅខាងក្រោមនៃទំព័រទីមួយ គឺគេបានបញ្ជាក់ពីគំនិតរបស់លោក ហើយគឺមានចំណុចប្រវត្តិសាស្ត្រដែលថាជាគំនិតដែលលោកបានផ្តល់ឲ្យទៅគេនោះ? តើលោកបានឃើញទេ?

**លោក ម៉ៃខល ផេសមិន៖**

សូមអភ័យទោស តើមេធាវីការពារអាចសុំឯកសារនេះបានដែរឬទេ?

**លោក ឌេល លីសាក់៖**

លោកមេធាវីការពារក្តី លោកមានលទ្ធភាពបើកសំណុំរឿងបាន។ ដូច្នេះ គឺថាលោកអាចមើលបាន។

**លោក ម៉ៃខល ផេសមិន៖**

ប៉ុន្តែឯកសារនេះមិនបានបង្ហាញលើអេក្រង់ទេ យើងមិនអាចមើលបាន។ តើឲ្យខ្ញុំមានអត្ថបទ

ហ្នឹងបានឬទេ?

**ប្រធានអង្គជំនុំ៖**

ខាងមន្ត្រីរដ្ឋបាលតុលាការបង្ហាញឯកសារលើអេក្រង់ទូរទស្សន៍នូវឯកសារ ដែលសហព្រះរាជអាជ្ញារងលើកយកមកពិភាក្សានេះ ដើម្បីឲ្យភាគី និងអង្គជំនុំជម្រះអាចមើលឃើញ។

[១១:២៩:៣៥]

**លោក ខេល លីសាក់៖**

សូមលោកប្រធាន យើងមិនមានចេតនាទៅដល់សំណួរជាក់លាក់ទេ ប៉ុន្តែខ្ញុំបង្ហាញឯកសារជាភាសាខ្មែរ ដើម្បីជូនលោក នួន ជា ហើយខ្ញុំមានERN ជាភាសាផ្សេងទៀត។ ប៉ុន្តែបើមេធាវីការពារគាត់ចង់បានហើយ គឺថាមានឯកសារហ្នឹងជាភាសាពីរទៀតនៅក្នុងលេខERN។ ប៉ុន្តែក្នុងគោលបំណង ដែលខ្ញុំបង្ហាញនៅលើអេក្រង់នេះគឺថា ដើម្បីតែលោក នួន ជា ដើម្បីឲ្យគាត់បានពិនិត្យ និងឆ្លើយសំណួរតែប៉ុណ្ណោះ។

លោកមេធាវីការពារ នៅក្នុងអត្ថបទភាសាអង់គ្លេស គឺ ERN 00716409 រហូតទៅដល់ 716430។

លោកប្រធាន ខ្ញុំសូមអនុញ្ញាត ហើយយើងខ្ញុំមាននៅលើអេក្រង់យើងខ្ញុំ ប្រសិនបើលោកប្រធានអាចដាក់បង្ហាញនៅក្នុងអេក្រង់នេះ ក៏សូមមេត្តាអញ្ជើញបាទ។

[១១:៣១:១៤]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សំណួរទីមួយរបស់ខ្ញុំជូនលោក នួន ជា ថាតើលោកស្គាល់ឯកសារនេះទេ? លោកនៅចាំតើនេះជាអក្សរផ្ទាល់ដៃរបស់លោក ឬក៏មន្ត្រីណាម្នាក់ អ្នកណាម្នាក់ដែលកត់ឯកសារនេះកាលពីសម័យនោះ?

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមអនុញ្ញាតលោកប្រធានជម្រាប ខ្ញុំមិនដែលឃើញឯកសារនេះទេ។ ហើយអក្សរដែលសរសេរនេះក៏មិនមែនអក្សរខ្ញុំដែរ។ អក្សរខ្ញុំមិនមែនសរសេរយ៉ាងនេះទេ អក្សរខ្ញុំសរសេរផ្សេង។ ឲ្យខ្ញុំសរសេរឲ្យមើលក៏បានដែរ។ នេះខ្ញុំមិនដែលឃើញទេឯកសារនេះ ទើបតែឃើញទេ។

**ស៖** សូមឲ្យលោកមើលនៅទំព័រទីមួយខាងក្រោម នៅក្នុងនោះសរសេរមានពាក្យថា នួន ជា។ ដូច្នេះ នៅត្រង់ទំព័រទីមួយផ្នែកខាងក្រោមហ្នឹង ជាអក្សរលោកដែរ ឬក៏មិនមែនទេ?

**ឆ៖** អក្សរខ្ញុំ? ខ្ញុំយល់ឃើញថាមិនមែនអក្សរខ្ញុំទេ។ ព្រោះខ្ញុំមិនដែលឃើញឯកសារនេះទេ។ ហើយអក្សរខ្ញុំមិនមែនស្អាតអីចេះទេ។

**ស៖** ថាតើលោកបានជាមួយនឹង ខាំនឿន ដែរឬទេ នៅខែឧសភា ឆ្នាំ១៩៩៨ ដែលនៅពេលនោះលោកបានផ្តល់ជូនឯកសារអំពីប្រវត្តិនៃចលនាតស៊ូពីឆ្នាំ១៩៥៤?

**ឆ៖** អត់ទោសខ្ញុំស្តាប់មិនច្បាស់។ ជួបអ្នកណា? សូមលោកបញ្ជាក់ តើខ្ញុំជួបអ្នកណា? សូមបញ្ជាក់ឈ្មោះអី?

**ស៖** ខ្ញុំសូមអភ័យទោស ដោយសារតែការប្រកបឈ្មោះរបស់ខ្ញុំមិនត្រឹមត្រូវ។ លោកស្គាល់លោកខាំ នឿន ដែរឬទេ? ហើយលោកបានជួបជាមួយនឹងគាត់នៅឆ្នាំ១៩៩៨ ដែរឬទេ? ហើយបានផ្តល់ជូននូវប្រវត្តិនៃចលនាតស៊ូចាប់ពីឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៧០?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនដែលជួប ហើយមិនដែលស្គាល់ឈ្មោះខាំ នឿន ហ្នឹងផង។ ហើយមិនដែលបានប្រគល់ឯកសារអីឲ្យអ្នកណាទេ។

**ស៖** ខ្ញុំបានឮពីសហសេវិករបស់ខ្ញុំថាឈ្មោះជាភាសាខ្មែរនោះ គឺអ្នកបកប្រែគាត់អានមិនបានត្រឹមត្រូវ។

[១១:៣៤:៤៦]

ដូច្នេះហើយ ខ្ញុំព្យាយាមអានឈ្មោះហ្នឹងម្តងទៀត។ ហើយខ្ញុំអាចអានប្រកបឈ្មោះនោះតែម្តង។ ឈ្មោះហ្នឹងប្រកបជាភាសាអង់គ្លេសថា K H E M N G U N ប្រកបថា ខឹម ងួន ថាតើលោកស្គាល់ឈ្មោះបុគ្គលរូបនេះដែរឬទេ? ហើយបានជួបជាមួយគាត់ក្នុងឆ្នាំ១៩៩៨ដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំសូមបញ្ជាក់ម្តងទៀត ថាខ្ញុំមិនដែលស្គាល់ ហើយមិនដែលជួបទេ។ តើអ្នកនោះធ្វើការអី សូមលោកបញ្ជាក់មកមើល? ហើយខ្ញុំជួបនៅឯណា? សូមបញ្ជាក់ឲ្យច្បាស់។

[១១:៣៦:០៩]

**ស៖** ខ្ញុំ-- យើងក៏មានឯកសារហ្នឹងផងដែរ ដែលឯកសារនេះគឺបានកំណត់បង្ហាញអត្តសញ្ញាណរបស់បុគ្គលនេះ។ ដូច្នេះ ខ្ញុំនឹងផ្តល់ជាភាសាខ្មែរដែលមាន ឯកសារ IS20.28 ហើយលោកនឹងឃើញឈ្មោះបុគ្គលនោះនៅលើឯកសារ IS20.28 នេះ ហើយខ្ញុំនឹងសួរម្តងទៀតថាតើលោកធ្លាប់ជួបបុគ្គលរូប

នោះដែរឬទេ?

**លោក ឌេល លីសាក់៖**

លោកប្រធានប្រសិនបើអនុញ្ញាត ឯកសារនេះគឺមាននៅក្នុងសំណុំរឿង គឺមានលេខឯកសារ IS20.28 លេខ ERN ជាភាសាខ្មែរដែលខ្ញុំសូមឱ្យបង្ហាញដល់ជនជាប់ចោទនោះ គឺ00078183 រហូតដល់ 78206។ សម្រាប់ប្រតិចារឹកឯកសារមួយនេះ គឺបានដកស្រង់យកទៅដាក់បញ្ចូននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយបានអានដោយក្រឡាបញ្ជី ហើយវាក៏បានយោងទៅលើឯកសារមុន ហើយឯកសារទាំងអស់នោះ បានដាក់មកនៅចំពោះមុខអង្គជំនុំជម្រះផងដែរ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមន្ត្រីតុលាការ!

បង្ហាញឯកសារអម្បាញ់មិញនេះលើអេក្រង់ទូរទស្សន៍ ដើម្បីឱ្យភាគី និងអង្គជំនុំជម្រះបានពិនិត្យ។

ចុចក្បាលមេក្រូសិនសឹមនិយាយ!

**លោក នួន ជា៖**

**ឆ៖** ហើយឯកសារនេះ តាមខ្ញុំចាំជាឯកសារដែលខ្ញុំនិយាយក្រៅផ្លូវការ មិនមែនជាឯកសារផ្លូវការទេ។ ឯ ខឹម ងួន នេះន៎ែ តាមខ្ញុំស្គាល់គឺជាមនុស្សដែលខាងន៎ែ លោកនាយក ហ៊ុន សែន បញ្ជូនឱ្យទៅធ្វើចារបុរសមានលេខ០៩ នេះតាមខ្ញុំដឹង។

[១១:៣៩:៣៧]

ខ្ញុំបាននិយាយមែន។ ខ្ញុំទទួលស្គាល់ ហើយខ្ញុំបានប្រាប់អំពីប្រវត្តិរបស់បក្សយ៉ាងម៉េចៗខ្លះ ដើម្បីឱ្យដឹង។ ប៉ុន្តែក្នុងឯកសារនេះខ្ញុំដូចជាមិនបាននិយាយផ្ទាល់ទេ។ ខ្ញុំដូចនិយាយតាមខ្សែអាត់ បានជាខ្ញុំសង្ស័យ ខ្ញុំមើលខ្ញុំសង្ស័យឯកសារនេះ ខ្ញុំមិនដែលហៅអ្នកណា “អា” មិនដែលហៅ អ្នកណា “មី” អីទេ ក៏ប៉ុន្តែឯកសារនេះ ខ្ញុំឃើញអ៊ីចឹង។ ខ្ញុំហៅ “អាហ៊ួ យន់” ណា អីណា គ្មានទេ។ នេះ ខ្ញុំទទួលស្គាល់ថាខ្ញុំបាននិយាយជាមួយ ខឹម ងួន មែន ប៉ុន្តែកាលបរិច្ឆេទខ្ញុំមិនចាំទេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកបានបញ្ជាក់ថា មានការពិភាក្សាជាមួយនឹងបុគ្គលនោះ តើពិតជាត្រឹមត្រូវទេ? ហើយមានការថតសំឡេងនៅពេលនោះ តើត្រឹមត្រូវដែរឬទេ?

[១១:៤០:៥៥]

**ធៈ** សូមជម្រាបលោកប្រធាន! មិនមានការពិភាក្សាអីទេ ហើយក៏មានថតខ្សែអាត់ដែរ ប៉ុន្តែមិនមានពិភាក្សាអីទេ ខ្ញុំគ្រាន់តែនិយាយ ខ្ញុំប្រាប់ថា ខ្ញុំនិយាយនេះ និយាយក្រៅផ្លូវការទេណា ហើយខ្ញុំម្នាក់ឯងខ្ញុំមិនអាចចាំអស់ទេ ពីព្រោះរឿងហ្នឹងវាយូរមកហើយ។ ប៉ុន្តែ និយាយគ្នានេះនិយាយបែបនិយាយគ្នាលេងផងទេ។

**សៈ** តើមាននរណាគេទៀត ក្រៅពីលោក ខឹម នួន មានវត្តមាននៅពេលនោះដែរឬទេ?

**ធៈ** តាមខ្ញុំចាំគ្មានទេ មានតែខ្ញុំ ហើយនិង ខឹម ងួន។ មិនមែន ខឹម នួន ទេ ខឹម ងួន។

**សៈ** ខ្ញុំសូមអភ័យទោសចំពោះការអានឈ្មោះ។ ថាតើលោកមានភាពអព្យាក្រឹតដែរឬទេ នៅពេលដែលលោកនិយាយជាមួយបុគ្គលនោះ? ហើយលោកមានភាពស្មោះត្រង់ដែរឬទេ?

**ធៈ** ពេលនោះ តាមខ្ញុំចាំ ខ្ញុំនិយាយស្មោះត្រង់ ខ្ញុំអត់លាក់លៀមអីទេ។ គុណសម្បត្តិរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ខ្ញុំនិយាយ គុណវិបត្តិការខ្វះខាតក៏ខ្ញុំនិយាយ។ ខឹម ងួន នេះ ធ្វើការនៅជាមួយតាម៉ុក។

[១១:៤២:៥៨]

**សៈ** សូមអរគុណលោក នួន ជា ខ្ញុំនឹងត្រឡប់ទៅឯកសារដំបូងវិញ នៅពេលដែលខ្ញុំដេញដោលសួរសំណួរទៅកាន់លោក។ នៅពេលនេះ ខ្ញុំសួរសំណួរជាលក្ខណៈទូទៅវិញ អំពីការសម្ភាសន៍ដែលលោកនិយាយប្រាប់គេកាលពីអតីតកាល។ ប្រាប់ទស្សនាវដ្តី ដែលនៅពេលនោះលោកនិយាយអំពីប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងឆ្នាំ១៩៩៨ ទៅដល់ឆ្នាំ២០០០ ថាតើលោកតែងតែនិយាយជាមួយនឹងអ្នកកាសែតដែលមកសម្ភាសលោកដែរឬទេ?

**ធៈ** ខ្ញុំមិនចាំ។ មិនដឹងជាអ្នកណាខ្លះៗខ្ញុំមិនចាំទេ ប៉ុន្តែអ្នកទៅនិយាយ មិនដឹងថាអ្នកនោះជាអ្នកកាសែត ឬមិនកាសែតទេ។ គេទៅសួរពីនេះពីនោះ ហើយខ្ញុំនិយាយតាមដែលខ្ញុំចាំ ហើយខ្ញុំនិយាយដោយត្រង់។

**សៈ** ខ្ញុំនឹងអានឈ្មោះបុគ្គលមួយចំនួន ហើយសួរលោកថា លោកចាំឈ្មោះបុគ្គលទាំងអស់នោះដែរឬទេ? នូ សារ៉ាត់ ជាអ្នកកាសែតមកពីប្រទេសថៃដែលទៅសម្ភាសជាមួយលោកនៅក្នុងខែកញ្ញា ឆ្នាំ២០០១ តើលោកចាំថា បានជួបជាមួយបុគ្គលនោះដែរឬទេ?

[១១:៤៤:៣៨]

**ធៈ** ខ្ញុំមិនចាំទេ។

**សៈ** លោកចាំលោក អៀ ម៉េងទ្រី ដែលបានទៅជួបលោកក្នុងខែមិថុនា ឆ្នាំ២០០៦ ដែរឬទេ?

**ឆៈ** ខ្ញុំមិនចាំទេ ពីព្រោះខ្ញុំមិនចាំឈ្មោះមិនចាំអីទេ។

**សៈ** លោកចាំអ្នកកាសែតជប៉ុន ដែលមកសម្ភាសលោកនៅខែតុលា ឆ្នាំ២០០៦ ដែរឬទេ?

**ឆៈ** ខ្ញុំមិនចាំដែរ។

**សៈ** ចុះលោក លោក ថេត សម្បត្តិ តើលោកចាំថាបាននិយាយជាមួយគាត់ដែរឬទេ?

**ឆៈ** ថេត សម្បត្តិ ខ្ញុំស្គាល់ ខ្ញុំចាំ។ ព្រោះ ថេត សម្បត្តិ នេះ ខំទាក់ទងជាមួយខ្ញុំប្រហែលដប់ឆ្នាំ បានខ្ញុំទុកចិត្តខ្លះ។ ស្គាល់រហូតដល់ឥឡូវនេះ ប៉ុន្តែកាលដែលទៅជួបខ្ញុំ ប្រាប់ខ្ញុំថាយកទៅធ្វើជាឯកសារទុកសម្រាប់គ្រួសារអ៊ំ។ ខ្ញុំមិនបានចាប់អារម្មណ៍ គេថា គេយកឯកសារនេះទៅផ្សាយ ឬទៅធ្វើជាកុនទៅអី ខ្ញុំមិនបានចាប់អារម្មណ៍ទេ ពីព្រោះគេកុហក គេកុហកមិនកុហកមិនដឹងទេ។ ប៉ុន្តែថា គេប្រាប់ថាធ្វើឯកសារនេះទុកសម្រាប់ប្រចាំគ្រួសារអ៊ំ។ ខ្ញុំក៏និយាយប្រាប់ត្រង់ទៅ។ ខ្ញុំស្គាល់ ថេត សម្បត្តិ។

[១១:៤៦:៥៣]

**សៈ** លោកបានដឹងថា លោកត្រូវបានគេថតខ្សែវីដេអូនៅពេលដែលលោកនិយាយជាមួយនឹងលោក ថេត សម្បត្តិ តើលោកពិតជាដូច្នោះដែរឬទេ?

**ឆៈ** ខ្ញុំដូចជាមិនបានឃើញទេ សួរមាត់ទទេ ប៉ុនគេលាក់អាខ្សែនៅឯណា១ ខ្ញុំមិនដឹងដែរ។

**សៈ** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ តើនៅពេលនោះលោកមិនបានឃើញគេដាក់ម៉ាស៊ីនថត កាមេរ៉ាថតលោក នៅពេលដែលលោកត្រូវបានលោក ថេត សម្បត្តិ សម្ភាសន៍នោះទេ ឬក៏យ៉ាងម៉េច?

**ឆៈ** ខ្ញុំមិនបានចាប់អារម្មណ៍ទេ។

**សៈ** ហើយលោកនិយាយថា លោកនិយាយដោយស្មោះត្រង់នៅពេលដែលលោកធ្វើការផ្តល់ការសម្ភាសជាមួយនឹងលោក ថេត សម្បត្តិ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ត្រឹមត្រូវ។

[១១:៤៨:១០]

**សៈ** វាពិតដែរឬទេ ថាក្រោយពេលដែលគេតុលាការចាប់ខ្លួនលោក ហើយឃុំខ្លួននៅក្នុងនេះ ហើយលោកចាត់ទុកលោក ថេត សម្បត្តិ ថាជាបងប្អូនសាច់ញាតិដើម្បីឲ្យគាត់ហ្នឹងអាចចូលមកជួបលោក ហើយបន្តធ្វើការសម្ភាសន៍លោកទៀត តើពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** ប្រពន្ធ អាចសាច់ញាតិខ្ញុំខ្លះ ប៉ុន្តែឆ្ងាយ ប៉ុន្តែ ថេត សម្បត្តិ ហ្នឹងមិនមែនសាច់ញាតិខ្ញុំទេ។ ពីព្រោះភូមិរបស់ប្រពន្ធ សម្បត្តិ នេះ នៅក្រោយភូមិខ្ញុំ។ សព្វថ្ងៃនេះក៏នៅរាប់អានគ្នាដែរ ប្រពន្ធខ្ញុំទៅមកអី គាត់ទៅនៅផ្ទះហ្នឹងដែរ។ ប៉ុន្តែ ថេត សម្បត្តិ នេះ ខ្ញុំមិនដែលស្គាល់ទេ ប្រពន្ធក៏ខ្ញុំមិនដែលស្គាល់ ប៉ុន្តែរៀបរាប់ទៅថាត្រូវជាបែបជាត្រូវជាបងប្អូនខ្ញុំខ្លះដែរ ពីព្រោះនៅច្រាបក្រសាំង១ ភូមិច្រាបក្រសាំងនេះវានៅក្រោយភូមិវត្តគរ។ ខ្ញុំមានបងប្អូននៅច្រាបក្រសាំងដែរ។

**ស៖** ខ្ញុំយល់ថា លោក និង ថេត សម្បត្តិ មិនមានចំណងសាច់ញាតិនោះទេ ក៏ប៉ុន្តែខ្ញុំចង់សួរថា តើលោកបានចុះនៅក្នុងបញ្ជីតុលាការថាលោក ថេត សម្បត្តិ នេះជាសាច់ញាតិ ដើម្បីឲ្យគាត់ហ្នឹងអាចមកចូលជួបលោកនៅក្នុងមន្ទីរឃុំឃាំងដើម្បីសម្ភាសន៍លោក តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ខ្ញុំមិនបានចាំទេ។

[១១:៥0:00]

**ស៖** តើលោកចាត់ទុកលោកនុំង គឺជាមិត្តរបស់លោកដែរឬទេ?

**ឆ៖** ខ្ញុំមិនចាត់ទុកជាមិត្តទេ ប៉ុន្តែគ្រាន់តែអ្នកស្គាល់រាប់អានគ្នាធម្មតា។

**ស៖** តើលោកបានយល់ចំពោះលោក ថេត សម្បត្តិ ដែរឬទេ ដែលថានៅពេលណាដែលគាត់បានមកធ្វើការងារជាមួយនឹងលោក?

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមស្កាត់សំណួរនេះ ខ្ញុំគិតថាសំណួរនេះ គឺមិនមានការពាក់ព័ន្ធទៅនឹងការជំនុំជម្រះផ្នែកទីមួយនោះទេ។ ផ្នែកទីមួយ គឺពាក់ព័ន្ធទៅនឹងប្រវត្តិបក្សនៅចន្លោះឆ្នាំ១៩៧៥ ប៉ុណ្ណោះ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ភាពពាក់ព័ន្ធនៅក្នុងសៀវភៅដែលចេញផ្សាយដោយលោក ថេត សម្បត្តិ នោះ គឺវាផ្អែកទៅលើកិច្ចសម្ភាសន៍ជាមួយនឹង នួន ជា ដែលក្នុងនោះ លើកឡើងអំពីប្រវត្តិនៅមុនឆ្នាំ១៩៧៥។ ដូច្នេះហើយវាជាកិច្ចសម្ភាសន៍ដែលវាពាក់ព័ន្ធនៅក្នុងការសម្ភាសន៍ជាមួយនឹងជនជាប់ចោទ ហើយវាពាក់ព័ន្ធនៅក្នុងកិច្ចដំណើរនីតិវិធីផ្នែកទីមួយនេះ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំដឹងមិនថា សហព្រះរាជអាជ្ញាលើកឡើងយោងទៅលើសៀវភៅមួយណាទេ ហើយមិនដឹងថាសៀវភៅហ្នឹង មាននៅក្នុងសំណុំរឿងឬក៏អត់ទៀត?

**លោក ខេល លីសាក់៖**

សៀវភៅនេះ ទើបតែរកឃើញថ្មីៗតែប៉ុណ្ណោះ ហើយយើងក៏បានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះកាលពីសប្ដាហ៍មុន ឬក៏សប្ដាហ៍ទៅមួយទៀត។ ខ្ញុំក៏ឃើញថា មានដាក់ផ្សាយនៅក្នុងសំណុំរឿងផងដែរ។ ខ្ញុំនឹងផ្ដល់ឯកសារ លេខយោងឯកសារនេះ នៅពេលក្រោយ។ ហើយក៏ខ្ញុំអាចឲ្យលោកហ្នឹងសួរបញ្ជាក់ខ្ញុំទៅលើសៀវភៅនេះ ក្នុងពេលឈប់សម្រាក ដើម្បីឲ្យទុកពេលនេះ ឲ្យខ្ញុំសួរទៅលើជនជាប់ចោទបន្តទៀត។ សូមអរគុណ។

[១១:៥២:១៦]

**លោក សុន អរុណ៖**

បើតាមខ្ញុំយល់ ខ្ញុំជាមេធាវីលោក នួន ជា។ លោក ថេត សម្បត្តិ តុលាការបានស្នើសុំឲ្យលោក ថេត សម្បត្តិ ផ្ញើហ្វីម ដែលក្នុងកុន ដែល ថេត សម្បត្តិ បញ្ចាំងនៅគ្រប់ប្រទេសហ្នឹង ប៉ុន្តែ ថេត សម្បត្តិ មិនអនុញ្ញាតឲ្យតុលាការយកមកប្រើទេ។ ហ្នឹងហ្វីមកុន ដល់ ថេត សម្បត្តិ ចេញសៀវភៅទៀត ក៏មិនបានអនុញ្ញាតឲ្យតុលាការ ព្រះរាជអាជ្ញាយកមកដើម្បីចោទកូនក្ដីខ្ញុំដែរ។ ហើយឥឡូវ ខ្ញុំសូមបដិសេធការចោទប្រកាន់របស់លោកព្រះរាជអាជ្ញា ដែលលោកព្រះរាជអាជ្ញាយកមកនិយាយពេលនេះ ដែលខ្ញុំមិនបានដឹង។ សូមអរគុណ។

[១១:៥៣:០៣]

**លោក អាកទ្វូរ វែកគែន៖**

លោកប្រធាន ខ្ញុំគិតថាដើម្បីឲ្យយល់គ្នាទៅវិញទៅមក-- អ្វីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានោះ គឺថាយើងត្រូវតែឲ្យគាត់បញ្ជាក់ពីសំណុំឯកសារ ដែលគាត់និយាយនោះ គាត់និយាយថា មានការដាក់ឯកសារចូលទៅក្នុងសំណុំរឿងនោះ ខ្ញុំចង់ដឹងថាតើឯកសារណាដែលដាក់បញ្ចូលទៅក្នុងសំណុំឯកសារនោះ?

[១១:៥៣:២៥]

អ៊ីចឹង សូមបញ្ជាក់ គឺថាឯកសារដែលភ្ជាប់ទៅនឹងដីកាដំណោះស្រាយ ឬក៏ជាភស្តុតាងដែលដាក់ចូលនៅក្នុងសំណុំរឿងស៊ើបអង្កេត។ តើព្រះរាជអាជ្ញាហ្នឹង ចង់និយាយអំពីអ្វី? អ៊ីចឹង ខ្ញុំគិតថា ជាការសំខាន់ណាស់ដើម្បីបំភ្លឺទៅដល់អង្គសវនាការ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាអាជ្ញា ឡើងបញ្ជាក់អំពីអត្តសញ្ញាណឯកសារដែលជាសៀវភៅ ដែលលោកមានបំណងនិយាយយោងទៅដល់សៀវភៅនិពន្ធរបស់លោក ទេព សម្បត្តិ (ស៊ីក) ដែលលោកគិតថាជាមូលដ្ឋាននៃភស្តុតាងពាក់ព័ន្ធជាមួយនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។

**លោក ឌេល លីសាក់៖**

ខ្ញុំរីករាយក្នុងការផ្តល់ឯកសារយោងនេះ ដើម្បីឲ្យច្បាស់លាស់ទាំងអស់គ្នា។ នៅពេលនេះ ខ្ញុំមិនមានបំណងសួរសំណួរពាក់ព័ន្ធនឹងសៀវភៅនេះទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែសួរអំពីភាពពាក់ព័ន្ធទៅនឹងសៀវភៅនេះ ដែលជាមូលដ្ឋានក្នុងការដេញដោលសំណួររបស់ខ្ញុំ។

[១១:៥៤:៤០]

ខ្ញុំមានការភ្ញាក់ផ្អើល ដែលថា សៀវភៅនេះត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងរួចទៅហើយ ហើយ មេធាវីការពារក្តីមិនបានដឹង មិនបានតាមដាន ថាសៀវភៅនោះ បានដាក់បញ្ចូលទៅក្នុងសំណុំរឿង លេខERN នៃឯកសារនេះ គឺ00757471 ដល់ 568។ ចំពោះលេខ ERN ផ្សេងទៀត ខ្ញុំនឹងផ្តល់ជូននៅពេលក្រោយ សៀវភៅនេះគឺដាក់សរសេរដោយលោក ថេត សម្បត្តិ ដែលមានចំណង ថា "នៅខាងក្រោយវាលពិឃាដ" គឺមានលេខ E152.2.2។

**លោក អាកឡូវ វែកគែន៖**

--របស់យើងអំពីការងារយើងជាមេធាវីនេះ។ ខ្ញុំយល់ឃើញថា ការកត់សម្គាល់របស់គាត់ គាត់និយាយអំពីសំណុំរឿង ដែលថាមានការដាក់បញ្ចូលក្នុងឯកសារហ្នឹង គ្រាន់ថាគាត់ធ្វើយ៉ាងណាឲ្យប្រាប់មកយើងថា គាត់ហ្នឹងបានបញ្ជូនសៀវភៅហ្នឹងមួយច្បាប់ ព្រោះថាពេលគេនិយាយពីសំណុំរឿងនោះវាមិនដូចដែលថា ការបញ្ជូនភស្តុតាងទៅឲ្យភាគីនោះទេ។ នៅពេលដែលគេនិយាយអំពីការដាក់ភស្តុតាងដែលថានឹងទទួលស្គាល់ដោយអង្គជំនុំជម្រះនោះ ក៏វារឿងផ្សេងមួយទៀត។ អ៊ីចឹងគឺថា លោកព្រះរាជអាជ្ញា ខ្ញុំគ្រាន់តែសុំឲ្យបំភ្លឺទេ មិនមែនចង់ឲ្យលោកបង្រៀនខ្ញុំទេ។

**ប្រធានអង្គជំនុំ៖**

លោក កាណាវាស មុន សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

ប្រសិនបើអនុញ្ញាត ខ្ញុំសូមលើកឡើងដោយសង្ខេប។ កាលពីថ្ងៃសុក្រ ពេលរសៀលយើងបាន

ទទួលអ៊ីម៉ែលពីលោក ខេលី ដែលគាត់បានលើកអំពីសៀវភៅដែលលើកឡើងនាពេលនេះ គឺក្រោយពេលដែលមានការថ្លែងបើកការចោទប្រកាន់។ នៅក្នុងទំព័រដំបូងលោក ខេលី បានបញ្ជាក់ថា នៅក្នុងទំព័រទី១នៃសៀវភៅ គឺវាជាកិច្ចសម្ភាសន៍ជាងមួយពាន់ម៉ោងជាមួយនឹងលោក នួន ជា។ នៅពេលដែលខ្ញុំអានសៀវភៅនោះ ប្រហែលជាភាគីក៏បានអានដែរ សៀវភៅនោះគឺវាជាប្រវត្តិរូបរបស់បុគ្គលម្នាក់ ដែលលោក ថេត សម្បត្តិ បាននិយាយអំពីខ្លួនគាត់ ហើយគាត់បានធ្វើការទាញសេចក្ដីសន្និដ្ឋានចេញពីកិច្ចសម្ភាសន៍ ហើយគាត់មិនបានដកស្រង់សម្ដីអ្នក ដែលត្រូវបានសម្ភាសជាគ្រប់ពេលវេលានោះទេ។ ដូច្នោះហើយ ខ្ញុំសូមជំទាស់ក្នុងការប្រើប្រាស់សៀវភៅនេះ លើកលែងតែសហព្រះរាជអាជ្ញា អាចមានលទ្ធភាពយកនូវកិច្ចសម្ភាសន៍ ជាងមួយពាន់ម៉ោងទាំងអស់នោះយកមកបង្ហាញ។ ហើយដើម្បីឲ្យយើងអាចធ្វើការបញ្ជាក់ថាតើលោក នួន ជា នោះ គាត់បាននិយាយអ្វីខ្លះ ជាងជាងយកមកនិយាយពេលនេះ។

[១១:៥៨:០៧]

ជាសង្ខេប ពេលខ្លះទៅលោក នួន ជា អាចនិយាយមែនក៏ប៉ុន្តែពេលខ្លះទៅជាការសន្និដ្ឋានពីសម្ដីរបស់លោក នួន ជា តែប៉ុណ្ណោះ។ ដូច្នេះប្រសិនករណីហ្នឹង ខ្ញុំសូមធ្វើការបដិសេធ។ ខ្ញុំទទួលស្គាល់ក្នុងការធ្វើការងារដោយខ្ជាប់ខ្ជួន ក្នុងការដាក់ឯកសារនេះ។ ដូច្នេះហើយ ខ្ញុំអាចយល់ថា ការដូចនេះពេលខ្លះទៅវាមិនមានលក្ខណៈត្រឹមត្រូវនោះទេ។ សូមអរគុណ។

[១១:៥៨:៣៤]

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នួន ជា។

**លោក នួន ជា៖**

រឿងហ្នឹងវាខ្លីទេ។ ខ្ញុំបានសរសេរសៀវភៅអំពីប្រវត្តិរបស់ខ្ញុំមួយ ហើយខ្ញុំពឹងឲ្យ ថេត សម្បត្តិ នេះបោះពុម្ពនៅប្រទេសកម្ពុជាយើងនេះ។ ថេត សម្បត្តិ ប្រាប់ខ្ញុំថា សៀវភៅនេះបើយកទៅបោះនៅញូវយ៉ក ណ៎ា វាមានតម្លៃជាង ពីព្រោះនៅប្រទេសខ្មែរយើងគេមិនសូវអានទេ។ ខ្ញុំក៏មិនសូវយល់ពីរឿងនេះដែរ ពីរឿងធ្វើសៀវភៅលក់ សៀវភៅអីនេះ ខ្ញុំថា បើអ៊ីចឹងសម្រេចមិត្តទៅ។ ដល់យកទៅ វាបាត់មិនដឹងប៉ុន្មានៗ ប្រហែលជា១០ឆ្នាំហើយ សៀវភៅហ្នឹងសរសេរ ខ្ញុំសរសេរហ្នឹង។ សរសេរពីប្រវត្តិបក្សប្រវត្តិអីនេះបន្តិចបន្តួច។ រហូតដល់ ថេត សម្បត្តិ ហ្នឹងយកសៀវភៅហ្នឹងទៅប្រែជាភាសាអង់គ្លេស

ដាក់ថា “សត្រូវប្រជាជន” ក៏មាន ហើយដាក់ស្អីក៏មាន ហើយទៅធ្វើជាកុនអី ហើយខ្ញុំអត់ដែរដឹងសោះ។ ថេត សម្បត្តិ នេះអត់សួរយោបល់អីខ្ញុំមួយម៉ាត់សោះ។ ខ្ញុំស្មានតែសៀវភៅហ្នឹង គេមិនបោះតើ។ ខ្ញុំក៏នៅស្ងៀមទៅ ខ្ជិលសួរ ខ្ជិលអី នេះរឿងហ្នឹង វាមានតែប៉ុណ្ណឹង។

ប៉ុន្តែសៀវភៅហ្នឹង ខ្ញុំសរសេរគ្រង់ ខ្ញុំសរសេរពីប្រវត្តិរបស់បក្សយ៉ាងម៉េចៗ វាខុស វាត្រូវយ៉ាងម៉េច អីយ៉ាងម៉េចៗ ហើយសៀវភៅហ្នឹងថាយកទៅបោះនៅញូវយ៉ក វាបានមានតម្លៃ។ ខ្ញុំក៏មិនដឹងថា វាតម្លៃអីយ៉ាងម៉េចៗទេ។ ហើយសៀវភៅហ្នឹងមាននារីកូរ៉េម្នាក់ឈ្មោះអីទៅ ខ្ញុំភ្លេចទៅរួមសរសេរដដែល ហើយមិនដឹងជាកែអត្ថបទខ្ញុំហ្នឹងយ៉ាងម៉េចៗ ខ្ញុំក៏មិនបានមើល។ ខ្ញុំសូមយកអត្ថបទដើមមកមើល អត្ថបទដែលផ្ញើទៅញូវយ៉កហ្នឹងណា ហើយមិនឃើញផ្ញើមកឲ្យខ្ញុំវិញទេ។ នេះខ្ញុំសូមជម្រាបលោកៗប្រធានឲ្យជ្រាបរឿងនោះ វាខ្លីតែប៉ុណ្ណឹង។ ប៉ុន្តែ សម្បត្តិ ហ្នឹងយកទៅពង្រីកធ្វើកុន ធ្វើអីៗ ធ្វើខ្សែអាត់អីៗទៀត អត់ប្រាប់ខ្ញុំមួយម៉ាត់សោះ អានេះ វាល្មើសក្នុងសិទ្ធិរបស់ខ្ញុំដែរ ប៉ុន្តែខ្ញុំមិននិយាយ។

នេះខ្ញុំសូមជម្រាប រឿងហ្នឹងវាខ្លីតែប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណច្រើនទូវការផ្តល់ព័ត៌មានដូច្នេះ ប៉ុន្តែរឿងកិច្ចការតុលាការអាចប្លែកពីនេះ ដោយសារតុលាការត្រូវការបង្ហាញភស្តុតាងៗដែលត្រូវដាក់នៅក្នុងសំណុំរឿង ហើយដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ដែលកំណត់អត្តសញ្ញាណឯកសារត្រឹមត្រូវ។

បញ្ហាទីពីរ ឯកសារដែលពាក់ព័ន្ធយកមកដេញដោល គឺកំណត់ទៅតាមអង្គហេតុជាក់លាក់ដែលអង្គជំនុំជម្រះបានកំណត់សម្រាប់ធ្វើសវនាការក្នុងវគ្គនីមួយៗ ដើម្បីចៀសវាងនូវភាពច្របូកច្របល់ដោយសារសំណុំរឿងក្តីនេះ វាធំធេង។ ប្រសិនបើគ្រប់គ្រងនៅក្នុងការដេញដោល នៅក្នុងការបង្ហាញភស្តុតាងនានា មិនជាក់លាក់ មិនតឹងតែងទេនោះ វានឹងអាចធ្វើឲ្យដេញដោលទៅមុខទៀតហ្នឹង វាច្របូកច្របល់រវាងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការរួចហើយៗ និងអង្គដែលមិនទាន់បានធ្វើកំណត់ឲ្យធ្វើសវនាការ។ នេះជាបញ្ហាបច្ចេកទេសនៅក្នុងការគ្រប់គ្រងដឹកនាំកិច្ចដំណើរការពិភាក្សា។

ប៉ុន្តែបញ្ហា ទោះបីយ៉ាងណាក៏ដោយក៏មានបញ្ហាមួយចំនួន ដែលជាការចង្អុលបង្ហាញទៅដល់មែនប៉ុន្តែឯកសារទាំងអស់នេះមិនទាន់ឈានដល់ការដេញដោលនូវខ្លឹមសារនៃសៀវភៅទេ គ្រាន់តែជាមូលដ្ឋាននៃការបង្ហាញនូវមូលហេតុដើមនូវគោលបំណងដើមនៃកំណត់ហេតុ ឬក៏ការពិភាក្សាផ្តល់បទសម្ភាសន៍ផ្សេងៗពាក់ព័ន្ធជាមួយនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដូចឯកសារដែលបានបង្ហាញ ដែលលោកបានធ្វើ

សម្ភាសជាមួយនឹង ខឹម ងួន ដែលបានដាក់បង្ហាញនូវកញ្ចក់អេក្រង់ទូរទស្សន៍ ដូច្នេះដែរ។ នេះជាបញ្ហាបច្ចេកទេសលើការងារគ្រប់គ្រងកិច្ចដំណើរការសវនាការ។

ហើយដើម្បីឲ្យបានច្បាស់លាស់លើបញ្ហានេះ សូមប្រគល់វេទិកាទៅលោកស្រីចៅក្រម ស៊ីវៀល ខាតវ៉ាយថ៍ ដើម្បីធ្វើការសង្កេតលើបញ្ហានេះ។ សូមអញ្ជើញ!

[១២:០៤:៥៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន លោកសហព្រះរាជអាជ្ញា។ ខ្ញុំយល់ឃើញថា លោកបានយោងទៅលើសៀវភៅនេះដែលមានចំណងជើងថា *"ប៊ីហាញ ឌឺ ឃាលលីង ហ្វៀល (Behind the Killing Field)"* ដោយសរសេរដោយលោក ថេត សម្បត្តិ ។ ដើម្បីបញ្ជាក់ថា វាមានភាពពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍រវាងជនជាប់ចោទ និងលោក ថេត សម្បត្តិ នោះ ហើយដើម្បីកុំឲ្យលើកឡើងអំពីខ្លឹមសារនៃសៀវភៅពេលនេះ គឺលោកចង់សួរតែភាពពាក់ព័ន្ធតែប៉ុណ្ណោះទេ តើពិតជាត្រឹមត្រូវដែរឬទេ?

**លោក ខេល លីសាក់៖**

គឺពិតជាត្រឹមត្រូវ។ នៅពេលនេះ យើងមិនមានការសួរសំណួរពាក់ព័ន្ធទៅលើខ្លឹមសារនៃសៀវភៅនោះទេ យើងគ្រាន់តែចង់បញ្ជាក់ថា វាមានកិច្ចសម្ភាសន៍នេះដែរឬទេ? ហើយសៀវភៅនោះ គឺវាមានពាក់ព័ន្ធយ៉ាងម៉េច?

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

នៅក្នុងដំណាក់កាលក្រោយលោកចង់ដាក់សៀវភៅនេះនៅចំពោះមុខអង្គជំនុំជម្រះនៅពេលក្រោយ លោកមិនចង់ធ្វើឡើងនៅពេលនេះទេ តើពិតជាត្រឹមត្រូវដែរឬទេ?

**លោក ខេល លីសាក់៖**

គឺពិតជាត្រឹមត្រូវ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

[១២:០៦:១០]

**ប្រធានអង្គជំនុំ៖**

បាទ, ឥឡូវដល់ពេលសមល្មមពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការ

សម្រាប់ព្រឹកនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តនៅរសៀលនេះ គឺចាប់ពីពេលម៉ោងមួយនិងសាមសិបនាទី។ ហេតុដូច្នេះ ភាគីនិងសាធារណជនជ្រាបនឹងសូមអញ្ជើញចូលមកកាន់កន្លែងរៀងៗខ្លួនមុនម៉ោងមួយនិងសាមសិបនាទី។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់បន្ទប់រង់ចាំនៅខាងក្រោម ហើយនិងឲ្យនាំពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

*(សវនាការសម្រាកពីម៉ោង ១២:០៧ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការនូវរសៀលនេះ ដោយប្រព័ន្ធសោតទស្សន៍ដែលបានរៀបចំសាក្សី ឡុង នរិន្ទ បានរៀបចំ និងដំណើរការរួចហើយ។ ដូច្នេះ នៅរសៀលនេះយើងនឹងបន្តស្តាប់សក្ខីកម្មសាក្សី ឡុង នរិន្ទ តាមប្រព័ន្ធសោតទស្សន៍។ ប៉ុន្តែមុននឹងផ្តល់វេទិកាទៅភាគីដែលពាក់ព័ន្ធ អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនថា ឥឡូវនេះលោក ឡុង នរិន្ទ ដោយសារគាត់វ័យចាស់របស់គាត់ ហើយនិងបញ្ហាជំងឺប្រចាំកាយរបស់គាត់នោះ គឺគាត់ត្រូវការនូវកូនរបស់គាត់ឈ្មោះ ឡុង សុធារិទ្ធ ដែលជាវេជ្ជបណ្ឌិតមួយរូបនៅអង្គុយជិតគាត់ ដើម្បីជួយត្រួតពិនិត្យនូវបញ្ហាសុខភាពរបស់គាត់រួមជាមួយនឹងលោក ញ៉ែម សំណាង ដែលជាបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។ ហើយម្យ៉ាងទៀតគឺដោយសារស្ថានភាពនៃសុខភាពនេះ អំឡុងពេលនៃការស្តាប់សក្ខីកម្មរបស់គាត់ទំនងមិនបានរយៈពេលវែងទេ។ អ៊ីចឹងគឺអាច១៥មីនុត ឬក៏២០មីនុត អាហ្នឹងអាចគាត់សុំសម្រាក។

[១៣:៣៤:០៧]

ហើយដើម្បីពន្លឿនកិច្ចដំណើរការនេះ សូមភាគីដែលពាក់ព័ន្ធរៀបចំនូវសំណួរដែលខ្លី ហើយច្បាស់លាស់ ដើម្បីឲ្យគាត់ងាយក្នុងការស្តាប់ និងឆ្លើយតបវិញបានឆាប់រហ័យ ដើម្បីអាចមានលទ្ធភាពក្នុងការបញ្ចប់យ៉ាងឆាប់រហ័ស ឬក្នុងអំឡុងពេលមួយសមស្របចំពោះសាក្សីរូបនេះ។

ហើយអង្គជំនុំជម្រះក៏នៅចងចាំផងដែរថា កាលពីពេលមុននោះ មុននឹងពេលបញ្ចប់នូវកិច្ច

ពិភាក្សាដេញដោលស្ដាប់សក្ខីកម្មរូបនេះ គឺដល់វេនសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលស្នើសុំសាកសួរ១០មីនុត។ ហើយកាលណោះអង្គជំនុំជម្រះអនុញ្ញាត។ ហើយដល់ពេលនេះ តើខាងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅតែប៉ុនប៉ងនៅក្នុងប្រើពេល១០នាទី ដែលបានសុំនេះ ដើម្បីក្នុងការសួរទៅសាក្សីរូបនេះដែរឬក៏អត់?

**លោក ពេជ អង្គ៖**

បាទ, សូមគោរពលោកប្រធាន ខាងមេធាវីនាំមុខនៅតែរក្សាសំណើសុំនេះ សុំលោកប្រធានអនុញ្ញាតឲ្យលោកស្រីមេធាវី នូស៊ីន សាកាវ៉ាទី ប្រើប្រាស់ពេលវេលានេះ។

សូមអរគុណ។

[១៣:៣៥:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។

សួស្ដីលោក ឡុង នរិន្ទ?

**លោក ឡុង នរិន្ទ៖**

បាទ។

**ប្រធានអង្គជំនុំ៖**

លោក ឡុង នរិន្ទ ស្ដាប់ឮខ្ញុំនិយាយទេ?

**លោក ឡុង នរិន្ទ៖**

គាត់សួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

សួរថា ស្ដាប់ឮលោកប្រធានចៅក្រមនិយាយទេ?

**លោក ឡុង នរិន្ទ៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ អង្គជំនុំជម្រះបន្តការស្ដាប់នូវសក្ខីកម្មរបស់លោក ដើម្បីបញ្ចប់នូវកិច្ចដំណើរការនីតិវិធីសវនាការតាមមធ្យោបាយសោតទស្សន៍នេះ។ ប៉ុន្តែ មុននឹងដំណើរការអង្គជំនុំជម្រះសូមជម្រាប

លោកថា ប្រសិនបើលោកត្រូវការសម្រាក ឬក៏ទៅបន្ទប់ទឹកគឺលោកប្រាប់ទៅលោក សំណាង ភ្លាម ហើយលោក សំណាង នឹងស្នើសុំជូនដំណឹងមកខ្ញុំ ខ្ញុំនឹងអនុញ្ញាតភ្លាម។ អ៊ំស្តាប់បានទេ?

**លោក ឡុង នរិន្ទ៖**

បាន។

**ប្រធានអង្គជំនុំ៖**

បាទ, ជាបន្តនេះ អង្គជំនុំជម្រះផ្ទេរ ប្រគល់វេទិកាទៅឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការសួរសំណួរនៅពេលវេលាដែលបានប្រគល់ឲ្យ។

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណ។

តើខ្ញុំសូមអនុញ្ញាតអង្គុយសួរបានដែរឬទេ លោកប្រធានចៅក្រម?

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតតាមការស្នើសុំ។

[១៣:៣៧:០៩]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី៖**

**ស៖** សូមជម្រាបសួរលោក ឡុង នរិន្ទ មុនពេលដែលយើងបញ្ចប់ពីសប្តាហ៍មុន យើងបាននិយាយអំពីអ្នកដែលត្រឡប់មកប-១។ តើលោកនៅចាំទេ?

**លោក ញ៉ែម សំណាង៖**

ឮទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ឮគាត់សួរថាម៉េចអំមិញ? សួរថាត្រឡប់ពីប-១?

**លោក ញ៉ែម សំណាង៖**

ត្រឡប់មកពីប-១ មកវិញ។

**ស៖** អ្នកត្រឡប់មកពីបរទេសមកប-១វិញ? លោក ឡុង នរិន្ទ តើលោកអាចនិយាយម្តងទៀតទេ ចម្លើយអម្បាញ់មិញនេះ?

**ឆ៖** បាទ។

[១៣:៣៨:២៣]

**លោក ញ៉ែម សំណាង៖**

អ៊ឺច្បាស់សំណួរថាអំមិញទេ?

**ឆ៖** ឆ្លើយម្តងទៀតបាទេ?

**លោក ញ៉ែម សំណាង៖**

ទាក់ទងនឹងសំណួរដែលថា តើជនបរទេសដែលត្រឡប់មកពី ប-១ នោះ-- ត្រឡប់ពីបរទេសមកចូលប-១ នោះយ៉ាងម៉េចណាអ៊ំ?

**អ្នកបកប្រែ៖**

សូមអភ័យទោសលោកប្រធានពីអ្នកបកប្រែ។ សំណួរសួរថា តើអ្នកដែលត្រឡប់មកពីបរទេសមក ប-១ វិញនោះ ជួបស្ថានភាពដូចម្តេច?

**សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី៖**

**ស៖** អ៊ីចឹងគឺអ្នកដែលមកពីបរទេសវិញមកប-១ នោះ។ អ៊ីចឹងខ្ញុំសួរឡើងវិញពីសំណួរនេះ។ នៅពេលដែលអ្នកត្រឡប់មកពីបរទេសមកប្រទេសកម្ពុជាវិញមក ប-១ តើគេតម្រូវឲ្យអ្នកទាំងនោះសរសេរប្រវត្តិរូបដែរឬទេ?

[១៣:៣៩:៣២]

**លោក ឡុង នរិន្ទ៖**

**ឆ៖** អាហ្នឹងខ្ញុំមិនអាចដឹងថា តើអ្នកអស់នោះគេឲ្យសរសេរដែរឬអត់ទេប្រវត្តិរូប ប៉ុន្តែខ្លួនខ្ញុំគឺថាវាមានបញ្ហាទាក់ទង មានអ្នកចោទប្រកាន់ថា ប្រហែលជាមានអ្នកចោទប្រកាន់ថាខ្ញុំ សេ.អ៊ី.អា អ៊ីចឹងហើយ ថាភ្នាក់ងារ សេ.អ៊ី.អា អ៊ីចឹងហើយ បានជា ផ្ទៃអ៊ំ អៀង សារី គាត់ថាឲ្យខ្ញុំសរសេរប្រវត្តិរូប។ ពីព្រោះរឿងហ្នឹង វារឿងដែលខ្ញុំនិយាយពីរឿង ថាច់ ជា នោះវាអ៊ីចឹង។ គឺថារៀនជាមួយគ្នានៅសាលាគរុវិជ្ជាដូចគ្នា ហើយលេងកីឡានៅក្នុងក្រុមជាមួយគ្នា។ ក្រុមសាលាគរុវិជ្ជាហ្នឹង ទាំង អត្តពលកម្ម ទាំងបាល់ទាត់ ដល់អ៊ីចឹងគេមើលទៅឃើញជិតស្និតនឹងគ្នា ត្រូវគេចោទតែម្តងមើលទៅ។

ហ្នឹងខ្ញុំស្មានទេ ប្រហែលអាចអ៊ីចឹងហើយបានជា គាត់ចង់ដឹងច្បាស់ពីរឿងហ្នឹង គាត់ឲ្យខ្ញុំសរសេរប្រវត្តិរូប។ គាត់សួរខ្ញុំហើយ គាត់សួរខ្ញុំពីរឿង ថាច់ ជា ហ្នឹងខ្ញុំជម្រាបគាត់ថា អ៊ីចឹងថា ថាច់ ជា ហ្នឹងគ្រាន់តែប្រឡងចូលសាលាគរុវិជ្ជាឆ្នាំជាមួយគ្នា រួចទៅរៀនបានថ្នាក់ទី៦ ហើយថ្នាក់ទី៥ ជាមួយគ្នា ដល់ថ្នាក់ ទៅលើៗទៀត អាហ្នឹងគឺអត់ទេ។

[១៣:៤១:១៦]

ដល់ទី៤ ហ្នឹង ដូចជាបែកគ្នា ហើយខ្ញុំចេះតែបន្តទៅទៀត រៀនបន្តទៅទៀតទៅ ថាច់ ជា ក៏គេចេញ បាត់ទៅ។ បែបធ្វើគ្រូមិនដឹង ធ្វើអីមិនដឹងទេ ធ្វើសាស្ត្រាចារ្យមើលទៅ។

**ស៖** សូមអរគុណ។ ថាតើលោក អៀង សារី សុំឲ្យលោករៀបចំប្រវត្តិរូបហ្នឹងសម្រាប់ឲ្យទៅអ្នកណា? ឲ្យទៅខាងណាដែរ?

**ឆ៖** ខ្ញុំអត់ដឹងទេហ្នឹង រឿងហ្នឹងមិនដឹងជាគាត់រៀបចំឲ្យទៅខាងណា ប៉ុន្តែគាត់សួរខ្ញុំផ្ទាល់នោះ គាត់សួរហើយ គាត់សួរពីរឿង ថាច់ ជា ហ្នឹង រួចដល់ខ្ញុំជម្រាបគាត់ទៅ គាត់ថាឲ្យសរសេរប្រវត្តិរូបឲ្យច្បាស់លាស់។ ខ្ញុំសរសេរប្រវត្តិរូបហ្នឹងទៅ។

**ស៖** សូមអរគុណ។ លោកបានបញ្ជាក់ពីសប្តាហ៍មុនថា អ្នកដែលត្រឡប់មកវិញមួយចំនួនត្រូវបាត់ខ្លួន តើលោក អៀង សារី ដែលនិយាយពីអ្នកដែលបានបាត់ខ្លួនទាំងអស់នោះដែរឬទេ?

**ឆ៖** អត់។

**ស៖** លោកក៏បានបញ្ជាក់ដែរពីអាទិត្យមុន បន្ទាប់ពីមនុស្សចេះតែបាត់ខ្លួនទៅ បុគ្គលិកនៅក្រសួងចេះតែនិយាយ ហើយគេនិយាយថា មនុស្សទៅរៀនសូត្រ ហើយម្នាក់ៗគឺថា ភ័យខ្លាចមិនចង់ទៅរៀនសូត្រទេ ថាតើគេភ័យខ្លាចពីរឿងអ្វី? ដែលគេមិនចង់ទៅរៀនសូត្រនោះ?

**ឆ៖** អាហ្នឹងពីព្រោះ ពាក្យរៀនសូត្រហ្នឹងអង្កាល់ហ្នឹងវាពិបាកណាស់។ ពាក្យថា រៀនសូត្រហ្នឹង ឬក៏ពាក្យថា ទៅធ្វើការងារពលកម្មហ្នឹង គឺមានទៅហ្នឹងឯណាពួកអ្នកអស់ហ្នឹងទៅសប៉ុន្មានទេ ស-២១ ឯណោះ។ ទៅសន្តិសុខឯណោះ។

[១៣:៤៣:៤៤]

**ស៖** ថាតើការងារអ្វីដែលគេបញ្ជូនអ្នកទាំងអស់នោះឲ្យទៅធ្វើការងារអ្វី?

**ឆ៖** អាហ្នឹងខ្ញុំមិនអាចដឹងទេ ពីព្រោះវាសុទ្ធតែថ្នាក់មជ្ឈិមៗអចិន្ត្រៃយ៍នោះ ហើយខ្ញុំជាយុទ្ធជន។

**ស៖** ហេតុអ្វីបានជាលោកយល់ថា ការទៅរៀនសូត្រ មានន័យថា ការទៅធ្វើពលកម្ម ឬក៏ជាការបញ្ជូនទៅស-២១ តើលោកបានធ្លាប់ឮអ្នកណាប្រាប់លោកអំពីរឿងនេះដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** ពីសប្តាហ៍មុនលោកបាននិយាយថា ទាំងបឹងត្របែក ទាំងច្រាំងចម្រេះ គឺជាផ្នែកនៃស-២១ ហើយអ្នកដែលត្រឡប់មកពីបរទេសត្រូវបានបញ្ជូនមកទីនោះហើយ តើនៅក្រោមប-១ ហ្នឹងគឺថា មន្ទីរទាំងពីរនេះជាមន្ទីរដូចម្តេចដែរ?

[១៣:៤៥:១៩]

**លោក ញ៉ែម សំណាង៖**

សូមសំណួរម្តងទៀត។

**សួរដោយលោកស្រី ទូស៊ីន សាកាវ៉ាទី៖**

**ស៖** លោកបាននិយាយថា បឹងត្របែក ហើយនិងច្រាំងចម្រេះ គឺជាផ្នែកនៃប-១ តើទីតាំងទាំងពីរហ្នឹងក្រសួងការបរទេសដែលថា ប-១ នោះប្រើសម្រាប់ធ្វើអ្វី គឺមន្ទីរដែលគេហៅថា បឹងត្របែក និងច្រាំងចម្រេះ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ច្រាំងចម្រេះ ឬក៏ទៅបឹងត្របែកហ្នឹង គឺទៅធ្វើ-- មែនទែនពិសេសទៅច្រាំងចម្រេះទៅធ្វើពលកម្ម ជាដាំដំណាំ ធ្វើត្រី ធ្វើអីអ៊ីចឹងរបៀបអ៊ីចឹង។

**ស៖** លោកបាននិយាយថា អ្នកដែលត្រឡប់មកពីបរទេស ត្រូវបានគេយកទៅដាក់កន្លែងនោះ តើគេឲ្យធ្វើអ្វីខ្លះ? ថាតើគេឲ្យអ្នកទាំងហ្នឹងដាំបន្លែរកត្រី ឬក៏ធ្វើអ្វីខ្លះទៀតជាពលកម្មនោះ?

**ឆ៖** ដែលទៅដាក់នៅប-១ អ្នកនៅប-១ផ្ទាល់ហ្នឹងគឺថា ដាំបន្លែ ហើយថែទាំបន្លែហ្នឹងទៅស្រោចទឹកទៅសម្រាប់ខ្លួនឯងកាលហ្នឹង គឺមាគ៌ាឯករាជ្យម្ចាស់ការ។

**ស៖** តើអ្នកណាជាអ្នកចាត់តាំងអ្នកទាំងអស់នោះទៅកន្លែងទាំងនោះ? ថាតើអ្នកណាជាអ្នកបញ្ជូនទៅបឹងត្របែក ហើយនិងគ្រប់គ្រងពួកគេនៅបឹងត្របែក ឬក៏នៅច្រាំងចម្រេះនោះ?

**ឆ៖** ខ្ញុំមិនដឹងទេ ពីព្រោះៗ ជាសុទ្ធថ្នាក់ខ្ពស់ៗហើយ សុទ្ធតែថ្នាក់មជ្ឈិមនោះបានទៅចាត់ចែងឬក៏សមាជិកត្រៀមមជ្ឈិម បានទៅចាត់ចែងការងារអស់ហ្នឹង ដែលខ្ញុំយុទ្ធជនអត់ដឹងអីទេ។

[១៣:៤៨:០៦]

**ស៖** ថាតើអ្នកដែលត្រឡប់មកពីបរទេសគេហៅថា ជាបញ្ញវន្ត ឬក៏គេហៅថាអ្វីដែលគេបញ្ជូនដែលពួកគាត់ត្រឡប់មកដល់កម្ពុជាវិញនោះ?

**ឆ៖** ពេលដែលមកដល់ប៉េកាំង គឺអ៊ំ អៀង សារី ហ្នឹងគាត់ថា តែងតែសុំមកស្រុកវិញហ្នឹងគឺសុំតាមគាត់ហ្នឹង តាមរយៈគាត់ហ្នឹង ព្រោះគាត់ជាបេសកជនពិសេសធ្វើការងារបរទេស ហើយមកដល់អ្នកដែលនេះខ្លះមកចូលប-១ហ្នឹង ខ្លះទៀតមិនដឹងទៅណា ខ្ញុំមិនដឹងទេ។

**ស៖** ចំពោះដែលអ្នកត្រឡប់មកដល់ តើគេហៅអ្នកទាំងអស់នោះថាជាពួកបញ្ញវន្តទេ អ្នកដែលមកដល់ថ្មីនៅក្នុង ប-១?

**ឆ៖** មកដល់ប-១ គេអត់ដែលហៅថា-- មកដល់ភ្លាមហ្នឹងគ្មានដែលអ្នកណាគេហៅថា អ្នកបដិវត្តន៍ទេអ្នកមកពីក្រៅនោះ។

[១៣:៤៩:៣៧]

**លោក ញ៉ែម សំណាង៖**

បញ្ញវន្តអ៊ំ។

**លោក ឡុង នរិន្ទ៖**

**ឆ៖** គេហៅថាបញ្ញវន្តហ្នឹងប៉ុណ្ណឹង។ ទាល់តែកសាងខ្លួនបានជា អ្នកបដិវត្តន៍បានគេហៅថាអ្នកបដិវត្តន៍។

**សួរដោយលោកស្រី ទូស៊ីន សាកាវ៉ាទី៖**

**ស៖** តើលោកអាចពន្យល់បានទេថា តើគេត្រូវបញ្ជាក់ខ្លួនឯងឡើងវិញ ឬក៏កសាងខ្លួនឯងឡើងវិញនោះ គឺមានន័យដូចម្ដេច?

[១៣:៥០:២០]

**ឆ៖** កសាងនេះខ្លួនឯងនេះ គឺអាហ្នឹងគឺខ្លួនឯងមែនតែម្ដង។ យើងស្ដាប់ទ្រឹស្ដីបដិវត្តន៍ហ្នឹងទៅរួចខំកសាងខ្លួនទៅ ខំធ្វើការទៅ ខំធ្វើការទាំង-- បញ្ញាជនខំធ្វើការទាំង ខាងបញ្ញា ទាំងធ្វើការងារខាងពលកម្ម។ អាហ្នឹង បើខ្លួន ខ្ញុំផ្ទាល់គឺ ព្រឹកឡើង ភ្ញាក់ពីម៉ោងបួន បួនកន្លះ ស្រោចដំណាំបន្លែហ្នឹងនៅ ប-១ ហ្នឹង។ សួនមាន-- សួនច្បារមួយ សួនបន្លែហ្នឹងមួយ។ ដាំអាហ្នឹងទៅ ហើយថែទៅ រួចទៅពួកអ្នកដែលដាំស្ពៃហ្នឹងគេទៅកាត់យកមកបន្លែអី ស្ពៃអី គេទៅកាត់យកមកស្ងោទៅ ហូបទៅ។

**ប្រធានអង្គជំនុំ៖**

មេធាវីសល់ប៉ុន្មានសំណួរទៀត មេធាវីដូចហួសពេលហើយ ផុតពេលហើយ។ នៅប៉ុន្មានសំណួរ សំណួរទៀត? អនុញ្ញាតឲ្យមួយសំណួរទៀត។

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណលោកប្រធាន ខ្ញុំមានសំណួរ ខ្ញុំនៅសល់សំណួរពីរប៉ុន្តែបើលោកប្រធានអនុញ្ញាតតែ មួយ ខ្ញុំអាចសួរតែមួយ។

**សួរដោយលោកស្រី នូស៊ីន សាកាវ៉ាទី៖**

**ស៖** ថាតើលោកមានការប្រជុំរៀនសូត្រ ឬក៏វគ្គសិក្សាអីទេនៅច្រាំងចម្រេះ ហើយនិងនៅបឹង ត្របែក?

**លោក ឡុង នរិន្ទ៖**

**ឆ៖** នៅច្រាំងចម្រេះ ហើយនៅបឹងត្របែក ខ្ញុំមិនដឹង ពីព្រោះខ្ញុំអត់ដែលបានទៅទេកន្លែងនុ៎ង។ នៅ ប-១ ហ្នឹង បានខ្ញុំដឹង ហ្នឹងមានប្រជុំរៀនសូត្រ។ មានប្រជុំការងារ ប្រជុំរៀនសូត្រ ហើយប្រជុំ ពាក់ព័ន្ធ។ អាហ្នឹងត្រួតពិនិត្យខ្លួនឯងហើយ។

[១៣:៥២:៥៨]

**លោកស្រី នូស៊ីន សាកាវ៉ាទី៖**

សូមអរគុណច្រើនលោក ឡុង នរិន្ទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាកិច្ចបន្តមុននឹងប្រគល់វេទិកាទៅសហមេធាវីការពារក្តី តើអស់លោក លោកស្រី ចៅក្រមមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោក ឡុង នរិន្ទ។ ខ្ញុំជាចៅក្រម ឡាវែន៍។ ខ្ញុំមានសំណួរទីបីដើម្បីចោទសួរ

ដល់លោក។ ជាដំបូង ខ្ញុំចង់ដឹងថា តើគេបានផ្តល់ឯកសារមួយដែលមានលេខយោង ES20.3 ដែលមានចំណងជើងជាភាសាបារាំងថា *"ការពិតលើរបបផ្តាច់ការ ប៉ុល ពត"*។ តើយើងអាចដឹងថា លោក ឡុង នរិន្ទ បានទទួលឯកសារនេះដែរឬទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** (ឮមិនច្បាស់)

**ស៖** តើយើងអាចដឹងទេថា តើលោក ឡុង នរិន្ទ បានដឹងអំពីឯកសារនេះដែរឬទេ ឬក៏បានទទួលឯកសារនេះដែរឬទេ? ឬក៏គាត់ ឬក៏លោកមាននៅនឹងដៃហ្នឹងស្រាប់ហើយ?

[១៣:៥៥:០២]

**ប្រធានអង្គជំនុំ៖**

លោក សំណាង អាចហុចបង្ហាញនូវឯកសារនៅក្នុងដៃរបស់លោក បើមានជូនគាត់ទៅលោក ឡុង នរិន្ទ ដើម្បីពិនិត្យមើល។

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន។

លោកប្រធានសូមអនុញ្ញាតទៅយកវែនតាបន្តិច។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ, លោក ឡុង នរិន្ទ តើលោកឮខ្ញុំនិយាយដែរឬទេ? លោក ឡុង នរិន្ទ តើលោកឮខ្ញុំនិយាយដែរឬទេ?

**លោក ញ៉ែម សំណាង៖**

ឮលោកចៅក្រមនិយាយដែរឬទេ អ៊ំ?

**លោក ឡុង នរិន្ទ៖**

អត់ឮ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ, តើលោកបានអានឯកសារនេះដែរឬទេ? លោកស្គាល់ឯកសារនេះដែរឬទេ?

**លោក ញ៉ែម សំណាង៖**

លោកចៅក្រមសួរថា តើអ៊ំស្គាល់ទេ ហើយបានស្គាល់វាដែរឬទេ?

**លោក ឡុង នរិន្ទ៖**

អត់។

**លោក ញ៉ែម សំណាង៖**

(ឮមិនច្បាស់)

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក ឡុង នរិន្ទៗ តើឯកសារនេះធ្វើឲ្យលោកនឹកឃើញដល់អ្វីមួយទេ ឬក៏លោកស្គាល់ឯកសារនេះទេ ឬក៏ឯកសារនេះថ្មីសុទ្ធសាធតែម្ដងចំពោះលោក?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំមិនដែលស្គាល់ទេឯកសារហ្នឹង។

**ស៖** ដូច្នេះលោកមិនបានដឹងថា ឯកសារនេះបានចេញមកពីមជ្ឈមណ្ឌលឯកសារនៃចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ តើលោកៗបានដឹងអំពីតួនាទីនៃមជ្ឈមណ្ឌលនេះឬទេ? គឺចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យនេះ? លោកឮសំណួរខ្ញុំដែរឬទេ? តើតួនាទីរបស់លោកនៅក្នុងចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យនេះ?

**ឆ៖** (ឮមិនច្បាស់)

**ប្រធានអង្គជំនុំ៖**

ទៅរៀបចំឡើងវិញ។ ឥឡូវលោកចៅក្រមសូមលោកសួរម្ដងទៀត។ ហើយសំណាង សំណាងជួយកត់ត្រានូវសំណួរហ្នឹងទៅ ហើយនិងនិយាយប្រាប់គាត់ឡើងវិញនៅពេលដែលគាត់ ក្នុងករណីដែលគាត់ស្ដាប់មិនយល់រំឭកពីសំណួរហ្នឹងប្រាប់គាត់ភ្លាម ដើម្បីឲ្យគាត់អាចយល់អំពីសំណួរ និងអាចឆ្លើយតបបាន ពុំដូច្នោះទេមិនអាចរកលទ្ធភាពនៃការបញ្ចប់នៅការសួរដេញដោល ករណីលោក ឡុង នរិន្ទនេះបានទេ។

លោកចៅក្រម លោកសួរម្ដងទៀត ហើយអ្នកបកប្រែក៏សុំរៀបចំនូវការបកប្រែហ្នឹងឲ្យបញ្ជាក់ឲ្យច្បាស់លាស់ផង ពីព្រោះសំណួរដែលបកប្រែហ្នឹង ស្ដាប់ទៅដូចជាមិនសំណួរ មិនមែនជាសួរទេ។

[១៤:០១:៥១]

**លោក ឡុង នរិន្ទ៖**

សួរពីតួនាទីខ្ញុំនៅក្នុងចលនាហ្នឹង?

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក ឡុង នរិន្ទ តើលោកអាចរំឭកប្រាប់យើងបានទេថា តើមុខងាររបស់លោកដែលជាអគ្គលេខានៃចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យនេះ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** មែនទែន ងារហ្នឹងមានតែនៅក្នុងលើក្រដាស។

**ស៖** នៅក្នុងក្របខ័ណ្ឌនៃសកម្មភាពនោះ លោកមានទំនាក់ទំនងជាមួយសារព័ត៌មានដែរឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ឹំយល់សំណួរទេ អ៊ឹំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំមាន មានដែលទំនាក់ទំនង-- ចំពោះសារព័ត៌មាន មានតែថ្ងៃដែលបង្កើតឱកាស បង្កើតចលនាហ្នឹងព្រោះអង្កាល់ហ្នឹងគឺថាបន្តការងារពីរឿងអីមិនដឹងទេអង្កាល់ហ្នឹង ប៉ុន្តែទៅចប់ស្អីមួយហើយបានបង្កើត បង្កើតហ្នឹងចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យហ្នឹង។

[១៤:០៣:៥១]

**ស៖** នៅក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងរបស់លោកជាមួយសារព័ត៌មាននោះ តើសេចក្តីប្រកាសសារព័ត៌មាន ឬក៏ការកត់សម្គាល់ផ្សេងៗនេះត្រូវបានបញ្ជូនទៅណាទេ?

**ឆ៖** ខ្ញុំមិនដឹងទេអាហ្នឹង មិនដឹងគាត់បញ្ជូនទៅណាទេ។ បញ្ជូនទៅមជ្ឈិមក៏មិនដឹង បញ្ជូនទៅមជ្ឈិមអចិន្ត្រៃយ៍ក៏មិនដឹង ខ្ញុំមិនដឹងទេ ព្រោះខ្ញុំជាយុទ្ធជន គេសុទ្ធតែថ្នាក់ខ្ពស់ៗហើយ។

**ស៖** តើលោកពិតជាលោកដែរឬទេ ដែលលោកបានប្រកាសចំពោះមុខសារព័ត៌មាននៅក្នុងឯកសារមួយដែលមានថា D56-- D36 (ស៊ីក) ហើយចំណងជើងនៃសារព័ត៌មាននោះ គឺសម្តាធដែលទាក់ទងនឹងតុលាការខ្មែរក្រហមនោះកាន់តែធំឡើងៗ។ ហើយនៅក្នុងឯកសារនេះមានការនិយាយថាអ្នកនាំពាក្យ ឡុង នរិន្ទ បានប្រមើលទុកថាការបង្កើតតុលាការខ្មែរក្រហមនេះ នឹងបង្កើតឲ្យមានកុបកម្ម ហើយនិងខ្មែរក្រហមគិតថា អាមេរិកនៅតែប្រកាន់ចលនាដែលប្រឆាំងទៅនឹងវៀតណាម។ តើលោកជាអ្នក ជាម្ចាស់នៃសេចក្តីថ្លែងការណ៍បែបនេះមែនឬទេ?

**ឆ៖** គាត់សួរថាម៉េច? ខ្ញុំដូចជា--

**លោក ញ៉ែម សំណាង៖**

ជាអ្នកប្រកាសសេចក្តីថ្លែងការណ៍ទាក់ទងទៅនឹងការបង្កើតតុលាការខ្មែរក្រហម-- ហ្នឹងអ៊ីចឹង ទាក់ទងនឹងអ្នកកាសែតបានប្រកាសអ៊ីចឹងមែន ឬយ៉ាងម៉េច?

**ឆ៖** អត់ទេ ខ្ញុំមិនដឹងទេ ភ្លេចហើយវាយូរហើយ ប៉ុន្តែដូចមិនដែលប្រកាស ឬក៏មិនដឹងអង្កាល់ហ្នឹង។ យ៉ាងម៉េចក៏មិនដឹង។

**ស៖** មានកំណត់សម្គាល់មួយដែលមានលេខ D366/584 ហើយគឺនិយាយ-- នេះគឺជាអត្ថបទមួយដែលផ្សព្វផ្សាយទស្សនាវដ្តីឥន្ទ្រទេវីនៅភ្នំពេញ ថ្ងៃទី៦ កញ្ញា ឆ្នាំ២០០០។ គេបានចោទសំណួរទៅលោកមួយចំនួន។ គេសួរលោកដូចតទៅនេះ៖ ទាក់ទងទៅនឹងការសម្លាប់រង្គាលនៅក្រោមរបបខ្មែរក្រហម តើលោកយល់ឃើញថាខ្មែរសម្លាប់ខ្មែរគ្នាឯង ឬក៏យ៉ាងណា ឬក៏មានការអន្តរាគមន៍ពីខាងក្រៅ? ហើយលោកប្រហែលជាបានឆ្លើយនៅពេលនោះ៖ ខ្ញុំមិនដឹងទេ ខ្ញុំពេលនោះ ខ្ញុំមិនដែលបានចេញទៅណាទេ។

តើលោកឮសំណួរខ្ញុំទេ តើលោកបាននិយាយអ៊ីចឹងមែនទេ លោក ឡុង នរិន្ទ?

**ឆ៖** គាត់សួរបានទេ ឬយ៉ាងថាម៉េច?

**លោក ញ៉ែម សំណាង៖**

សុំសំណួរម្តងទៀត លោកចៅក្រម។

**ឆ៖** ទេ សំណួរនេះ ខ្ញុំយល់ហើយ ថាខ្ញុំបាននិយាយអ៊ីចឹងមែន។ ប៉ុន្តែអានិយាយអ៊ីចឹងមែននោះនិយាយពីអី?

[១៤:០៩:០៣]

**ស៖** បាទ, សំណួរគឺដូចតទៅនេះ ទាក់ទងទៅនឹងការសម្លាប់រង្គាលនៅក្រោមរបបខ្មែរក្រហមនោះ តើលោកយល់ឃើញថាខ្មែរសម្លាប់ខ្មែរគ្នាឯង ឬក៏មានការអន្តរាគមន៍ពីខាងក្រៅ? ចម្លើយរបស់លោក អង្កាល់នោះទំនងជា៖ ខ្ញុំមិនដឹងទេ ព្រោះខ្ញុំមិនដែលចេញទៅណាទេ។

**ឆ៖** អាហ្នឹងអ៊ីចឹងគឺថាខ្ញុំមិនអាចដឹងទេ។ ខ្ញុំជាយុទ្ធជនមិនមែនកម្មាភិបាលទេ អត់--។

**លោក ញ៉ែម សំណាង៖**

អ៊ីចឹង សំណួរចង់សួរអ៊ំថាតើនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០០ គេសួរអ៊ំថាមានខ្មែរសម្លាប់ខ្មែរ ឬក៏មានបញ្ហាបរទេសមកពីខាងក្រៅ ហើយអ៊ំបាននិយាយថា អ៊ំអត់បានដឹងទេ។ តើអ៊ំបាននិយាយអ៊ីចឹង

មែនដែរ ឬអត់?

**លោក ឡុង នរិន្ទ៖**

**ឆ៖** នេះខ្ញុំអត់ដឹង នោះអត់ដឹងមែនហ្នឹង។

[១៤:១០:៣៦]

**ស៖** បាទ, ឥឡូវនេះយើងត្រឡប់មកនិយាយអំពីឯកសារដែលមានចំណងជើងថា "ការពិតនៅក្រោមរបបផ្តាច់ការរបស់ ប៉ុល ពត"។ យើងយោងទៅនឹងព្រឹត្តិការណ៍សំខាន់ៗមួយចំនួន ឧទាហរណ៍ដូចជា នៅទំព័រទី៦ មានចែងយ៉ាងដូច្នេះ ការសម្លាប់រង្គាលរបស់ខ្មែរនៅទីក្រុងហាណូយ (ខ្មែរដែលប្រមូលផ្តុំនៅខ្មែរខាងជើងនៅប្រទេសវៀតណាម បន្ទាប់ពីសន្ធិសីទហ្សឺណែវនៅឆ្នាំ១៩៥៤) បន្ទាប់ពីសន្ធិសីទនៅឆ្នាំ១៩៥៤នេះ អ្នកតស៊ូខ្មែរចំនួន២.០០០នាក់ ត្រូវបានដឹកទៅផ្នែកខាងជើងនៃប្រទេសវៀតណាមនៅតាមកាប៉ាល់ប៉ូឡូញ។ លន់ នល់ បានថ្ងៃទី ខែមីនា ឆ្នាំ១៩៧០ លន់ នល់ បានទម្លាក់ សីហនុចេញពីអំណាច។ សង្គ្រាមបានផ្ទុះនៅប្រទេសកម្ពុជា ហើយនិងរាលដាលដល់ប្រទេសវៀតណាមហើយនិងឡាវ។ ក្នុងស្ថានភាពថ្មីនេះ ខ្មែរភៀសខ្លួនទាំងអស់នៅវៀតណាមខាងជើងដែលគេតែងតែហៅថា ខ្មែរហាណូយ បានស្ម័គ្រចិត្តត្រឡប់មកប្រទេសកម្ពុជាវិញ។

[១៤:១២:១២]

នៅក្នុងចំណោមក្រុមនោះ មានអ្នកបច្ចេកទេសមួយចំនួន ជាពិសេសមានផ្នែកជំនាញខាងផ្នែកយោធា ដោយខ្លាចថាក្រុមនេះជាឧបសគ្គសម្រាប់អំណាចផ្តាច់ការរបស់ខ្លួន ប៉ុល ពត បានចេញបញ្ជាឲ្យសម្លាប់ជនរួមជាតិទាំងអស់នោះ ម្នាក់ម្តងៗ ទាំងក្រុមៗរហូតដល់ការកម្ចាត់បំផ្លាញទាំងស្រុង។ លើកលែងតែមេម៉ាយពីរបីនាក់ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតដល់សព្វថ្ងៃ។ តើលោកមានសេចក្តីអត្ថាធិប្បាយអីដែរឬទេ ទាក់ទងអ្វីដែលខ្ញុំ ទើបនឹងអាននេះ?

**ឆ៖** ខ្ញុំអត់ដឹងទេ មិនជាអ្នកណានៅរស់ អ្នកណាស្លាប់។

**ស៖** ឥឡូវនេះខ្ញុំអានវគ្គមួយទៀត។ ប្រហែលជាលោកនឹងអាចនឹកឃើញអ្វីខ្លះ ទំព័របន្ទាប់ទៀតគឺថា ការជម្លៀសអ្នកក្រុងក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ នៅពេលត្រឡប់មកពីប៉េកាំងវិញនៅថ្ងៃទី២៣ មីនា ឆ្នាំ១៩៧៥។ ខ្ញុំដកស្រង់មក៖ ឯកឧត្តម អៀង សារី បានឃើញថាទីក្រុងភ្នំពេញក្លាយជាទីក្រុងខ្មោច ដោយប្រជាជនត្រូវបានជម្លៀសខ្លួនចេញរួចអស់ទៅហើយ។ ប៉ុល ពត បានសម្រេចឲ្យមានការជម្លៀស ដូច្នេះដោយឯកឧត្តម អៀង សារី មិនបានដឹងទាល់តែសោះ។ ប៉ុល ពត បានចែក

ប្រជាជនខ្មែរទាំងមូលជាពីរប្រភេទ។ ប្រជាជនមូលដ្ឋាន គឺជាអ្នកដែលបានចូលរួមក្នុងការតស៊ូ ហើយដែលកំពុងរស់នៅក្នុងសហករណ៍ រីឯប្រជាជនថ្មីវិញ ឬក៏ប្រជាជន១៧មេសា គឺអ្នកដែលត្រូវបានជម្លៀសពីក្រុងនានា ជាពិសេសពីភ្នំពេញ ប្រជាជនថ្មីត្រូវបានបញ្ជូនទៅការដ្ឋានផ្សេងនៅតាមជនបទ ស្រែចម្ការ ការដ្ឋានសំណង់ទំនប់ ឬក៏ការដ្ឋានសាងសង់ផ្លូវរទេះភ្លើង ដើម្បីហ្វឹកហាត់ឲ្យចេះអត់ធន់ និងការរងទុក្ខលំបាកវេទនាផ្លូវចិត្តនិងផ្លូវកាយ។ ទង្វើបែបនេះបណ្ដាលឲ្យមានការបាក់បែកគ្រួសារ ដោយសមាជិកគ្រួសារគេត្រូវបំបែកឲ្យទៅធ្វើការងារផ្សេងៗ ទៅតាមអាយុនិងកម្លាំងកាយ គួរឲ្យខ្លោចចិត្តណាស់ អ្នកខ្លះដែលបង្ហាញសេចក្ដីស្រលាញ់ចំពោះគ្រួសារ ត្រូវបានចោទថាជាជនក្បត់។ ជាបន្ថែមទៅលើនេះទៀតគឺថា កង្វះទីកន្លែងរស់នៅ ចំណីអាហារគ្រប់គ្រាន់ និងការងារធ្ងន់ធ្ងរបានធ្វើឲ្យអ្នកនៅទីក្រុងមួយចំនួនធំបាត់បង់ជីវិត ជាពិសេសកុមារ និងមនុស្សចាស់ជរា។ តើអ្វីដែលខ្ញុំបាននិយាយអម្បាញ់មិញនេះនោះគឺថា ធ្វើឲ្យលោកមានចំណាប់អារម្មណ៍អីទេ?

[១៤:១៦:៣៥]

**លោក ញ៉ែម សំណាង៖**

ម៉េចដែរអ៊ំមានការចាប់អារម្មណ៍ការអានរបស់ចៅក្រមអំមិញខ្លះ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ, ខ្ញុំមែនទែនទៅអង្កាល់ហ្នឹង អត់ជាព័ត៌មានគឺស្ដាប់តែវិទ្យុកម្ពុជាប្រជាធិបតេយ្យហ្នឹង។ ដូច្នោះ គឺដឹងតែដោយសារវិទ្យុហ្នឹង តែវិទ្យុហ្នឹងថាម៉េចវា-- ព្រោះវាអត់មានមកពីប្រភពណាទៀត វាមានតែប្រភពមួយហ្នឹងដូចជានិយាយថា ប្រជាជនមានហូបចុក ឆ្អែតឆ្អន់បីពេលអី ខ្ញុំជឿថាអ៊ីចឹង ប៉ុន្តែដល់ខ្ញុំទៅជូនគណៈប្រតិភូបរទេសមួយទៅសៀមរាប ខ្ញុំឃើញប្រជាជនស្គម រួចស្លៀកពាក់ខោអាវរយ៉េរយ៉ៃខ្ញុំចាប់អារម្មណ៍ពេលនុំងគឺថា ទេមិនស្រួលទេ រឿងហ្នឹង គឺមិនចេះតែដូចវិទ្យុនិយាយទេ។

[១៤:១៧:៥០]

**ស៖** ឥឡូវខ្ញុំអានកថាខណ្ឌមួយទៀត ដែលមានចំណងជើងថា "ការសម្លាប់រង្គាលបញ្ញាជន និងឥស្សរជន និងអ្នកការទូតត្រឡប់មកពីបរទេសវិញ"។ បញ្ញវន្តនៅបរទេសមួយចំនួនធំត្រូវបានស្វាគមន៍ការរំដោះភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ពួកគេបានត្រឡប់ចូលមកភ្នំពេញវិញដោយស្ម័គ្រចិត្តក្នុងគោលបំណងយកចំណេះវិជ្ជារបស់ខ្លួនមកបម្រើប្រទេសជាតិ។ តែគួរឲ្យអនិច្ចានៅពេលចុះមកដល់ព្រលានយន្តហោះពោធិ៍ចិនតុងវិញភ្លាម ពួកគេត្រូវកៀងប្រមូល ហើយបញ្ជូនទៅជំរំផ្សេងៗនៅទូទាំង

ប្រទេស ដើម្បីឲ្យតស៊ូទ្រាំនឹងការរងលំបាកវេទនាទាំងចិត្តផ្លូវកាយ ដូចជាប្រជាជន១៧ មេសាដែរ។ ជើងកាងទាំងបួន ប៉ុល ពត, នួន ជា, សុន សេន និង យុន យ៉ាត មិនដែលខ្វល់ ជូនដំណឹងទៅដល់ឯកឧត្តម អៀង សារី អំពីការមកដល់របស់ពួកប្រជាជនទាំងនោះទេ។

[១៤:១៨:៥៩]

ការងារធ្ងន់ធ្ងរជំងឺ និងខ្វះអាហារហូបចុកបានធ្វើឲ្យមនុស្សមួយចំនួនធំស្លាប់ ហើយមួយចំនួនទៀតត្រូវបានប្រហារជីវិតក្រោមការចោទប្រកាន់ថា ជនក្បត់ ជាភ្នាក់ងារ សេ.អ៊ី.អា និង កា.ហ្សេ.បេ ទៅតាមនិន្នាការរបស់ប្រទេសដែលពួកគេធ្លាប់រស់នៅ។ សូម្បីតែការមកដល់វិញរបស់ម្តាយក្មេក ឬបងប្អូនថ្លៃរបស់លោក អៀង សារី ក៏មិនត្រូវបានលាក់នឹងគាត់ដែរ។ នៅពេលក្រោយមកទៀត ប្អូនថ្លៃស្រីម្នាក់របស់គាត់គឺ ខៀវ ធារ័ត្ន ដែលជាបណ្ឌិតច្បាប់ត្រូវអ្នកយាមជំរំនៅតាខ្មៅ នៅភ្នំពេញច្របាច់កស្លាប់ដែរ។

សំណួរគឺថា តើអំណានទាំងអស់នេះៗគឺថា ធ្វើឲ្យលោកមានចំណាប់អារម្មណ៍អ្វីទេ?

**ឆ៖** បាទ, មែនទែនទៅ ខ្ញុំអត់បានដឹងទេអង្កាល់ដែរ-- ពីរឿងប្អូនថ្លៃ ឬក៏នេះនោះ ខ្ញុំអត់បានដឹងទេ។ គឺដូចខ្ញុំបានជម្រាបអ៊ីចឹង ថាប្រភពព័ត៌មាន មានតែមួយទេ មានតែវិទ្យុកម្ពុជាប្រជាធិបតេយ្យ។ តែវិទ្យុកម្ពុជាប្រជាធិបតេយ្យនិយាយថាម៉េច គឺថាយល់អ៊ីចឹង ទៅតាមអ៊ីចឹង អត់មានការវិភាគអីច្រើនទេ។

**ស៖** អ៊ីចឹងឯកសារហ្នឹង គឺថានិយាយអំពីព្រឹត្តិការណ៍មួយចំនួនទាក់ទងទៅនឹងការបោសសម្អាតឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៨ ហើយឯកសារនេះបញ្ចប់យ៉ាងដូច្នេះ។ ដោយមូលហេតុទាំងអស់នោះ គឺថាឃាតករបស់ប្រទេសកម្ពុជាមិនមែនអ្វីក្រៅពី ប៉ុល ពត នោះទេ។ ឧក្រិដ្ឋកម្មសង្គ្រាម មិនមែនអ្នកណាក្រៅផ្សេងពី ប៉ុល ពត នោះទេ គឺ ប៉ុល ពត នេះហើយ និងជាអ្នកហែហមមួយក្តាប់តូច ដូចជា នួន ជា, តាម៉ុក, សុន សេន ដែលហៅ ខៀវ, យុន យ៉ាត ហៅ អាត ដែលជាឃាតកសម្លាប់រង្គាលប្រជាជនកម្ពុជា ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរហូតដល់ពេលនេះ។ ដូច្នេះ ក្នុងស្ថានភាពដូច្នេះ ពួកគេត្រូវតែទទួលការកាត់ទោសប្រហារជីវិត។ តើលោកមានការកត់សម្គាល់អ្វីទេ? តើលោកធ្លាប់បានឮការនិយាយបែបនេះទេ? លោកមានការភ្ញាក់ផ្អើលអ្វីទេ?

**ឆ៖** ខ្ញុំអត់ដែលបានឮទេ។

[១៤:២២:១៦]

**ស៖** លោក ឡុង នរិន្ទ លោកបាននិយាយថា គឺថាលោកធានា ការពារដល់ព្រះវរបិតា នរោត្តម សីហនុ តើលោកអាចប្រាប់យើងបានទេថា តើមុខងាររបស់លោកនៅបរមរាជវាំងនោះ ស្អីទៅ?

**លោក ញ៉ែម សំណាង៖**

យល់ទេ អ៊ំយល់សំណួរទេ?

**លោក ឡុង នរិន្ទ៖**

រឿងខ្ញុំទៅនៅ--

**លោក ញ៉ែម សំណាង៖**

វាំងនោះ តើមុខងារអ៊ំធ្វើអ្វីដែរ នៅវាំង?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ពេលដែលខ្ញុំទៅនៅវាំងហ្នឹង គឺថាមានពីរនាក់ គឺថាលោក ឈន ហៃ ហើយនិងខ្ញុំ។ លោក ឈន ហៃ គាត់ទាក់ទងពីកន្លែងមួយទៅកន្លែងមួយ។ ឯខ្ញុំគឺថា ការពារព្រះករុណាហ្នឹង ធ្វើម៉េច មិនដឹងជារឿងអីទេ បានជាឲ្យខ្ញុំទៅការពារហ្នឹង គឺមានតែប៉ុន្មាននាក់ទេអង្គាល់ហ្នឹង? ក្រុមមិនដឹងឲ្យទៅនៅឲ្យការពារហ្នឹង គឺយាមយប់ យាមថ្ងៃ ខ្លាចក្រែងលោមាន សត្រូវ។

[១៤:២៤:០២]

**ស៖** នៅពេលដែលលោកការពារសម្តេច សីហនុ នោះ តើព្រះករុណា អាចដើរយាងទៅណាតាមចិត្តដែរឬទេ?

**ឆ៖** ព្រះករុណា អាហ្នឹងគឺថាលោកប្រុងទៅណា តាមរយៈលោក ឈន ហៃ ទេ មិនមែនខ្ញុំទេ។ ខ្ញុំគឺថាកុំឲ្យការពារសម្រាប់តែ បើលោកចេញទៅណា ខ្ញុំទៅតាមការពារប៉ុណ្ណឹង។

**ស៖** លោក ឡុង នរិន្ទ លោកត្រូវបានស្តាប់យកចម្លើយពីសំណាក់អ្នកស៊ើបអង្កេត ហើយសក្ខីកម្មរបស់កូដហ្នឹងគឺថា D71/3 ហើយនៅពេលស្តាប់យកចម្លើយរបស់លោកហ្នឹងនៅទំព័រទី៩ គេចោទសំណួរទៅកាន់លោកដូចតទៅនេះ៖ ហេតុអ្វីបានជាព្រះករុណាលាលែងពីតំណែង? តើព្រះអង្គមិនសប្បាយចិត្តអំពីរឿងអ្វីមួយ? លោកបានឆ្លើយយ៉ាងដូច្នេះ៖ ព្រះអង្គលាលែងពីតំណែងពីព្រោះព្រះអង្គពុំមានសិទ្ធិសេរីភាពក្នុងការយាងទៅទីណាទីណាតាមចិត្ត។ ដូច្នេះ ព្រះអង្គត្រូវធ្វើសំណើទៅដល់គណៈកម្មាធិការមជ្ឈិមទៅលោក ឈន ហៃ ហើយព្រះអង្គមិនមានសិទ្ធិទៅណាបាននោះទេ។

តើលោកបញ្ជាក់បានឬទេថា អ្វីដែលខ្ញុំទើបតែអាននេះពិតជាត្រឹមត្រូវ?

[១៤:២៥:៥៨]

**ឆ៖** អង្កាល់ពេលនុ៎ងគឺថា អារឿងហ្នឹងក៏ខ្ញុំគ្រាន់តែថា ព្រះករុណាលោកមានតែលោក ឈន ហៃ ទេដែលជាអ្នកនាំពាក្យរបស់លោកទៅសុំខាងមជ្ឈិមហ្នឹង។ ព្រោះម្ដងនោះ ព្រះករុណាលោកចេញទៅក្រៅវាំង ខ្ញុំតាមលោកទៅការពារឲ្យលោក-- ថ្វាយលោក ហើយឡានលោក សុន សេន គាត់ជិះឡានហ្ស៊ីបមក។ ដល់ខ្ញុំខ្លាចគ្រោះថ្នាក់ដល់ព្រះករុណា ខ្ញុំវាដៃឲ្យឈប់ ក៏គាត់អត់ឈប់ដែរ។ ជិះទៅវឹងទៅទៀតទៅ។ ដូច្នោះវាអ៊ីចឹង។

**ស៖** បើតាមលោកវិញ ថាតើការងាររបស់លោក គឺជាការងារជាអ្នកយាម ឬក៏ជាអង្គរក្សរបស់ព្រះករុណានោះ តើលោកទទួលបទបញ្ជាដើម្បីការពារព្រះអង្គ ឬក៏យ៉ាងណា?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

អត់ៗយល់។

**លោក ញ៉ែម សំណាង៖**

សំណួរថា តើលោកអ៊ំទទួលបទបញ្ជាមកការពារព្រះអង្គឬយ៉ាងម៉េច?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ, គឺថាខ្ញុំមកនៅវាំងហ្នឹងគឺត្រូវតែការពារព្រះករុណា ប៉ុណ្ណឹង។ គឺយប់ក៏យាម ថ្ងៃក៏យាមវាំងហ្នឹង គឺមិនឲ្យនរណាចូលមកផ្ដេសផ្ដាស់ទេ។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេ ដែលថានៅពេលដែលគេសួរយកចម្លើយពីលោកហ្នឹងនោះ សំណួរដូចតទៅនោះ៖ តើលោកបានឃើញ អៀង សារី ទៅកាន់ក្រសួង ប-៦ ដែលស្ថិតនៅច្រាំងចំរេះ ឬនៅកន្លែងផ្សេងទៀតនោះ? លោកបានឆ្លើយទៅសំណួរនឹងថា៖ គាត់ទៅនុ៎ងដើម្បីគ្រប់គ្រងពីការអប់រំនៅបឹងត្របែក។ មុននឹងទៅធ្វើការនៅប-១ គាត់ទទួលបន្ទុកខាងអប់រំនយោបាយ ពួកបញ្ញាជន ហើយនិងសមាជិករបស់ក្រសួងផ្សេងៗទៀត។

តើលោកអាចបញ្ជាក់បានទេថា នេះជាការត្រឹមត្រូវ?

[១៤:៣០:០៨]

**ឆ៖** អម្បាញ់មិញហ្នឹង គាត់សួរខ្ញុំថាម៉េច គាត់ថា--

**លោក ញ៉ែម សំណាង៖**

សុំសំណួរម្តងទៀត។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** នៅក្នុងពេលស្តាប់ចម្លើយលោក គេបានសួរសំណួរលោកដូចតទៅនេះ៖ តើលោកធ្លាប់ឃើញលោក អៀង សារី ទៅកន្លែងដែលស្ថិតនៅក្រោមឱវាទរបស់មន្ទីរប-១ ដែរឬទេ? ដូចជាឧទាហរណ៍ ដូចជាកន្លែងមួយដែលស្ថិតនៅច្រាំងចំរេះ ឬនៅកន្លែងណាផ្សេងទៀត? ហើយលោកបានឆ្លើយទៅវិញថា៖ គាត់បានទៅដើម្បីអប់រំនៅមន្ទីរបឹងត្របែកមុននឹងចូលទៅកាន់តំណែងប-១ ហើយគឺខ្ញុំសំដៅទៅដល់លោក អៀង សារី គឺគាត់ទទួលបន្ទុកក្នុងការអប់រំនយោបាយទៅលើពួកបញ្ញាជន ឬសមាជិកដែលស្ថិតនៅជាសមាជិកក្រសួងផ្សេងៗទៀត។

តើលោកពិតជាបានឆ្លើយអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ មែនទែនទៅ មិនដឹងជាគាត់ទទួលអប់រំអ្នកណាខ្លះ ដែលខ្ញុំដឹង គឺដឹងតែអ្នកដែលនៅប-១ហ្នឹង ដល់ពេលគាត់បើកវគ្គគេចូលទាំងអស់គ្នាហ្នឹង ចូលស្តាប់ទាំងអស់គ្នាហ្នឹង ប៉ុណ្ណឹង។

**លោក ញ៉ែម សំណាង៖**

អ៊ំ លោកចៅក្រមសួរថា គ្រាន់តែឲ្យឆ្លើយទៅនឹងអ្វីដែលលោកចៅក្រមបានអាន ដែលអ៊ំបានឆ្លើយនៅជាមួយនឹងក្រុមស៊ើបអង្កេតហ្នឹង ថាតើអ៊ំបានឆ្លើយអ៊ីចឹងមែនដែរឬទេ? អ៊ីចឹងណាអ៊ំ?

**លោក ឡុង នរិន្ទ៖**

ឆ្លើយថាម៉េច ថាគឺទៅអប់រំនៅបឹងត្របែកអីហ្នឹង?

[១៤:៣២:១២]

**លោក ញ៉ែម សំណាង៖**

បាទៗ។

**លោក ឡុង នរិន្ទ៖**

**ឆ៖** ពីព្រោះអ្នកដែលនៅបឹងត្របែកហ្នឹង--

**ស៖** បាទ ប៉ុន្តែលោក ឡុង នរិន្ទ គឺជាការ--

**ឆ៖** ការបរទេស ប៉ុន្តែគេទៅធ្វើការងារពលកម្ម ដើម្បីកសាងខ្លួន។

[១៤:៣២:៥៩]

**ស៖** តើលោក អៀង សារី បានចូលទៅផ្ដល់វគ្គអប់រំអ្វីនៅមន្ទីរបឹងត្របែកដែរឬទេ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយឥឡូវហ្នឹង។ ព្រោះបីបួនឆ្នាំទៅហើយ ដប់ឆ្នាំឬឆ្ងាយហើយ។

**ស៖** នៅក្នុងការស្ដាប់ចម្លើយនេះដដែល គេសួរសំណួរលោកពាក់ព័ន្ធទៅនឹងការចាប់ខ្លួនមនុស្ស នៅក្នុងមន្ទីរប-១។ គេបានសួរសំណួរលោកថា៖ តើអ្នកណាជាអ្នកចេញបញ្ជា ហើយតើអ្នកណាជាអ្នកបញ្ជូនបញ្ជាទាំងអស់នោះ? ហើយលោកបានឆ្លើយដូចតទៅនេះ៖ គឺបញ្ជាចេញមកពីគណៈមជ្ឈិម គឺប៉ុល ពត ហើយបញ្ជានេះ គឺបញ្ជូនទៅមន្ទីរស-២១ បន្ទាប់មកពួកជីវពលនៅមន្ទីរស-២១ បានមករកមនុស្ស ដោយផ្ទាល់នៅមន្ទីរប-១ ដោយសួរថា តើអ្នកដែលត្រូវចាប់ខ្លួនហ្នឹងនៅកន្លែងណា? បន្ទាប់មកពួកគាត់បានទៅជួបអ្នកទាំងនុ៎ង ហើយបានបញ្ជាក់ថា អង្គការបានបញ្ជាឲ្យពួកគេទៅធ្វើការអប់រំ ហើយចាប់ពីពេលនោះមក គឺគេមិនដែលឃើញពួកអ្នកទាំងអស់នោះត្រឡប់មកវិញទេ។ ឧទាហរណ៍ដូចអ្នកនៅមន្ទីរប-១ ដែលទំនាក់ទំនងជាមួយ កុយ ធួន ហើយនិងមួយទៀតឈ្មោះ អ៊ុំ ជុន។ ហើយនៅមន្ទីរប-១ នេះ គឺគាត់ប្រព្រឹត្តអំពើអាក្រក់ដែលត្រូវបានគេរិះគន់នៅក្នុងក្រុមគាត់ ដូច្នេះគេក៏ចាប់ខ្លួនគាត់។ ហើយប្រសិនបើប្រធានគាត់មិនបានរៀបរាប់ទៅកាន់ថ្នាក់លើទេ គឺមិនអីទេ។

តើលោកមានចាំពីការដែលលោកបញ្ជាក់បែបនេះទៅកាន់អ្នកដែលសួរសំណួរលោកទេ?

**ឆ៖** ខ្ញុំអត់យល់ទេ។

**លោក ញ៉ែម សំណាង៖**

អ្វីដែលលោកចៅក្រមនិយាយអំមិញ គឺជាការសន្ទនារវាងអ៊ំ ហើយនិងអ្នកស៊ើបអង្កេតកាលពីឆ្នាំ ២០០៧ ណាអ៊ំ។

**លោក ឡុង នរិន្ទ៖**

បាទ។

**លោក ញ៉ែម សំណាង៖**

ហ្នឹងហើយ! ហើយតាមអ្វីដែលលោកចៅក្រមនិយាយហ្នឹង អ៊ំបានចាំទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

អត់បានចាំទេ ភ្លេចហើយ។

**លោក ញ៉ែម សំណាង៖**

ជម្រាបលោកចៅក្រម កូនប្រុសរបស់សាក្សី និងសាក្សីសុំពេលសម្រាកលោកប្រធាន។

[១៤:៣៥:៥០]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណដោយសារ-- អរគុណលោក ឡុង នរិន្ទ។ ដោយសារពេលក៏សមល្មមនឹងសម្រាកដែលហើយ។ ដូច្នេះអង្គជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះម្ភៃនាទី សូមអញ្ជើញចូលមកវិញ ដើម្បីបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥៥ នាទី)*

[១៤:៥៦:០៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ជម្រាបសួរលោក ឡុង នរិន្ទ។ លោក ឡុង នរិន្ទ ស្តាប់បានទេ?

**លោក ឡុង នរិន្ទ៖**

បាទ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកាទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ។

សូមអញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

[១៤:៥៦:៤៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ខ្ញុំគ្មានសំណួរអីផ្សេងទៀតដែលត្រូវចោទសួរទៅសាក្សីទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រមមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទេ? បាទ បើមិនមានទេ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្តីជនជាប់ចោទ ដើម្បីមានឱកាសក្នុងការសួរសំណួរ

ទៅកាន់សាក្សីរូបនេះ។ ហើយជាដំបូងនេះ សូមផ្តល់វេទិកាទៅសហមេធាវីការពារក្តីលោក នួន ជា មុនគេ។

សូមអញ្ជើញប្រសិនបើមានសំណួរ!

[១៤:៥៧:៤៦]

**លោក សុន អរុណ៖**

ខ្ញុំ សុន អរុណ មេធាវីការពារលោក នួន ជា សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** ជាបឋមខ្ញុំសូមសួរទៅលោក នរិន្ទ ក្នុងឋានៈលោកជាបញ្ញាជនខ្មែរម្នាក់ដែលមានជីវិតរស់នៅរហូតសព្វថ្ងៃ ហើយបាន-- លោកបានចូលប្រឡូកក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលមានមុខងារជាមន្ត្រីជាន់ខ្ពស់ ឬកម្មាភិបាលនៅក្នុងសម័យនោះដែរ។

ពេលលោកចេញពីឆេកូ មកប្រទេសកម្ពុជា លោកត្រូវសំណាក់នៅក្រុងប៉េកាំងមួយរយៈពេលជួយធ្វើការជាមួយ ហ្វុង មានន័យថា រណសិរ្សរួបរួមជាតិកម្ពុជា ក្នុងនោះមានរាជរដ្ឋាភិបាលមួយបង្កើតឡើងហៅថា “ហ្គ្រុង” ដោយអតីតព្រះមហាក្សត្រ នរោត្តម សីហនុ ក្នុងឆ្នាំ១៩៧០ រាជរដ្ឋាភិបាលនេះ នៅក្រៅប្រទេស គឺក្រុងប៉េកាំង ប្រជាមានិត-- រឿងនេះពិតជាអ៊ីចឹងមែនឬអត់? សូមលោក នរិន្ទ ឆ្លើយ។ លោកស្តាប់ខ្ញុំបានទេ?

[១៤:៥៩:២៧]

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំឮហើយ ប៉ុន្តែ--

**ស៖** ខ្ញុំសូមអានម្តងទៀត យ៉ាងយឺតៗ សំណួរខ្ញុំវែងបន្តិច ប៉ុន្តែលោកអាចឆ្លើយខ្លីៗបានហើយ។ ពេលលោកបានទៅសិក្សានៅប្រទេស ឆេកូ រួចមក ត្រឡប់មកប្រទេសកម្ពុជាវិញលោកត្រូវមកឆ្លងកាត់ក្រុងប៉េកាំង ត្រូវសំណាក់នៅក្រុងប៉េកាំងប្រទេសចិនមួយរយៈ ដើម្បីជួយធ្វើការជាមួយនឹងហ្វុងគេហៅថារណសិរ្សរួបរួមជាតិកម្ពុជា ក្នុងនោះមានរាជរដ្ឋាភិបាលមួយបង្កើតឡើងហៅថា “ហ្គ្រុង” ដោយអតីតព្រះមហាក្សត្រនរោត្តម សីហនុ ក្នុងឆ្នាំ១៩៧០។ រាជរដ្ឋាភិបាលនេះនៅក្រៅប្រទេស

គឺក្រុងប៉េកាំងប្រទេសចិនប្រជាមានិត រឿងនេះពិតមែនថាអ៊ីចឹងទេ បើតាមលោកដឹង?

**លោក ញ៉ែម សំណាង៖**

ម៉េចដែរលោកអ៊ំ?

**លោក ឡុង នរិន្ទ៖**

សួរគេថាម៉េច?

**លោក ញ៉ែម សំណាង៖**

អ្វីដែលលោកមេធាវីអានអម្បាញ់មិញនេះអ៊ំបានស្តាប់ទេ? ហើយលោកមេធាវីសួរថា តើអ៊ំ តើពិតជាដូចអ្វីដែលគាត់បានអានហ្នឹងមែន ឬក៏អត់?

**លោក ឡុង នរិន្ទ៖**

អ៊ំ។

[១៥:០១:00]

**លោក ញ៉ែម សំណាង៖**

តើអ៊ំចាប់បានអ្វីដែលមេធាវីអានទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ, ខ្ញុំមកពីក្រៅមក មកចូលប៉េកាំង ហើយបានចេញពីប៉េកាំងតមកទៀត--

**ស៖** សំណួរខ្ញុំខ្លី គឺត្រឹមត្រូវអ៊ីចឹងហើយ។ ខ្ញុំសុំសួរតទៅទៀត លុះក្រោយមកត្រូវបានមកធ្វើការនៅក្រុងហាណូយជាមួយនឹងអ្នកស្រី អៀង ធីរិទ្ធ គឺធ្វើខាងវិទ្យុ នៅឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ រឿងនេះពិតទេ?

[១៥:០១:៥0]

**ឆ៖** បាទ, ខ្ញុំមកពីប៉េកាំងមក មកចូលធ្វើការនៅវិទ្យុនៅហាណូយ។

**ស៖** បាទ, អរគុណ។ លុះក្រោយមកទៀត រាជរដ្ឋាភិបាល ហ្គ្រុង បានបញ្ជូនលោកឲ្យមកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៧៣ មកដល់ស្ទឹងត្រង់ខេត្តកំពង់ចាមនៃប្រទេសកម្ពុជា នៅពេលដែលលោកបានចេញពីហាណូយ មកប្រទេស-- កាត់តាមប្រទេសវៀតណាម-- សុំទោស១ ពេលដែលលោកចេញពីហាណូយប្រទេសវៀតណាម លោកបានមកតាមផ្លូវលំហូជីមិញ ដើម្បីមកប្រទេសកម្ពុជា រឿងនេះពិតជាអ៊ីចឹងទេ?

**ឆ៖** ខ្ញុំចេញពីហាណូយមកវិញ គឺមកកម្ពុជា មកចូលនៅស្ទឹងត្រង់ នៅប-១៥។

**ស៖** ប៉ុន្តែពេលនោះលោកមកតាមផ្លូវណា? មកតាមផ្លូវលំហូជីមិញ ឬមកតាមយន្តហោះ?

[១៥:០៣:១០]

**ឆ៖** ខ្ញុំមកតាមផ្លូវហូជីមិញ។

**ស៖** អរគុណ។ នៅពេលដែលលោកមកពីហាណូយ ចូលប្រទេសកម្ពុជាមានគ្នាប៉ុន្មាននាក់?

**ឆ៖** ទេ ខ្ញុំមិនចាំថាប៉ុន្មាននាក់ទេអង្កាល់ហ្នឹង។

**ស៖** មានច្រើនទៀតនែ៎?

**ឆ៖** មិនច្រើនប៉ុន្មានទេ។

**ស៖** សូមអរគុណ។ លោកអាចជម្រាបអង្គសវនាការបានទេថា ផ្លូវលំហូជីមិញនេះ ជាផ្លូវមួយបើតាមលោកស្មានទៅ ជាផ្លូវមួយសម្រាប់គមនាគមន៍ធម្មតា សម្រាប់ដឹកទំនិញចុះឡើង ដឹកមនុស្សចុះឡើង ឬក៏ផ្លូវសម្រាប់ជាយុទ្ធសាស្ត្រៗសង្គ្រាមផ្លូវហូជីមិញ ដែលប្រទេសវៀតណាមបានសាងសង់ហើយមក?

**លោក ញ៉ែម សំណាង៖**

យល់ទេអ៊ំសំណួរ?

**លោក ឡុង នរិន្ទ៖**

អត់យល់ទេ សួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

លោកមេធាវីសួរថា ផ្លូវដែលអ៊ំអញ្ជើញមកហ្នឹងជាផ្លូវ គេដឹកទំនិញចរាចរណ៍ធម្មតា ឬមួយក៏ជាផ្លូវយុទ្ធសាស្ត្រសង្គ្រាម?

**លោក ឡុង នរិន្ទ៖**

**ឆ៖** មែនទែនជាផ្លូវយុទ្ធសាស្ត្រសង្គ្រាម។

[១៥:០៤:៥០]

**ស៖** បាទ, សូមអរគុណណាស់ ឆ្លើយខ្លីៗអ៊ីចឹងខ្ញុំចង់បាន។ ពេលដែលលោកអញ្ជើញមកតាមផ្លូវលំហូជីមិញនោះ លោកបានឃើញមានស្នាមទម្លាក់ មានស្នាមគ្រាប់បែកទម្លាក់ពីយន្តហោះអាមេរិកាំង

នៅតាមផ្លូវហូរហែមកអ៊ីចឹងទេ? ឬម៉្យាងទៀត មានឃើញទិដ្ឋភាពទូទៅ ឧទាហរណ៍ដូចជាមនុស្សស្លាប់ ឬក៏បាក់បែកខូចខាតអីទៅតាមផ្លូវលំហូជីមិញហ្នឹងមានច្រើនទេ?

**ឆ៖** អាហ្នឹងខ្ញុំអត់បានឃើញទេ។ ឃើញតែរណ្ដៅគ្រាប់បែកដែលផ្ទុះ។

**ស៖** សូមអរគុណ។ លោកបានឆ្លើយជម្រាបចៅក្រមស៊ើបអង្កេត កាលពីថ្ងៃ២០ ខែមេសា ១៩៧៥ ក្រោយពេលរំដោះភ្នំពេញបានប៉ុន្មានថ្ងៃ លោក នរិន្ទ បានមកដល់ភ្នំពេញ។ ពេលលោកមកដល់ភ្នំពេញ លោកនៅរស់នៅក្រោមស្ពានជ្រោយចង្វាពេលនោះ លោករស់របៀបម៉េចនៅក្រោមស្ពានជ្រោយចង្វា លោកអាចមានប្រសាសន៍បន្តិចបានទេ? ខ្លីបានហើយ។

[១៥:០៦:៣៦]

**លោក ញ៉ែម សំណាង៖**

យល់ទេអ៊ំ? យល់សំណួរទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** អត់យល់ទេ។

**ស៖** ជួយពន្យល់ផង។

**លោក ញ៉ែម សំណាង៖**

ពេលដែលអ៊ំអញ្ជើញមកវិញហ្នឹង ហើយមកបានមករស់នៅក្រោមស្ពានជ្រោយចង្វា តើស្ថានភាពអ៊ំរស់យ៉ាងដូចម្ដេច? លោកមេធាវីចង់ឲ្យអ៊ំពន្យល់។

**លោក ឡុង នរិន្ទ៖**

**ឆ៖** រស់នៅក្រោមស្ពានជ្រោយចង្វាហ្នឹង គឺគ្រាន់តែក្រាលកន្ទេលហើយក៏សម្រាកទៅ ហើយអត់មានធ្វើការងារអីទេ។

**ស៖** សុំសួរបន្ថែម។ ចុះទិដ្ឋភាពទូទៅនៅភ្នំពេញ លោកឃើញបែបយ៉ាងម៉េច? ទិដ្ឋភាពទូទៅនៅទីក្រុងភ្នំពេញ។ អាហ្នឹងថ្ងៃ២០ ខែមេសា ១៩៧៥ មានន័យថា ក្រោយដែលគេជម្លៀសប្រជាជនចេញពីទីក្រុងហើយ ពីភ្នំពេញហើយ។ លោកឃើញទិដ្ឋភាពនៅហ្នឹងយ៉ាងម៉េច?

[១៥:០៨:០៧]

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអ៊ំ?

**លោក ឡុង នរិន្ទ៖**

អត់យល់ទេ។ គាត់សួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

សូមលោកមេធាវីសួរម្តងទៀត។ លោកមេធាវីអធ្យាស្រ័យ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមអរគុណ។ សូមទោស។ ខ្ញុំសូមសួរសាជាថ្មី ថាពេលដែលលោកមកដល់ភ្នំពេញ បើតាមខ្ញុំមើលក្នុងឯកសារថ្ងៃ២០ ខែមេសា ឆ្នាំ១៩៧៥ ពេលហ្នឹងមានន័យថា ភ្នំពេញខ្មែរក្រហមបានរំដោះ បានជម្លៀសប្រជាជនចេញសឹងតែអស់ហើយ ខ្ញុំក៏មិនបាននៅជាមួយដែរ។ ប៉ុន្តែពេលហ្នឹងលោកឃើញទេសភាពទូទៅនៅទីក្រុងភ្នំពេញហ្នឹងរបៀបណា? មានមនុស្សទេ? គ្មានមនុស្សទេ ឬក៏សកម្មភាពរបៀបម៉េច?

**ឆ៖** ក្នុងពេលហ្នឹងគឺថា ខ្ញុំឃើញតែមនុស្សដើររពុយៗ ហើយខ្ញុំអត់សួរផង គេទៅណាអីអត់សួរទេ។

**ស៖** លោកមានប្រសាសន៍ថា ដើររពុយៗហ្នឹងយ៉ាងម៉េច រពុយៗសូមមានប្រសាសន៍ឲ្យបានចំបន្តិចមករពុយហ្នឹងមានន័យថា អស់មនុស្ស ជិតអស់មនុស្សហើយ ឬក៏មនុស្សនៅមានធម្មតា?

**ឆ៖** ពីព្រោះនៅមានមនុស្សដើរនៅឡើយ។ ខ្ញុំដើរចេញពី-- មិនដឹងជាគេដើរទៅណាទៀត ហើយខ្ញុំអត់សួរគេទេ ពីព្រោះពេលហ្នឹងគឺ ដឹងច្រើនពេកក៏មានបញ្ហាដែរ។ បើអត់ដឹងស្រួល។

**ស៖** ខ្ញុំមិនសួរថាលោកដឹង ឬមិនដឹងទេ។ ខ្ញុំសួរលោកថា លោកឃើញទិដ្ឋភាពទូទៅនៅទីក្រុងភ្នំពេញហ្នឹង ចង់បញ្ជាក់ថា ពេលដែលលោកមកក្រោយគេជម្លៀសចេញពីភ្នំពេញហើយហ្នឹង លោកឃើញរបៀបណា? ចង់បានសម្តីថាលោកឃើញរបៀបណា?

**ឆ៖** នៅពេលដែលខ្ញុំនៅក្រោមស្ពានជ្រោយចង្វាហ្នឹងគឺថា ពេលហ្នឹងមនុស្សដើរចេញហ្នឹងមិនដឹងដើរទៅណាទេ។ ដូច្នេះអាចគេជម្លៀសហើយ ប៉ុន្តែមិនមែនបានន័យថាអស់ពីភ្នំពេញនៅឡើយទេ ពីព្រោះដល់ខ្ញុំទៅនៅគេយកខ្ញុំពីក្រោមស្ពានជ្រោយចង្វាទៅនៅ ប-១ នៅមានមនុស្សដើរតាមមុខក្រសួងហ្នឹងទៅក្រៅទៀត ទៅក្រៅភ្នំពេញទៀត។

**ស៖** ខ្ញុំសូមជម្រាបលោកថា ពេលដែល មុននឹងជម្លៀសប្រជាជន បើតាមស្ថិតិមិនជាផ្លូវការទេ មានប្រហែលជាពីរលានជាង ទីក្រុងភ្នំពេញ ដល់ពេលជម្លៀស ពេលហ្នឹងមានណែនណាន់តាន់តាប់

ហើយភ្នំពេញ ហើយពេលដែលលោកមកនោះ ក្រោយប៉ុន្មានថ្ងៃលោកមកដល់ភ្នំពេញនេះ? តើលោកឃើញទេសភាពហ្នឹងរបៀបម៉េចនៅក្នុងក្រុងភ្នំពេញហ្នឹង ជិតអស់មនុស្សហើយ ឬក៏អស់ នៅសល់មួយៗ ឬក៏ថានៅមនុស្សនៅធម្មតា? គ្រាន់ជម្រាបបញ្ជាក់ម្តងទៀតថា ប្រជាជននៅទីក្រុងភ្នំពេញមានប្រហែលជាងពីរលាននាក់មុននឹងខ្មែរក្រហមជម្លៀសប្រជាជនចេញ។ លោកយល់សំណួរខ្ញុំទេ?

[១៥:១១:១៩]

**ផៈ** ខ្ញុំមកនៅ ប-១ ខ្ញុំអត់មានបានចេញទៅណាទេ។ ដូច្នោះ ខ្ញុំអត់ដឹងថា មនុស្សមាននៅសល់នៅភ្នំពេញដែរឬក៏មិនសល់។ ប៉ុន្តែខ្ញុំឃើញមនុស្សដើរចេញទៅក្រៅហ្នឹងរពុយៗហ្នឹងទៀត។

**សៈ** ពេលដែលលោកបានចូលធ្វើការនៅក្នុង ប-១ លោកបានឆ្លើយម្តងរួចទៅហើយ ប៉ុន្តែខ្ញុំនឹងសួរបញ្ជាក់បន្ថែមបន្តិចទៀត ការងាររបស់លោកនៅក្នុងការិយាល័យ ប-១ នុ៎ង មុខងារលោកធ្វើជាអ្វី?

**ផៈ** ជាអ្នកវ៉ៃម៉ាស៊ីនអង្គុលីលេខ។

**សៈ** ពេលដែលលោកចូលមកដល់ភ្នំពេញហ្នឹង ថ្នាក់លើបានបង្គាប់បញ្ជាឲ្យលោក ឬក៏អនុញ្ញាតឲ្យលោកធ្វើការនៅក្នុងការិយាល័យ ប-១ ហ្នឹង វ៉ៃអង្គុលីលេខហ្នឹង ដោយបង្ខំលោក ឬក៏ដោយលោកស្ម័គ្រចិត្ត?

**ផៈ** គ្មាននរណាបង្ខំទេ គឺថាពេលហ្នឹងមាននីរសារ ទៅដឹកខ្ញុំពីក្រោមស្ពានជ្រោយចង្វាហ្នឹងមកដាក់នៅ ប-១ ហ្នឹងតែម្តង។

**សៈ** ពេលនុ៎ងលោកចូលធ្វើការនៅក្នុង ប-១ ហ្នឹងលោកឃើញមានភាពច្របូកច្របល់ទេ ប្រជាជនអី មានរត់ចុះរត់ឡើង ឬក៏យ៉ាងម៉េចទេ?

**ផៈ** ហ្នឹងខ្ញុំ ពីព្រោះខ្ញុំមកនៅ ប-១ គឺនៅតែក្នុងបរិវេណ ប-១ ហ្នឹង អត់ទៅណាទេ។

**សៈ** ប៉ុន្តែមនុស្សធ្វើការហ្នឹង អ្នកធ្វើការនៅក្នុងប-១ ទាំងប៉ុន្មានហ្នឹង តើច្របូកច្របល់ទេ ព្រោះអីពេលហ្នឹងគេកំពុងជម្លៀសខ្លួន?

**ផៈ** មានអ្នកខ្លះគេទៅធ្វើការនៅច្រាំងចំរេះ អ្នកខ្លះគេទៅធ្វើការនៅបឹងត្របែកហ្នឹង។

**សៈ** ពេលនោះម្ហូបអាហារ ចំណីសម្រាប់ចិញ្ចឹមជីវិតមានគ្រប់គ្រាន់ទេ?

[១៥:១៣:៣៧]

**ផៈ** នៅប-១ គឺថាមានគ្រប់គ្រាន់ដែរ មានបីពេល គឺបបរ បាយថ្ងៃត្រង់ ហើយនិងបាយល្ងាច។

**ស៖** លោកជាបញ្ញាជនម្នាក់មកពីប្រទេសក្រៅ ពេលដែលគេជម្លៀសខ្លួនចេញពីទីក្រុង លោកជាជន គេហៅប្រជាជនថ្មី កាលហ្នឹងខាងខ្មែរក្រហមមានដេញលោក ឬជម្លៀសលោកឲ្យចេញពីទីក្រុងជាមួយគេជាមួយឯងទេ?

**ផ៖** គាត់សួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

អ៊ំជាបញ្ញាជនមួយថ្មី ហើយតើខាងខ្មែរក្រហមមានដេញលោកអ៊ំចេញពីកន្លែងធ្វើការហ្នឹងទេ?

**ផ៖** អត់ទេ អត់មានទេ។

**ស៖** អត់មាន។ សូមអរគុណណ៎ា។

ពេលដែលលោកធ្វើការបានមួយរយៈ លោកបានទទួលងារជាអនុកងការពារព្រះនរោត្តម សីហនុនៅក្នុងវាំង។ ពិតទេរឿងហ្នឹង? លោកស្តាប់បានទេ?

[១៥:១៥:០៩]

**ផ៖** បាទ, គឺកាលហ្នឹង ខ្ញុំទៅតែមួយរយៈ ហើយត្រឡប់មក ប-១ វិញទេ។ ធ្វើការនៅ ប-១ ហ្នឹងឯង។

**ស៖** ការពារលោកបានប៉ុន្មានឆ្នាំ? ប៉ុន្មានខែ? រយៈពេលប៉ុន្មានទាន?

**ផ៖** ទៅនៅវាំងដូចជា-- ប្រហែលប្រាំមួយខែប៉ុណ្ណឹងឯង បាទ។

**ស៖** ពេលដែលលោកទទួលមុខងារជាកងអនុប្រធានកងការពារ បន្ទាប់ពីលោក ឈន ហៃ ណ៎ា ផ្នែកកងការពារ។ លោក នរិន្ទ និយាយបានទេ ថាតើលោកដឹងថា សម្តេច ព្រះនរោត្តម សីហនុ លោកមានមុខងារជាអ្វីទេ ពេលដែលលោកធ្វើកងការពាររបស់ព្រះអង្គ? ព្រះអង្គសម្តេច នរោត្តម សីហនុ មុខងារលោកជាអ្វីនៅក្នុង--

**ផ៖** ខ្ញុំដឹង គឺថាលោកជាប្រមុខ-- ប្រធានគណៈប្រធានរដ្ឋ។

**ស៖** កាលហ្នឹង លោកមិនទាន់លាលែងចេញពីប្រមុខរដ្ឋនៅឡើយទេ មិនអ៊ីចឹង? កាលលោកនៅការពារព្រះអង្គ? ព្រោះអីលោក សម្តេច នរោត្តម សីហនុ លោកលាលែងចេញពីប្រមុខរដ្ឋនៃរដ្ឋាភិបាលរួបរួមជាតិ មានន័យថាពីហ្រ្គុង? ហើយពេលហ្នឹង លោកទៅការពារលោកក្នុងវាំង លោកមានអំណាចទេ ពេលនុ៎ង? លោកមានអំណាច លោកអាចប្រើធ្វើអីបានដូចលោកនៅជាប្រមុខរដ្ឋសម័យសង្គមរាស្ត្រនិយមទេ?

**ឆ៖** ខ្ញុំ ចំពោះព្រះករុណា គឺថាដល់លោកលាលែងទៅ លោកទៅនៅប៉េកាំង ហ្នឹងមិនដឹងជាលោកទាក់ទង-- ព្រះករុណាលោកទាក់ទងជាមួយនឹងការបរទេសហ្នឹង ជាមួយនឹងកម្ពុជាប្រជាធិបតេយ្យហ្នឹង យ៉ាងម៉េចទេ។ ប៉ុន្តែលោកជាប្រធាន គណៈប្រធានរដ្ឋ។

**ស៖** កាលពីហ្នឹង ដូចជាមិនទាន់ដាក់ឈ្មោះគណៈប្រធាននៃគណៈប្រធានរដ្ឋនៅឡើយទេ។ ពីព្រោះអី នៅក្នុងរដ្ឋាភិបាលរួបរួម-- រាជរដ្ឋាភិបាលរួបរួមជាតិ ដែលលោកបង្កើតតាំងពីឆ្នាំ១៩៧០ មកម្ល៉េះ។

**ឆ៖** បាទ។

[១៥:១៧:៤៣]

**ស៖** យល់ស្របតាមខ្ញុំទេ? បើអ៊ីចឹង មានន័យថា--

**ឆ៖** ទៅប៉េកាំងទៅហើយ គឺខ្ញុំអត់មានការពារអីលោកទៀតទេ។ កាលហ្នឹង គឺចិន គេការពារហើយ។

**ស៖** បើលោកមិនការពារទេ ខ្ញុំសួរបន្ត នៅក្នុងសំណួរសាកសួរ សួរឆ្លើយរបស់ចៅក្រមស៊ើបអង្កេតនៅឯកសារលេខ D91/3 ក្នុងហ្នឹង មាននិយាយថាលោកបាន លោក នរិន្ទ ហ្នឹង មានមួយថ្ងៃអំមិញ ចៅក្រមបានសួរម្តងហើយ ប៉ុន្តែឥឡូវលោកឆ្លើយថាមិនដឹងទេ។ រឿងហ្នឹង ខ្ញុំសួរម្តងទៀត។ លោកថា លោកបានឃើញព្រះអង្គយាងចេញក្រៅវាំង ហើយពេលហ្នឹង លោកដើរការពារលោកព្រះអង្គហើយឃើញឡាន សុន សេន បើកឡានអាហ្ស៊ីប កាត់មុខព្រះអង្គ ដោយគ្មានញញើត។ រឿងហ្នឹង លោកបានមានប្រសាសន៍ មាននិយាយខ្លួនឯងដែរ? អ៊ីចឹងទេ?

**ឆ៖** អាហ្នឹង គឺថាខ្ញុំឃាត់ឡាន សុន សេន ហ្នឹង ប៉ុន្តែអត់ឈប់ទេបាទ អាន៎ុង។

**ស៖** បាទ, អ៊ីចឹងបានខ្ញុំចង់សួរថា ពេលដែលលោកនៅក្នុងវាំង លោកមានអំណាច ឬអត់? ពីព្រោះអីនៅពេលដែលលោកចប់ឆ្នាំ១៩៧៩ ហើយ ចូលឆ្នាំ៨០អី លោកចេញក្រៅហើយ ចេញក្រៅប្រទេស លោកបានប្រកាសថា ខ្មែរក្រហមដាក់គុកលោក។ រឿងហ្នឹង លោកមានដឹងទេ?

**ឆ៖** ព្រះករុណាលោកប្រកាសអ៊ីចឹងហើយ។

**ស៖** អ៊ីចឹង បានន័យថា លោកបានឮដែរ? បើលោកបានឮ ហើយបានដឹងផង។ អ៊ីចឹង ខ្ញុំសួរថាលោកមានអំណាចទេ ពេលនុ៎ង ពេលដែលលោកនៅក្នុងនុ៎ង? ខ្ញុំសួរដដែលៗ បីដងហើយ។ បើសិនលោក នរិន្ទ មិនយល់ សូមឲ្យប្អូនហ្នឹងជួយពន្យល់ផង សំណួររបស់ខ្ញុំ។

[១៥:២០:០៥]

**លោក ញ៉ែម សំណាង៖**

លោកមេធាវីចង់មានន័យថា តើសម្តេចព្រះនរោត្តម សីហនុ នៅអំឡុងពេលដែលអ៊ំការពារហ្នឹង ថាតើព្រះអង្គមានអំណាចដែរឬទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** នៅពេលដែលលោក ដែលខ្ញុំនៅការពារព្រះករុណាហ្នឹង គឺថាលោកអត់មានអំណាចអីទេ។ អំណាច គឺនៅលើមជ្ឈិមបក្សនោះទេ មែនទែននៅលើ ប៉ុល ពត ទេ។ ប៉ុន្តែខ្ញុំក៏អត់មានបញ្ហាទាក់ទងពីរឿងហ្នឹង គឺអត់មានទេ។ ក៏រឿងហ្នឹង គឺថាមានអ្នកផ្សេងទៀត កាលណាព្រះករុណា លោកចង់យាងទៅណាអី ត្រូវប្រាប់អ្នកផ្សេងហ្នឹងគេនាំទៅជួប នាំទៅប្រាប់--។

[១៥:២០:៥៩]

**ស៖** ពីថ្ងៃបន្តិច មុននេះបន្តិចលោកបាន-- លោក នរិន្ទ បានឆ្លើយទៅខាងចៅក្រមហើយ គឺលោក ឈន ហៃ គាត់អ្នកនាំសារ នាំពាក្យថាព្រះអង្គចង់យាងទៅណា ចង់ធ្វើអី មិនអ៊ីចឹងហ៎?

**ឆ៖** បាទ។

**ស៖** លោកនៅចាំទេថា សម្តេចនរោត្តម សីហនុ លាលែងចេញប្រមុខរដ្ឋនៃរដ្ឋាភិបាល*ហ្គ្រុង* នៅពេលណាទេ?

**ឆ៖** ខ្ញុំកាលហ្នឹងគ្រាន់តែដឹងអ៊ីចឹង ប៉ុន្តែវាអត់មានមុខងារអីនៅក្នុងហ្នឹង។

**ស៖** ខ្ញុំមិនសួរពីមុខងារលោកទេ។ ខ្ញុំសួរថា លោកបានដឹងទេ? ហើយចាំថានៅថ្ងៃណា ខែណា ឆ្នាំណាទេ?

**ឆ៖** អត់ទេ, អត់ចាំទេ។

**ស៖** បាទ អរគុណ។ ហើយដឹងថាហេតុអ្វីបានជាលោកលាលែងចេញពីមុខតំណែងប្រមុខរដ្ឋនៃរាជរដ្ឋាភិបាល ហ្គ្រុង ទេ?

**ឆ៖** ពីព្រោះ-- អ្ហ៎! ខ្ញុំមិនដឹងទេអារឿងហ្នឹង គឺថាទាល់តែសួរព្រះករុណាផ្ទាល់។

**ស៖** រឿងមួយទៀត។ ពេលលោកតា នួន ជា គាត់បានជម្រាបអង្គសវនាការម្តងរួចហើយពីព្រឹកមិញថា ព្រះករុណាបានអំពាវនាវឲ្យបងប្អូនប្រជាជនខ្មែរចូលព្រៃម៉ាគី ដើម្បីតស៊ូវាយរំដោះចេញពីចក្រពត្តិអាមេរិកាំង។ ពេលហ្នឹងលោកនៅណា?

[១៥:២២:៤៣]

**ឆ៖** ពេលហ្នឹងខ្ញុំនៅឆែកស្ទូវ៉ាគីនៅឡើយ។

**ស៖** ប៉ុន្តែលោកបានឮសំឡេងហ្នឹងទេ?

**ឆ៖** ខ្ញុំឮសំឡេងហ្នឹង បានខ្ញុំមកវិញហ្នឹង។ លោកអំពាវនាវពី-- ព្រះករុណាលោកអំពាវនាវពីប៉េកាំងទៅ។

**ស៖** សូមអរគុណ។

**ឆ៖** ហើយប៉េកាំងមកចូល ហ្រ្គុង ហ្នឹង ហើយបានចេញពីប៉េកាំងមកហាណូយ តមកទៀត។

**ស៖** នៅក្នុងឯកសារដដែល លោកបានសរសេរថា ពេលព្រះអង្គគង់នៅក្នុងអំណាច គឺពីពេលចូលប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥ មករហូតដល់ព្រះអង្គលាលែងពីរដ្ឋាភិបាល ហ្រ្គុង។ តើព្រះអង្គមានមុខងារធ្វើអ្វី? លោកធ្វើអីខ្លះ ពេលដែលលោកឈប់ លាលែងហើយហ្នឹង? លោកមិននៅក្នុងវាំងកាលហ្នឹងលោកចាំថាព្រះអង្គនៅក្នុងវាំង មិនអ៊ីចឹងណ៎ា?

**ឆ៖** បាទ, កាលពេលហ្នឹង គឺព្រះអង្គលោកនៅក្នុងវាំង ហើយ--

**ស៖** មានដឹងថាលោកធ្វើអីទេនៅក្នុងវាំងហ្នឹង? គេឲ្យធ្វើអី?

**ឆ៖** ខ្ញុំមិនដឹងឲ្យធ្វើអីទេ មិនដឹងធ្វើអីទេ។

[១៥:២៤:១៨]

**ស៖** អរគុណណាស់។ នៅក្នុងឯកសារដដែលបានសួរលោកថា ពេលព្រះអង្គលាលែងពីប្រមុខនៅដើមឆ្នាំ១៩៧៦ ប្រហែលខែមីនា ពេលនោះមានតែលោក ខៀវ សំផន, សុន សេន, អៀង សារី និងកម្មាភិបាលមជ្ឈិមខ្លះបានសួរសុខទុក្ខ (សូមទោស) បានទៅអង្វរលោកកុំឲ្យលាលែង។ តើរឿងនេះលោក នរិន្ទ ដឹងទេ?

**ឆ៖** កាលហ្នឹង គឺខ្ញុំដឹងគឺថាឃើញអ៊ំៗហ្នឹងទៅ--

**ស៖** អត់ឮទេ!

**ឆ៖** ទៅជួបព្រះករុណាហ្នឹងសុំអង្វរកុំឲ្យ--

**ស៖** អត់ឮទេ! អត់ឮ!

**ប្រធានអង្គជំនុំ៖**

លោកមើលឡើងវិញ មកពីអស់ថ្មទេអី? សូមបន្តលោក ឡុង នរិន្ទ ឆ្លើយនូវសំណួរបន្ត។

**សួរដោយលោក សុន អរុណ៖**

**ស៖** អំមិញលោកឮសំណួរខ្ញុំទេទាន?

**លោក ឡុង នរិន្ទ៖**

**ឆ៖** គឺពេលហ្នឹងខ្ញុំដឹងពីព្រោះអំៗទៅប្រហែលជា ដូចប៉ុន្មាននាក់ទេទៅសុំឃាត់លោកកុំឲ្យលាលែងហ្នឹង។

**ស៖** ហើយព្រះអង្គមានយោបល់យ៉ាងម៉េចតបទៅវិញទេ? មានដឹងទេ?

**ឆ៖** អាហ្នឹងខ្ញុំអត់ដឹងទេ មិនដឹងជាលោកមានយោបល់យ៉ាងម៉េចទេ ក៏ប៉ុន្តែព្រះករុណា អ្នកណាទៅធ្វើម៉េចលោកបាន តែលោកថាម៉េចអ៊ីចឹងហើយ។

**ស៖** សូមអរគុណណាស់។ សំណួរមួយទៀត ពេលលោកលាលែងពីប្រមុខរដ្ឋនៃរាជរដ្ឋាភិបាលហ្គ្រុង នោះតើលោកដឹងថាមតិប្រជាពលរដ្ឋទូទៅទាំងប្រទេសមានមតិ និងយោបល់យ៉ាងណាខ្លះចំពោះព្រះអង្គ?

**ឆ៖** ពេលហ្នឹង ខ្ញុំអត់ដឹងអីទេ ពីរឿងថាមតិប្រជាជនហ្នឹង ប្រជាពលរដ្ឋហ្នឹងយ៉ាងម៉េចហ្នឹងខ្ញុំអត់ដឹងទេ។

[១៥:២៦:៥៨]

**ស៖** សំណួរមួយនេះ លោកបានឆ្លើយនឹងចៅក្រមពាក់កណ្តាលហើយ ប៉ុន្តែខ្ញុំនៅសល់ថែមពាក់កណ្តាលទៀត ប៉ុន្តែខ្ញុំមើលទាំងអស់ដើម្បីសួរនៅចុងក្រោយ។ លោក នរិន្ទ លោកបានឆ្លើយប្រាប់អ្នកសាកសួររបស់ចៅក្រមស៊ើបអង្កេតកាលពីខែធ្នូ ឆ្នាំ២០០៧ ថាពេលព្រះអង្គគង់នៅក្នុងវាំង ព្រះអង្គបានយាងចេញទៅកំសាន្តនៅក្រៅវាំង ម្តងមួយយាម ហើយពេលនោះ សុន សេន ជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងសន្តិសុខក្នុង និងក្រៅប្រទេស បានបើកឡានកាត់មុខសម្តេចដោយពុំមានការគោរពព្រះអង្គទេ។ ចំពោះលោក នរិន្ទ វិញយល់យ៉ាងម៉េចបើ សុន សេន គាត់បើកឡានកាត់មុខព្រះអង្គ ដែលឃើញព្រះអង្គយាងចេញអ៊ីចឹងហើយ។ ផ្ទាល់ខ្លួនរបស់លោក លោកយល់ថាយ៉ាងម៉េច? ព្រោះអីលោកជាកងការពារពេលនុ៎ង?

[១៥:២៧:៤៧]

**ឆ៖** ខ្ញុំអង្គាល់ហ្នឹង គឺថាខ្ញុំជាអ្នកការពារហ្នឹង ខ្ញុំលើកដៃរាមិនឲ្យមកទេឡានហ្នឹង ប៉ុន្តែឡានហ្នឹងនៅតែមកអ៊ីចឹង ហើយសំណាងល្អ ដែលខ្ញុំអត់មានបញ្ហាអីកាលហ្នឹង។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីព្យាយាមក្នុងការប្រើការតាំងសំណួរទីមួយមិនច្រំដែល ទីពីរមិនអាចធ្វើឲ្យសំណួរឯណាដែលនាំឲ្យសាក្សីបញ្ចេញនូវមតិយោបល់ធ្វើការសន្និដ្ឋាននៅក្នុងអង្គហេតុដែលគាត់បានឃើញបានដឹងនោះទេ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានបានឲ្យយោបល់។

**សួរដោយលោក សុន អរុណ៖**

**ស៖** ពេលដែលនៅក្នុងរាជរដ្ឋាភិបាលក្រោ្កុង នៅឡើយសម្តេចជាប្រមុខរដ្ឋ អ្នកណាជានាយករដ្ឋមន្ត្រីពេលហ្នឹង?

**ឆ៖** អង្កាល់ដែលសម្តេចជាប្រមុខរដ្ឋហ្នឹងគឺ ប្រមុខរដ្ឋក៏ព្រះករុណា នាយករដ្ឋមន្ត្រីក៏ព្រះករុណា។

**ស៖** ចុះសម្តេច ប៉ែន នុត ជាអ្វី?

**ឆ៖** អ៊ូ! សម្តេច ប៉ែន នុត អ៊ីចឹងហ៎! សម្តេច ប៉ែន នុត ជានាយករដ្ឋមន្ត្រី។

**ស៖** សូមអរគុណ។ លោក នរិន្ទ លោកបានស្គាល់លោក គាត ឈន់ និងលោក ជួន ប្រសិទ្ធ ច្បាស់លាស់ទេ?

**ឆ៖** ខ្ញុំស្គាល់ដោយសារធ្វើការនៅក្នុងក្រសួងជាមួយគ្នា តែប៉ុណ្ណឹង។

[១៥:៣០:០៥]

**ស៖** កាលពីនៅក្រសួង ប-១ ហ្នឹង លោក គាត ឈន់ លោក ជួន ប្រសិទ្ធ គាត់-- មុខងារគាត់ធ្វើអ្វី?

**ឆ៖** ខ្ញុំមិនដឹងទេអាហ្នឹង រឿងហ្នឹង។

**ស៖** នៅក្នុងចម្លើយរបស់លោក នៅក្នុងឯកសារដដែលថាសម្តេចនរោត្តម សីហនុ បានយាងចេញទៅចម្ការកៅស៊ូជប់ និងទតស្រែឃោធាត្រង់ម្តុំវាលស្បូវ។ តើពិតមែនទេ?

**ឆ៖** បាទ, ព្រះកុរណាបានទៅធ្វើទស្សនកិច្ចចម្ការកៅស៊ូជប់ហ្នឹង បានទៅមែន អង្កាល់ហ្នឹង។

**ស៖** អង្កាល់ហ្នឹងលោក បានទៅតាមការពារលោកទេ? ព្រះអង្គទេ?

**ឆ៖** បានទៅ។

**ស៖** អង្កាល់ពេលដែលព្រះអង្គយាងទៅហ្នឹងសន្តិសុខ នៅតាមស្រុកស្រែ នៅតាមចម្ការអីចឹង យ៉ាងម៉េច?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេ អ៊ំ?

**លោក ឡុង នរិន្ទ៖**

ខ្ញុំអត់យល់ច្បាស់ទេ។

**លោក ញ៉ែម សំណាង៖**

សួរថា តើពេលដែលព្រះអង្គយាងហើយអ៊ំ ទៅយាម-- ទៅការពារព្រះអង្គ តើអ៊ំយល់ថាស្ថានភាពសន្តិសុខនៅតាមស្រុកស្រែនុ៎ងយ៉ាងម៉េចដែរ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ពេលហ្នឹងគឺថា ខ្ញុំទៅ ប៉ុន្តែមុនខ្ញុំទៅហ្នឹង ខ្ញុំដឹងថាខាងស្រែនោះក៏គេរៀបចំហើយ គេមានសន្តិសុខរបស់គេ ខ្ញុំទៅគ្រាន់តែទាក់ទងជាមួយគេនិយាយប្រាប់គេថា ព្រះកុរុណាលោកយាងមកដូច្នោះ សូមឲ្យការពារឲ្យបានល្អផង ប៉ុណ្ណឹងទេ។

[១៥:៣១:៥៨]

**ស៖** តាមចម្លើយរបស់លោកនៅក្នុង ជាមួយចៅក្រមស៊ើបអង្កេតមានតែប៉ុណ្ណឹង ឆ្លើយថាបានទៅទស្សនកិច្ចកន្លែងអំមិញហ្នឹង។ ប៉ុន្តែមានកន្លែងណាផ្សេងទៀតទេ ព្រះអង្គបានយាងទៅ?

**ឆ៖** គាត់សួរថាម៉េចអំមិញ?

**លោក ញ៉ែម សំណាង៖**

ថាតើព្រះអង្គបានយាងទៅទតកន្លែងណាផ្សេងទៀតទេ អ៊ំ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បានទៅមើលស្រែឃោជានៅម្តុំជិតនៅនេះ បានទៅមើល-- ព្រះកុរុណាលោកបានទៅមើលគេធ្វើស្រែនៅជិត ហួសជ្រោយចង្វាទៅ ប៉ុន្តែមិនទាន់ទៅដល់ន័ស្ទីនេះទេ--

**ស៖** វាលស្បូវ?

**ឆ៖** ក្រុងជិតភ្នំពេញដែរហ្នឹង។

**ស៖** សូមបន្តសំណួរ ជិតអស់ហើយនៅសល់តែមួយទៀត។ ក្នុងឯកសារដដែលនោះបានសរសេរថា ពេលដែលលោក អៀង សារី មិននៅមិនមាននរណាអាចសម្រេចកិច្ចការអ្វីក្នុង ប-១ នោះបានទេ។ នេះជាការពិត ឬទេ ឬក៏ថាលោកគ្រាន់តែឆ្លើយឲ្យតែរួចខ្លួន ឬយ៉ាងម៉េច? បើលោក អៀង សារី មិននៅអត់មាននរណាអាចសម្រេចបាន។

[១៥:៣៣:៤៩]

**ឆ៖** ហ្នឹងគឺគាត់ ពេលដែលគាត់មិននៅគាត់ចេញទៅក្រៅ គាត់មកប្រាប់ មកធ្វើការជាមួយនឹងកម្មាភិបាលនៅនេះហ្នឹង គាត់មានប្រសាសន៍ថា អ៊ីចឹង។ គឺថា បើគាត់មិននៅកុំឲ្យនរណាមកយកអីអត់ទេ អត់មានឲ្យនរណាយកបុគ្គលិករបស់គាត់ចេញពីក្រសួងទេ។

**ស៖** សូមអរគុណ។ តែលោក អៀង សារី ត្រូវតែធ្វើតាមគណៈមជ្ឈិមដែលមាន ប៉ុល ពត ជាប្រធាន។ លោក អៀង សារី ធ្វើអ្វីត្រូវឲ្យ ប៉ុល ពត យល់ព្រមជាមុនសិន។ រឿងហ្នឹងពិតជាអ៊ីចឹងទេ? ឧទាហរណ៍ៗមួយចុះថា ដូចលោក អៀង សារី លោកអញ្ជើញទៅអង្គការសហប្រជាជាតិ ដើម្បីធ្វើសុន្ទរកថាពីរឿងកម្ពុជាប្រជាធិបតេយ្យ។ សុន្ទរកថារបស់ អៀង សារី នោះក៏ត្រូវសុំការសម្រេចពី ប៉ុល ពត ដែរ។ រាល់រៀងរាល់ឆ្នាំអ៊ីចឹង តើរឿងហ្នឹងពិតអ៊ីចឹង ឬយ៉ាងម៉េចបើតាមលោកដឹង?

**ឆ៖** ខ្ញុំមិនដឹងយ៉ាងម៉េចទេ ប៉ុន្តែសុន្ទរកថាប្រហែលជាមានការសម្រេចពីមជ្ឈិមទៅស្រួលបួលបានលោក អៀង សារី គាត់បានមានសិទ្ធិយកទៅសូត្រនៅអង្គការសហប្រជាជាតិ។

**ស៖** សូមអរគុណ។

[១៥:៣៥:៣៥]

**ប្រធានអង្គជំនុំ៖**

ឈប់ៗលោកមេធាវី!

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំសូមជំទាស់ទៅនឹងមេធាវី ដែលបានធ្វើការសន្និដ្ឋាន ដែលថា គាត់មិនបានទទួលការណែនាំពីគណៈមជ្ឈិមអចិន្ត្រៃយ៍នេះជានាំមុខសាក្សី។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតតុលាការបង្គាប់លោកមេធាវីថា កុំឲ្យសួរសំណួរនាំមុខទៅដល់សាក្សី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ហើយដើម្បីឲ្យបានងាយយល់ ហើយច្បាស់លាស់សូមលោកអាចងើបឈរ

ឡើង ដើម្បីបង្ហាញជំហរថា លោកជំទាស់ ចៀសវាងថា លោកមិនច្បាស់លាស់លើការជំទាស់នេះ នាំឲ្យសំណួរដែលសួរទៅហើយ សាក្សីឆ្លើយរួចហើយ ទើបមានការជំទាស់ជាក្រោយ។ ដូច្នេះយើងជាប្រធានអង្គសវនាការមិនដឹងសម្រេចអំពីបញ្ហានេះដូចម្ដេចទេ។ តាមធម្មតាភាគីកាលបើស្ដាប់នូវសំណួរ ដែលសួរនោះហើយវាមានលក្ខណៈផ្ទុយពីគោលការណ៍នៃការតាំងសំណួរនៅក្នុងតាមផ្លូវតុលាការនោះ គឺលើកដៃ ឬក៏ឈរ ដើម្បីបង្ហាញនូវជំហរជំទាស់នោះ គឺអង្គជំនុំជម្រះនឹងស្ដាប់ការជំទាស់នោះថាតើត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ ដើម្បីសម្រេចថាឲ្យសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកជំនាញឆ្លើយ ឬក៏មិនត្រូវឆ្លើយទេ នេះជាការងាយ។

ហើយរំឭកម្ដងទៀតគឺ សូមលោកប្រយ័ត្ននូវសំណួរដែលមានការបែបសួរនាំមុខនូវសំណួរទាំងឡាយដូចនាំមុខ ឬក៏សំណួរច្រំដែល អានេះយើងបាននាំណែរួចហើយ។

សូមអញ្ជើញសហព្រះរាជអាជ្ញា!

[១៥:៣៧:៥៦]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន ដោយហេតុថា ខ្ញុំមិនអាចជំទាស់បានភ្លាមដោយហេតុថា ការបកប្រែជាអង់គ្លេសនោះវាយឺតបន្តិច ហើយគាត់ស្ដាប់សំណួរជាភាសាខ្មែរ គាត់ឆ្លើយភ្លាមដូច្នេះខ្ញុំមិនទាន់ជំទាស់បានភ្លាម។ ខ្ញុំបានក្រោកឈរដែរ ក៏ប៉ុន្តែរង់ចាំការបកប្រែ ប៉ុន្តែសាក្សីគាត់បានឆ្លើយផុតទៅហើយ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រម។ សំណួរដែលទាក់ទងទៅនឹងកូនក្ដីរបស់ខ្ញុំ គឺជាវិធីដែលយកពីសេចក្ដីសង្ខេបនៃចម្លើយរបស់គាត់ដែលថា ហើយនិងផ្អែកទៅតាមដំណាក់កាលនីមួយៗ អ៊ីចឹងទៅមើលទំព័រលេខ៥ ឯកសារហ្នឹងជាអត្ថបទភាសាអង់គ្លេស ហើយយើងនឹងឃើញថា ខ្ញុំអាចនឹងជូន ERN គឺថានៅកន្លែងនេះទាក់ទងនឹងសាក្សីនេះ ថា អៀង សារី គឺធ្វើតាមគណៈមជ្ឈិមបក្សជាឧទាហរណ៍ ទោះបីជាសុន្ទរកថាដែលត្រូវយកទៅអាននៅអង្គការសហប្រជាជាតិក៏ត្រូវតែឆ្លងគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិមដែលមាន ប៉ុល ពត ជាប្រធាន។ ដូច្នេះត្រូវតែមានការឯកភាព ដូច្នេះខ្ញុំមិនយល់អ្វីទេដែលថា ការជំទាស់របស់សហព្រះរាជអាជ្ញានោះជំទាស់ទៅលើអ្វីទេ បើជំទាស់បែបនេះមិនត្រឹមត្រូវទេ។

[១៥:៣៩:២៩]

**លោក ខេល លីសាក់៖**

ដូច្នេះ គឺថា ដូចអ្នកប្រែ គឺថាសំណួរ គឺទាក់ទងទៅនឹងចម្លើយដែលថា លោក អៀង សារី ទទួលបញ្ជាអំពីគណៈមជ្ឈិម ប៉ុន្តែអ្វីដែលលោកលើកអំមិញនេះ គឺមិនបែបនោះទេ គឺវាខុសគ្នាបាទ។

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅព្រះរាជអាជ្ញាខ្លីទេ។ ខ្ញុំដកស្រង់នូវសំណួរនិងចម្លើយហ្នឹងចេញពីនៅក្នុងឯកសារ នៅក្នុងឯកសារ D91/3 ប៉ុន្តែនៅក្នុងបន្តពីសំណួរហ្នឹងទៅ ខ្ញុំមានសំណួរបន្ថែមបន្តិចទៀត។ អ៊ីចឹង ហើយបានខ្ញុំយកសំណួរហ្នឹងដើម្បីបន្ថែមនឹងសំណួររបស់ខ្ញុំ។ ខ្ញុំចង់និយាយជម្រាបទៅខាងព្រះរាជអាជ្ញាតែប៉ុណ្ណឹង។ បើអ៊ីចឹងខ្ញុំសូមបន្ត។

**សួរដោយលោក សុន អរុណ៖**

**ស៖** បើដូច្នេះមែន។ លោក នរិន្ទ ពាក្យគេចោទថា ប្រជាជនខ្មែរក្នុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ នោះបានស្លាប់យ៉ាងច្រើន។ នោះគឺបញ្ជាពី ប៉ុល ពត ឬអ្វី? ឬមួយបញ្ជាពីនរណាផ្សេងទៀត? លោកអាចឆ្លើយសំណួររបស់ខ្ញុំនេះបានទេ? ខ្ញុំសួរម្តងទៀត បើសិនលោកមិនយល់។ ខ្ញុំឃើញលោកកំពុងក្អកអំមិញ។

[១៥:៤០:៥១]

ខ្ញុំសួរថា បើដូច្នេះដែលលោកឆ្លើយពីលើមកហើយហ្នឹង។ បើដូច្នេះមែន ពាក្យគេចោទថា ប្រជាជនខ្មែរក្នុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃនោះ បានស្លាប់យ៉ាងច្រើន នោះគឺជាបញ្ជារបស់ ប៉ុល ពត ដែរឬអ្វី? ឬមួយបញ្ជាពីនរណាផ្សេងទៀត?

**លោក ឡុង នរិន្ទ៖**

**ឆ៖** នោះខ្ញុំមិនដឹងទេ។

**លោក សុន អរុណ៖**

សូមអរគុណ។ ខ្ញុំដូចជាអស់មានសំណួរអីហើយខ្ញុំមានតែប៉ុណ្ណឹង។ ហើយបន្ទាប់ខ្ញុំកូនក្តីខ្ញុំចង់សួរទៅលោក នរិន្ទ បានមួយសំណួរ តែមួយសំណួរទេ បើលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជម្រះអនុញ្ញាត ប៉ុន្តែសួរៗមកតាមរយៈប្រធាន។ សួរមកតាមប្រធាន សួរបន្តទៅលោក

នរិន្ទ។ សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ខ្ញុំអនុញ្ញាតអង្គុយ។ តាមរយៈលោកប្រធាន។ ខ្ញុំសូមគោរពលោកប្រធាន។

តាមរយៈលោកប្រធាន ខ្ញុំសូមសួរលោក ឡុង នរិន្ទ ដូចតទៅនេះ៖ ក្នុងប្រវត្តិរូបរបស់លោកជាភាសាខ្មែរ លោកបានរៀបរាប់បន្តិចពី សឺង ង៉ុកថាញ់។ ខ្ញុំចង់សួរថា តើលោកមានទទួលឥទ្ធិពលនយោបាយពី សឺង ង៉ុកថាញ់ ដែរឬទេ? ព្រោះលោកថា លោកមានសមានចិត្តលើ សឺង ង៉ុកថាញ់ ព្រោះ សឺង ង៉ុកថាញ់ គាត់ជាអ្នកប្រឆាំងស្តេច ប្រឆាំងបារាំង។ នេះជាសំណួរទីមួយ។

[១៥:៤២:៥៩]

**ប្រធានអង្គជំនុំ៖**

លោក ឡុង នរិន្ទ ឥឡូវនេះសំណួររបស់លោក នួន ជា នៅក្នុងប្រវត្តិរូបរបស់លោក ជាភាសាខ្មែរហ្នឹង លោកបានរៀបរាប់បន្តិចពី សឺង ង៉ុកថាញ់ តើលោកបានទទួលឥទ្ធិពលពីឈ្មោះ សឺង ង៉ុកថាញ់ ហ្នឹងដែរឬទេ? ហើយដោយសារ សឺង ង៉ុកថាញ់ ហ្នឹងគឺជាអ្នក ជាមនុស្សប្រឆាំងស្តេច ប្រឆាំងព្រះរាជា?

**លោក ឡុង នរិន្ទ៖**

ខ្ញុំអត់មានទទួលឥទ្ធិពលពី សឺង ង៉ុកថាញ់ ទេ។ គ្រាន់តែគឺថា អង្គាល់ហ្នឹងគាត់ ចេញមុខប្រឆាំងនឹងបារាំង ដូច្នោះហ្នឹង ដែលខ្ញុំពេញចិត្តនោះ។ ឯស្អីៗផ្សេងទៀត ខ្ញុំអត់ដឹងទេ មិនចូលចិត្តទេ។

[១៥:៤៤:០៤]

**លោក នួន ជា៖**

ប៉ុន្តែថា លោកមានសមានចិត្តលើ សឺង ង៉ុកថាញ់ ព្រោះ សឺង ង៉ុកថាញ់ ជាអ្នកប្រឆាំងស្តេច និងប្រឆាំងបារាំង? ពីរនេះ លោកយល់យ៉ាងម៉េច ប្រឆាំងស្តេច ហើយនិងប្រឆាំងបារាំងនេះ?

**ប្រធានអង្គជំនុំ៖**

សំណួរទីពីរហ្នឹងគឺថា លោកមានសមានចិត្តទៅលើ សឺង ង៉ុកថាញ់ ពីព្រោះ សឺង ង៉ុកថាញ់ ហ្នឹងគឺជាមនុស្សប្រឆាំងស្តេច ហើយនិងប្រឆាំងបារាំង? តើបញ្ហាដែលលើកឡើងដូច្នេះហ្នឹងមានន័យថាម៉េច?

**លោក ឡុង នរិន្ទ៖**

អង្គាល់សម័យហ្នឹង យុវជនហ្នឹងគឺវាអ៊ីចឹង ទាំងអស់គ្នីទាំងអស់គ្នាហ្នឹង យុវជនខ្មែរហ្នឹង ជយោទៅ ដូច្នោះខ្ញុំក៏ជយោនឹងគេទៅ។ ដល់ខ្ញុំទទួលការអប់រំពី-- ខ្ញុំដឹងថាជាបញ្ហាមិនល្អទេអាហ្នឹង។

**លោក នួន ជា៖**

ខទីពីរ លោកស្គាល់ ហង់ ធន់ហាក់ ដែលជាដៃស្តាំរបស់ សឺង ង៉ុកថាញ់ ហើយឆ្នាំ១៩៧២ ហង់ ធន់ហាក់ ឡើងធ្វើជានាយករដ្ឋមន្ត្រី។ តើលោកមាននិន្នាការនយោបាយជាប់ទាក់ទងជាមួយចលនាខ្មែរសេរី សឺង ង៉ុកថាញ់ និង ហង់ ធន់ហាក់ ដែរឬទេ?

**លោក ឡុង នរិន្ទ៖**

អត់ទេ ខ្ញុំអត់មានទាក់ទងពីរឿងនយោបាយជាមួយជាមួយនឹង ហង់ ធន់ហាក់ទេ។

**លោក នួន ជា៖**

សូមសួរ ខទីបី សូមគោរពលោកប្រធាន តើលោកមានស្គាល់ឈ្មោះ អៀ ស៊ីចូវ ដែលជាដៃស្តាំមួយរបស់ សឺង ង៉ុកថាញ់ ដែរឬទេ?

**លោក ឡុង នរិន្ទ៖**

ខ្ញុំគ្រាន់តែឮសូរឈ្មោះ អៀ ស៊ីចូវ ហ្នឹងប៉ុណ្ណឹង ប៉ុន្តែខ្ញុំអត់ដែលស្គាល់ មិនដឹងមុខគាត់យ៉ាងម៉េចផងទេ។

**លោក នួន ជា៖**

ខទីបួន តើឈ្មោះយុវជនទាំងប៉ុន្មាន ដែលលោកបានរៀបរាប់ក្នុងប្រវត្តិរូបរបស់លោកមកទាំងប៉ុន្មាននេះ តើពួកនេះ ធ្វើចលនាក្នុងក្រុម សឺង ង៉ុកថាញ់ ដែរឬទេ? ហើយធ្វើសកម្មភាពអ្វីខ្លះ?

**លោក ឡុង នរិន្ទ៖**

ហ្នឹងខ្ញុំមិនដឹងទេ។ ដឹងគេធ្វើអី។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។

**លោក នួន ជា៖**

ខ្ញុំជម្រាប ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។

[១៥:៤៨:០៣]

ម៉េចទៅ?

**លោក សុន អរុណ៖**

សូមអត់ទោស ឲ្យសហព្រះរាជអាជ្ញាសិន ដោយសារមីក្រូមិន--

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការរៀបចំនូវក្បាលមីក្រូសម្រាប់ពួកគាត់។

**លោក ម៉ៃខល ផេសមិន៖**

សូមគោរពលោកប្រធាន មីក្រូហ្វូនរបស់ខ្ញុំស្តាប់ឮធម្មតា។ ប៉ុន្តែ ខ្ញុំអត់អាចទទួលការបកប្រែទៅជាភាសាដែលខ្ញុំស្តាប់បានទេ។ ប៉ុន្តែបើសិនជាតុលាការអាចស្តាប់ខ្ញុំបាន ខ្ញុំនឹងចាប់ផ្តើមសំណួរ ខ្ញុំអាចប្រើពេលតែ២០នាទី ទាក់ទងទៅនឹងសាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការរៀបរយនូវប្រព័ន្ធបកប្រែភាសា ដើម្បីឲ្យបានស្តាប់បានទាំងអស់គ្នា ជាពិសេសដោយឡែកមេធាវីការពារក្តី នួន ជា ដែលកំពុងតែដំណើរការសួរដល់សាក្សី។

សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំ-- តើយើងអាច យើងផ្តល់ពេលវេលាឲ្យបានច្បាស់លាស់ទៅ ដើម្បីសួរទៅកាន់ភាគីនីមួយៗនោះលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបទៅភាគីរួចហើយ តាំងពីដើមទីមករហូតដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់មានសមត្ថភាព និងលទ្ធភាពពេញលេញនៅក្នុងការកំណត់ពេលវេលាជាក់លាក់សម្រាប់ស្តាប់សក្ខីកម្មសួរចម្លើយជនជាប់ចោទ ក៏ដូចជាសួរដើមបណ្តឹងរដ្ឋប្បវេណី សាក្សីនៅឡើយទេ។ ដោយសារកម្រិតនៃការយល់ដឹងពាក់ព័ន្ធនៅក្នុងអង្គហេតុនេះ វាមានទំហំខុសៗគ្នា។ បញ្ហាទីពីរភាពរអាក់រអួលនៃកិច្ចដំណើរការរបស់-- លទ្ធភាពនៃបញ្ហាធ្វើសវនាការតាមប្រព័ន្ធសោតទស្សន៍ ដែលអស់លោក លោក

ស្រីបានធ្វើឃើញជាក់ស្តែងហើយ។ យើងធ្វើការងារនេះដ៏លំបាក ជួបប្រទះនូវបញ្ហាជាច្រើន បញ្ហាសុខភាព បញ្ហាបច្ចេកទេសប្រព័ន្ធសោតទស្សន៍ បញ្ហាអ៊ីនធឺណិតជាបន្តបន្ទាប់។

[១៥:៥១:១១]

លទ្ធភាពដែលយើងប្រឹងប្រែង ប្រមើលមើលថា នឹងអាចចប់នៅវសៀលនេះ ប៉ុន្តែដោយហេតុមិនចប់។ ដូច្នោះឱកាសបន្តិចបន្តួចយើងនឹងទុកលទ្ធភាពទៅឲ្យមេធាវី ដែលមានបំណងសួរ គឺអាចសួរបន្តរហូតដល់ម៉ោងសម្រាកថ្ងៃនេះ។

សូមអញ្ជើញលោកមេធាវី!

**សួរដោយលោក ម៉ៃខល ផេសមិនៈ**

សូមអរគុណលោកប្រធាន។

**ស៖** លោក ឡុង នរិន្ទ ដូចដែលលោកបានបញ្ជាក់ឈ្មោះ គាត ឈន់ ហើយលោកនិយាយថាគេធ្វើការជាមួយគាត់នៅ ប-១។ តើការទទួលខុសត្រូវរបស់គាត់ដូចម្តេចដែរ ដែលលោកថា ឈ្មោះថា គាត ឈន់ នោះ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរគាត់?

**លោក ឡុង នរិន្ទ៖**

**ឆ៖** បាទ (ឮមិនច្បាស់) ។

**ស៖** សំណួរខ្ញុំបានឃើញលោកឆ្លើយ ប៉ុន្តែខ្ញុំអត់ស្តាប់ឮការបកប្រែ។ សូមលោកបញ្ជាក់ម្តងទៀតបានទេ? បាទ ខ្ញុំនឹងសួរម្តងទៀត។ ពីរបីមីនុតកន្លងទៅនេះ គឺថាលោក និងលោក គាត ឈន់ ជាអ្នកធ្វើការជាមួយគ្នានៅក្នុងមន្ទីរ ប-១ ប៉ុន្តែខ្ញុំមិនដឹងថា គាត់ទទួលខុសត្រូវអ្វីទេ។ លោកបានឆ្លើយអ៊ីចឹង តើមែនឬទេ?

[១៥:៥៣:១៥]

**ឆ៖** បាទ លោក គាត ឈន់ គាត់នៅក្រុមមិនជាមួយខ្ញុំទេ។ គឺគាត់ខាងក្រុមអ្នកនិពន្ធឯណានោះទេ ហើយក៏ខ្ញុំមិនដឹងអ្នកណាទទួលខុសត្រូវគាត់ ហើយអ្នកណាចាត់ចែងការងារស្អីៗម៉េច ខ្ញុំមិនដឹងទេ។

**ស៖** ចាតើអ្នកសរសេរ អ្នកនិពន្ធហ្នឹងធ្វើអ្វីខ្លះនៅមន្ទីរ ប-១ នោះ?

**ឆ៖** ខ្ញុំ អាហ្នឹងក៏ខ្ញុំមិនដឹងដែរ គឺថាគេ--

**ស៖** ថាតើកាលនោះ លោកជាអ្នកជិតស្និទ្ធជាមួយលោក គាត ឈន់ ទេ?

**ឆ៖** សួរថាម៉េច?

**លោក ញ៉ែម សំណាង៖**

តើអ៊ំ ជាងអ្នកជិតស្និទ្ធជាមួយនឹងលោក គាត ឈន់ ទេ?

**លោក ឡុង នរិន្ទ៖**

**ឆ៖** គាត់នៅផ្នែកផ្សេង ខ្ញុំនៅផ្នែកផ្សេង ដូច្នោះគ្រាន់តែជិតស្និទ្ធជាអ្នកធ្វើការនៅក្រសួងជាមួយគ្នាប៉ុណ្ណឹង។

[១៥:៥៤:៣៣]

**ស៖** ថាតើគាត់ណែនាំឲ្យលោកថា ត្រូវសរសេរប្រវត្តិដូចម្ដេចដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** តើលោក គាត ឈន់ មិនមែនជាមនុស្សម្នាក់ក្នុងចំណោមដែលសុំឲ្យពួកបញ្ញាជនជាអ្នកសរសេរប្រវត្តិរូបទេឬ?

**ឆ៖** ហ្នឹងក៏ខ្ញុំមិនដឹងទេ។

**ស៖** នៅឆ្នាំ២០០៧ លោកបានប្រាប់ទៅអ្នកស៊ើបអង្កេតថា លោកបានបញ្ជាក់ថា គាត់នោះជាមនុស្សម្នាក់ដែលណែនាំឲ្យអ្នកផ្សេង ឬក៏ពួកបញ្ញាជនរៀបចំប្រវត្តិរូប។ តើលោកបានឆ្លើយបែបនោះទេកាលនោះ?

[១៥:៥៥:៣៤]

**ឆ៖** មិនចាំទេ ភ្លេច។

**ស៖** កាលពីអាទិត្យមុន គេសួរលោក តុលាការសួរលោកអំពីការប្រជុំ ដែលធ្វើឡើងនៅ ប-១ នៅឆ្នាំ១៩៧៧ ដែលលោក អៀង សារី ប្រាប់បុគ្គលិកថា គាត់មិនអនុញ្ញាតឲ្យមានការចាប់ខ្លួនបុគ្គលិកគាត់ទេ កាលណាគាត់មិននៅភ្នំពេញ។ ថាតើលោកនៅចាំទេការប្រជុំហ្នឹង? ការពិតបែបហ្នឹងឬទេ?

**ឆ៖** ខ្ញុំមិនចាំទេ។

**ស៖** នៅក្នុងចំណុចមួយ លោកបានបញ្ជាក់អំពីការប្រជុំនេះគឺនៅក្នុងការផ្ដល់សម្ភាសន៍ឲ្យអ្នកអង្កេតរបស់ចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៧ ហើយសប្ដាហ៍មុននេះគឺចៅក្រម-- ភាគីសួរលោកអំពីកិច្ចប្រជុំនេះដែរ។ តើលោកមិនចាំទេឬ? ឬក៏លោកនៅចាំអ្វីខ្លះទេ?

[១៥:៥៧:១៥]

តើលោកនៅចាំអំពីសំណួរឬក៏បញ្ហាហ្នឹងទេ? បាទ គឺចំណុចដែលលោកបានឆ្លើយទៅនឹងអ្នកអង្កេតពីឆ្នាំ២០០៧ ហើយនិងការឆ្លើយពីអាទិត្យមុននេះ គឺថាពេលដែលក្នុងប្រជុំនោះលោក អៀង សារី នោះថា ពេលដែលគាត់មិននៅក្នុងមន្ទីរ មិនអនុញ្ញាតឲ្យមានអ្នកណាមកចាប់មនុស្ស ឬក៏មកយកមនុស្សចេញទេ។ លោកចាំថា គាត់បាននិយាយបែបហ្នឹងដែរឬទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំយល់សំណួរទេអំមិញ?

**លោក ឡុង នរិន្ទ៖**

អត់ ខ្ញុំ សួរ-- (ឮមិនច្បាស់)។

**លោក ញ៉ែម សំណាង៖**

សួរថា នៅពេលដែលលោក អៀង សារី មិននៅ គឺលោក អៀង សារី មិនអនុញ្ញាតឲ្យអ្នកណាយកមនុស្ស ឬក៏ចាប់មនុស្សចេញពី ប-១ នោះទេ។ តើអ៊ំបានចាំទេ?

[១៥:៥៨:៣៨]

**លោក ឡុង នរិន្ទ៖**

**ឆ៖** អាហ្នឹងខ្ញុំគ្រាន់តែនឹកឃើញថា គាត់មានប្រាប់អ៊ីចឹងម្តង អាហ្នឹងគាត់និយាយជាទូទៅក្នុងពេលប្រជុំក្រសួងទេ។ ប៉ុន្តែអាហ្នឹងវាដៅទៅលើកម្មាភិបាលហ្នឹង។ ហើយខ្ញុំជាយុទ្ធជន ខ្ញុំ--

**ស៖** លោកបានប្រាប់អ្នកស៊ើបអង្កេតកាលពីឆ្នាំ២០០៧ថា លោកមិនបានចូលរួមក្នុងការប្រជុំនោះទេ។ តើការនោះពិតដែរឬទេ? ត្រឹមត្រូវទេ?

**ឆ៖** ចូលប្រជុំ?

**លោក ញ៉ែម សំណាង៖**

សាក្សីចង់សួរថា តើចូលប្រជុំអ្វី? ចូលប្រជុំក្នុងអី?

**លោក ឡុង នរិន្ទ៖**

**ឆ៖** ខ្ញុំឥឡូវហ្នឹង ខ្ញុំមិនដឹងជាខ្ញុំ--

**ស៖** សំណួរគឺការប្រជុំដែលកើតឡើងនៅក្នុងឆ្នាំ១៩៧៧ ដែលលោក អៀង សារី បានប្រាប់បុគ្គលិកនៅមន្ទីរ ប-១ ថាមិនត្រូវអនុញ្ញាតឲ្យអ្នកណាមកចាប់មនុស្សទេនៅពេលគាត់មិននៅ ហើយ

លោកបានប្រាប់អ្នកស៊ើបអង្កេតដែលសួរលោកថា លោកមិនបានវត្តមាន ឬក៏ចូលរួមក្នុងកិច្ចប្រជុំហ្នឹងទេ?

**ឆ៖** ខ្ញុំអត់មានវត្តមានទេ ព្រោះខ្ញុំមិនមែនជាកម្មាភិបាលទេ ខ្ញុំជាយុទ្ធជន។

**ស៖** តើលោកចាំទេ ថានរណាគេប្រាប់លោកអំពីការប្រជុំនៅពេលនោះ?

[១៦:០០:៥៤]

**ឆ៖** តែមានការប្រជុំក្រសួង គឺថាមនុស្សវាអស់ពីក្រសួងទៅចូលរួមប្រជុំហ្នឹង ប៉ុន្តែខ្ញុំដូចជាមិនចាំទេ អត់មាននឹកឃើញស្អីទេ។

**ស៖** នៅក្នុងឆ្នាំ២០០៧--

**លោក ញ៉ែម សំណាង៖**

លោកប្រធាន! សាក្សីសុំអនុញ្ញាតសម្រាក។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅសំណាង?

**លោក ញ៉ែម សំណាង៖**

សាក្សីបាននិយាយថា សួរច្រើន ហើយសុំសម្រាកលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណច្រើន។ ហើយដោយសារមានការនឿយហត់ និងស្ថានភាពនៃសុខភាពផង ហើយដូច្នេះការសួរដេញដោលសាក្សីរូបនេះ គឺផ្អាកសម្រាប់សវនាការធ្វើថ្ងៃនេះ។

ហើយអ៊ំ លោក ឡុង នរិន្ទ ស្អែក ស្អែកអាចផ្តល់សក្ខីកម្មបានទេ ប្រហែលជាមួយព្រឹកទៀត ឬមិនដល់មួយព្រឹកទេនឹងចប់ហើយ។

[១៦:០២:១១]

**លោក ឡុង នរិន្ទ៖**

បាទ។

**លោក ញ៉ែម សំណាង៖**

លោកប្រធាន សុំអនុញ្ញាតអ៊ំថាស្អែកអាចធ្វើសក្ខីកម្មមួយព្រឹកទេអ៊ំ? អ៊ំមានយោបល់យ៉ាងម៉េចជម្រាបប្រសាសន៍លោកប្រធានទេ។

**លោក ឡុង នរិន្ទ៖**

ខ្ញុំមើលទៅ សុខភាពខ្ញុំបែបមិនអនុញ្ញាតទេ ពីព្រោះឥឡូវហ្នឹងធ្ងន់ក្បាល កាន់តែធ្ងន់ទៅៗដូចជា--

[១៦:០២:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណច្រើន។ អ៊ីចឹងអ៊ំសម្រាកត្រឹមហ្នឹងសិនចុះអ៊ំ។ ហើយចាំអង្គជំនុំជម្រះនឹងពិភាក្សាជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញដើម្បីរិះរកលទ្ធភាពពេលណាសមស្របដើម្បីបន្តធ្វើផ្ដល់សក្ខីកម្ម ឲ្យអ៊ំផ្ដល់សក្ខីកម្មបញ្ចប់ប្រហែលជានៅកម្រិតមិនដល់ ឬក៏ត្រឹមយ៉ាងយូរពីរម៉ោងទៀតប៉ុណ្ណោះលើការផ្ដល់សក្ខីកម្មរបស់អ៊ំណា។ ប៉ុន្តែដោយសារមិនទាន់ច្បាស់សាល់ អាហ្នឹងចាំប្រគល់តួនាទីទៅឲ្យខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញសម្របសម្រួលលើបញ្ហានេះចុះ។

ឥឡូវនេះដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺសមល្មមនឹងឈប់សម្រាកហើយ។

ដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមត្រូវ ហើយសវនាការត្រូវលើកទៅបន្តនៅថ្ងៃស្អែក ចាប់វេលាម៉ោងប្រាំបួនព្រឹក ហើយកិច្ចដំណើរការ ការប្រមើលមើល និងការតាមផែនការគឺត្រូវបន្តស្ដាប់សក្ខីកម្មសាក្សីរូបនេះតទៅទៀត ប៉ុន្តែក្នុងករណីមិនអាចដំណើរការបានដូចអ្វីដែលគាត់បានបង្ហាញស្ថានភាពជាក់ស្ដែងរបស់សាក្សីរូបនេះ អង្គជំនុំជម្រះគឺនឹងដំណើរស្ដាប់បន្តស្ដាប់សក្ខីកម្ម-- សួរចម្លើយជនជាប់ចោទនេះជាបន្តនៅថ្ងៃស្អែក។

[១៦:០៤:០១]

ដូច្នេះ ភាគីនិងសាធារណជនជ្រាប ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងវិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ សូមសម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*